# ព្រះ

# អភិធម្មត្ថសង្គហ

## បរិច្ឆេទទី ៣

# បកិណ្ណកសង្គហវិភាគ

រៀបរៀងដោយ

បណ្ឌិតធម្មាចារ្យ រស់ សុជាត

ព.ស ២៥៤១

# អភិធម្មត្ថសង្គហ

## បរិច្ឆេទទី ៣

## បកិណ្ណកសង្គហវិភាគ

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

------ ◎ ------

# សេចក្តីផ្តើម

ព្រះអនុរុទ្ធាចារ្យ បានរួបរួមឡើងនូវ ព្រះអភិធម្មត្ថសង្គហៈ បរិច្ឆេទទី៣ នេះ មានឈ្មោះថា **បកិណ្ណកសង្គហវិភាគ** ។

**បកិណ្ណកៈ** ប្រែថា រាត់រាយ រាត់រាយ ច្របូកច្របល់ ពាសពេញ ។

**សង្គហៈ** ប្រែថា រួបរួម ។

**វិភាគ** ប្រែថា វគ្គ ឬ ជំពូក ។

ដូច្នេះ បកិណ្ណកសង្គហវិភាគ ប្រែថា ជំពូករួបរួមចិត្ត និង ចេតសិក ដែលរតាត់រតាយពាសពេញទូទៅ ពោលគឺ សម្តែងអំពីការរួបរួមនូវ ចិត្ត និង ចេតសិក ដែលកើតឡើងនោះ ដោយប្រភេទនៃ វេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍ និង វត្ថុ តាមសមគួរ ។

ព្រះអភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៣ អំពីបកិណ្ណកសង្គហវិភាគនេះ ព្រះអនុរុទ្ធាចារ្យសម្តែងគាថាសង្គហៈទុក ១៤ គាថា ដែលនឹងត្រូវពង្រីកសេចក្តីតាមលំដាប់ដូចតទៅ :-

# គាថាសង្គហៈ

១. សម្បយុត្តា យថាយោគំ តេបញ្ញាស សភាវតោ
ចិត្តចេតសិកាធម្មា តេសន្ទានិ យថារហំ
២. វេទនាហេតុតោ កិច្ច ទ្វារាលម្ពណវត្ថុតោ
ចិត្តុប្បាទវសេនេវ សង្គហោ នាម និយតេ

សភាវធម៌ ៥៣ គឺ ចិត្ត និង ចេតសិក ពោលដោយលក្ខណៈរបស់ខ្លួន ប្រកបដល់គ្នានឹងគ្នា ដោយឯកុប្បាទៈជាដើមតាមដែលប្រកបបាន សម្តែងពិស្តាររួចមកហើយ ។

ឥឡូវនេះ នឹងនាំយកនូវបកិណ្ណកសង្គហៈនៃចិត្ត និង ចេតសិក ទាំងនោះ មកសម្តែងដោយប្រភេទនៃ វេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍ និង វត្ថុ តាមសមគួរនៃការប្រកបបាន ។

សភាវធម៌ ៥៣ យ៉ាងដែលពោលមកនោះ សំដៅយកចិត្ត ១ និង ចេតសិក ៥២ សឹងរាប់ដោយការកាន់យកសភាវលក្ខណៈនៃនាមធម៌នោះៗជាការសំខាន់ គឺថា **ចិត្ត** សូម្បី មានចំនួន ៨៩ ឬ ១២១ ដួងក៏ដោយ កាលបើរាប់ដោយសភាវលក្ខណៈហើយ ក៏មានត្រឹមតែ ១ គឺ មានការដឹងនូវអារម្មណ៍ ជាលក្ខណៈ ( អារម្មណវិជានន លក្ខណំ ) **ផស្សចេតសិក** មានការប៉ះខ្ទប់នឹងអារម្មណ៍ជាលក្ខណៈ( ផុសនលក្ខណោ ) **វេទនាចេតសិក** មានការសោយអារម្មណ៍ ជាលក្ខណៈ ( អនុភវន លក្ខណា ) ចេតសិកទាំង ៥២ ប្រភេទនេះ មានសភាវលក្ខណៈដោយចំពោះផ្ទាល់ៗខ្លួន ផ្សេងៗគ្នាទាំង ៥២ ប្រភេទ ដូច្នេះកាលបើរួបរួម ចិត្ត និង ចេតសិក ចូលគ្នាហើយ ក៏បានសភាវធម៌ ៥៣ ដែលមានឈ្មោះថា **នាម-តេបញ្ញាស** ។

ចំពោះគាថាទី ២ ព្រះអនុរុទ្ធាចារ្យមានបំណងប្រាថ្នា សម្តែងដើម្បីឲ្យជា **បុញ្ញានុសន្ធិ** និង **អបរានុសន្ធិ** គឺ ប្រទាក់ ភ្ជាប់គ្នា

រវាង បរិច្ឆេទទី ២ ដែលបានសម្ដែងរួចមកហើយ និងបរិច្ឆេទទី ៣ ដែលនឹងត្រូវសម្ដែងតទៅ ។ ម្យ៉ាងទៀត ដើម្បីកំណត់នូវមេបទក្នុង បរិច្ឆេទទី ៣ ថា នឹងសម្ដែងសង្គហៈ ៦ យ៉ាង មានវេទនាសង្គហៈ ជាដើម ទាំងដើម្បីបង្ហាញនូវសេចក្ដីប្ដេជ្ញាថា នឹងពង្រីកសេចក្ដីនៃការ កើតឡើងនៃចិត្ត ដោយប្រភេទនៃ **វេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍** និង **វត្ថុ** ។

ព្រះអភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៣ ព្រះអនុរុទ្ធាចារ្យ បាន សម្ដែងទុកនូវការចែកចិត្តតែម្យ៉ាងប៉ុណ្ណោះ មិនបានសម្ដែងការចែក ចេតសិកទុកផងទេ ប៉ុន្តែការកើតឡើងនៃចិត្តដែលហៅថា **ចិត្តុប្បាទ** គឺ ចិត្តដែលកើតព្រមគ្នានឹងចេតសិក , ដូច្នេះទើបជាការសមគួរ ដែលនឹងអាចសម្ដែងទុកនូវការសង្គ្រោះ ទាំងចិត្ត ទាំងចេតសិក ដោយ ប្រភេទនៃ **វេទនា ហេតុ កិច្ច ទ្វារ អារម្មណ៍** និង **វត្ថុ** ឲ្យពិស្តារ ដោយន័យទៅតាមលំដាប់ ។

-------- • --------

# វេទនាសង្គហៈ

ការរួបរួមនូវចិត្ត – ចេតសិកដោយប្រភេទនៃវេទនា ឈ្មោះថា **វេទនាសង្គហៈ** ។

## គាថាសង្គហៈ

៣. សុខំ ទុក្ខមុបេក្ខាតិ តិវិធា តត្ថវេទនា
សោមនស្សំ ទោមនស្សំ ឥតិភេទេន បញ្ចធា

ប្រែថា ក្នុងវេទនាសង្គហៈ នោះ កាលបើពោលដោយ **អារម្មណានុភវនលក្ខណៈ** គឺ លក្ខណៈនៃការសោយនូវអារម្មណ៍ ហើយ មានវេទនា ៣ យ៉ាង គឺ :-

**១. សុខវេទនា**

**២. ទុក្ខវេទនា**

**៣. ឧបេក្ខាវេទនា**

កាលបើពោលដោយ **ឥន្ទ្រិយភេទ** គឺ ប្រភេទជាធំនៃវត្ថុទទួល

អារម្មណ៍ហើយ មានវេទនា ៥ យ៉ាង គឺ :-

**១. សុខវេទនា** **២. ទុក្ខវេទនា**

**៣. សោមនស្សវេទនា** **៤. ទោមនស្សវេទនា**

**៥. ឧបេក្ខាវេទនា**

# អធិប្បាយ

“ **វេទនា** ” ជាចេតសិកបរមត្ថមួយប្រភេទ ដែលមានការប្រព្រឹត្តិទៅ ដោយអាការសោយនូវអារម្មណ៍ជាលក្ខណៈ ឬ ជាធម្មជាតិ ដែលមានសេចក្ដីដឹងខ្លួនចំពោះបណ្ដាអារម្មណ៍ទាំងពួងដែលមកប្រាកដ ។ ការសង្គ្រោះចិត្ត-ចេតសិក ដោយប្រភេទនៃវេទនានេះ មានសម្ដែងទុកជា ២ ន័យ :-

**ន័យទី ១** សម្ដែងដោយ **អារម្មណានុភវនលក្ខណន័យ** គឺ ន័យដែលសម្ដែងពីការប្រព្រឹត្តិទៅនៃការសោយនូវអារម្មណ៍ ។

**ន័យទី ២** សម្ដែងដោយ **ឥន្ទ្រិយភេទន័យ** គឺ ន័យដែលសម្ដែងពីសភាពជាធំក្នុងការសោយនូវអារម្មណ៍ តាមប្រភេទនៃវត្ថុទទួលអារម្មណ៍ ។

# ន័យទី ១
# អារម្មណានុភវនលក្ខណន័យ មានវេទនា ៣

ក្នុងបណ្ដាអារម្មណ៍ ៦ គឺ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ដែលសត្វទាំងឡាយបានទទួលជានិច្ចនេះ ចែកចេញជា ៣ ប្រភេទ គឺ :-

**១. ឥដ្ឋារម្មណ៍** គឺ អារម្មណ៍ល្អ ។

**២. អនិដ្ឋារម្មណ៍** គឺ អារម្មណ៍មិនល្អ ។

**៣. មជ្ឈត្តារម្មណ៍** គឺ អារម្មណ៍ជាកណ្ដាល។

សេចក្ដីដឹងខ្លួន ក្នុងការសោយអារម្មណ៍របស់សត្វនោះ តែងប្រព្រឹត្តទៅតាមប្រភេទនៃអារម្មណ៍ គឺ :-

**១.** ខណៈដែលកំពុងនៅសោយឥដ្ឋារម្មណ៍នោះ ក៏ដឹងខ្លួនសប្បាយកាយ សប្បាយចិត្ត សេចក្ដីដឹងខ្លួនសប្បាយនេះ ហៅថា **សុខវេទនា** ។

**២.** ខណៈដែលកំពុងនៅសោយអនិដ្ឋារម្មណ៍នោះ ក៏ដឹងខ្លួនមិនសប្បាយកាយ មិនសប្បាយចិត្ត សេចក្ដីដឹងខ្លួនមិនសប្បាយនេះ

ហៅថា **ទុក្ខវេទនា** ។

**៣.** ខណៈដែលកំពុងនៅសោយមជ្ឈត្តារម្មណ៍នោះ ក៏ដឹងខ្លួនព្រងើយៗ មិនជាសុខ មិនជាទុក្ខ ទាំងកាយទាំងចិត្ត សេចក្ដីដឹងខ្លួនព្រងើយៗ មិនជាសុខ មិនជាទុក្ខនេះ ហៅថា **អទុក្ខមសុខវេទនា** ។

# សម្ដែងការចែកចិត្ត ១២១ ដោយវេទនា ៣

( អារម្មណានុភវនលក្ខណន័យ )

**១. ចិត្តដែលកើតព្រមនឹងសុខវេទនា** ទាំងសុខកាយទាំងសុខចិត្ត មាន ៦៣ ដួង គឺ :-

- សុខសហគតកាយវិញ្ញាណចិត្ត ១ ដួង
- សោមនស្សសហគតចិត្ត ៦២ ដួង
- រួមចិត្តដែលកើតព្រមនឹងសុខវេទនា ៦៣ ដួង

# តារាងរួមចិត្ត
# ដែលកើតព្រមនឹងសុខវេទនា ៦៣ ដួង

ចិត្តកើតព្រមនឹងសុខវេទនា ៦៣ ដួង

- -សុខសហគតកាយវិញ្ញាណចិត្ត ១ ដួង
- -កាមសោមនស្ស ១៨ ដួង
  - ស-លោភមូលចិត្ត ៤ ដ
  - ស-សន្តីរណចិត្ត ១ ដ
  - ស-ហសិតុប្បាទចិត្ត ១ ដ
  - ស-មហាកុសលចិត្ត ៤ ដ
  - ស-មហាកិរិយាចិត្ត ៤ ដ
  - ស-មហាវិបាកចិត្ត ៤ ដ
- -ឈានសោមនស្ស ៤៤ ដួង
  - បឋមជ្ឈានចិត្ត ១១ ដ
  - ទុតិយជ្ឈានចិត្ត ១១ ដ
  - តតិយជ្ឈានចិត្ត ១១ ដ
  - ចតុត្ថជ្ឈានចិត្ត ១១ ដ

**២. ចិត្តដែលកើតព្រមនឹងទុក្ខវេទនា** ទាំងទុក្ខកាយ ទាំងទុក្ខចិត្ត មាន ៣ ដួង គឺ :

- ទុក្ខសហគតកាយវិញ្ញាណចិត្ត ១ ដួង
- ទោមនស្សសហគតចិត្ត ២ ដួង
- រួមចិត្តដែលកើតព្រមនឹងទុក្ខវេទនា ៣ ដួង

# តារាងរួមចិត្ត ដែលកើតព្រមនឹងទុក្ខវេទនា ៣ ដួង

| | |
|---|---|
| ចិត្តដែលកើតព្រមនឹងទុក្ខវេទនា ៣ | -ទុក្ខសហគតកាយវិញ្ញាណ ១ |
| | -ទោមនស្សទោសមូលចិត្ត ២ |

**៣. ចិត្តដែលកើតព្រមនឹងអទុក្ខមសុខវេទនា** គឺសេចក្តីមិនសុខមិនទុក្ខ ទាំងកាយទាំងចិត្ត ហៅថា **ឧបេក្ខាវេទនា** មាន ៥៥ ដួង គឺ :

- ឧបេក្ខាសហគតចិត្ត ៥៥ ដួង
- រួមចិត្តដែលកើតព្រមនឹងឧបេក្ខាវេទនា ៥៥ ដួង

# តារាងរួមចិត្ត
# ដែលកើតព្រមនឹងឧបេក្ខាវេទនា ៥៥ ដួង

ចិត្តកើតព្រមនឹងអទុក្ខមសុខវេទនា ឬ ឧបេក្ខាវេទនា ៥៥ ដួង

- -កាមឧបេក្ខា
  - ឧបេក្ខាលោភមូលចិត្ត ៤ ដួង
  - ឧបេក្ខាមោហមូលចិត្ត ២ ដួង
  - ឧបេក្ខាអហេតុកចិត្ត ១៤ ដួង
  - ឧបេក្ខាមហាកុសលចិត្ត ៤ ដួង
  - ឧបេក្ខាមហាវិបាកចិត្ត ៤ ដួង
  - ឧបេក្ខាមហាកិរិយាចិត្ត ៤ ដួង
- -ឈានឧបេក្ខា
  - រូបាវចរបញ្ចមជ្ឈានចិត្ត ៣ ដួង
  - អរូបាវចរចិត្ត ១២ ដួង
  - លោកុត្តរបញ្ចមជ្ឈានចិត្ត ៨ ដួង

# ន័យទី ២

# ឥន្ទ្រិយភេទន័យ មានវេទនា ៥

## គាថាសង្គហៈ

៤. សុខមេកត្ថ ទុក្ខញ្ច ទោមនស្សំ ទ្វយេ ឋិតំ
ទ្វាសដ្ឋីសុ សោមនស្សំ បញ្ចបញ្ញាសកេតរា ។

ប្រែថា សុខវេទនា និង ទុក្ខវេទនា នីមួយៗប្រកបនៅក្នុងចិត្ត ១ ដួង ទោមនស្សវេទនាប្រកបក្នុងចិត្ត ២ ដួង សោមនស្ស-វេទនា ប្រកបនៅក្នុងចិត្ត ៦២ ដួង ឧបេក្ខាវេទនាប្រកបនៅក្នុងចិត្ត ៥៥ ដួង ( ពោលដោយឥន្ទ្រិយភេទន័យ ) ។

**ឥន្ទ្រិយភេទន័យ** គឺន័យដែលសម្តែងការសោយអារម្មណ៍តាមប្រភេទជាធំនៃវត្ថុទទួលអារម្មណ៍ ពោលគឺ ការសោយអារម្មណ៍របស់សត្វទាំងឡាយនោះ តែងប្រាកដច្បាស់តាមផ្លូវកាយខ្លះ តាមផ្លូវចិត្តខ្លះ។ ការប្រាកដច្បាស់ក្នុងការសោយ អារម្មណ៍នេះ ហៅថា ភាពជាធំក្នុងការសោយអារម្មណ៍ ដែលនឹងត្រូវប្រាកដបាន ២ ផ្លូវ គឺ ផ្លូវកាយ

និង ផ្លូវចិត្ត ។

**សេចក្ដីដឹងខ្លួនសប្បាយតាមផ្លូវកាយនោះ** វេទនាចេតសិក ដែលកើតព្រមនឹងសុខសហគតកាយវិញ្ញាណចិត្តនោះ ជាធំ ជាអ្នកគ្រប់គ្រងក្នុងការសោយអារម្មណ៍ ដែលសប្បាយកាយ ហៅវេទនានោះថា **សុខវេទនា** ។

**សេចក្ដីដឹងខ្លួនមិនសប្បាយតាមផ្លូវកាយនោះ** វេទនា-ចេតសិក ដែលកើតព្រមនឹងទុក្ខសហគតកាយវិញ្ញាណចិត្តនោះ ជាធំ ជាអ្នកគ្រប់គ្រងក្នុងការសោយអារម្មណ៍ ដែលមិនសប្បាយកាយ ហៅវេទនានោះថា **ទុក្ខវេទនា** ។

**សេចក្ដីដឹងខ្លួនសប្បាយតាមផ្លូវចិត្តនោះ** វេទនាចេតសិក ដែលកើតព្រមនឹងសោមនស្សសហគតចិត្តនោះ ជាធំ ជាអ្នកគ្រប់គ្រងក្នុងការសោយអារម្មណ៍ ដែលសប្បាយចិត្ត ហៅវេទនានោះថា **សោមនស្សវេទនា** ។

**សេចក្ដីដឹងខ្លួនមិនសប្បាយតាមផ្លូវចិត្តនោះ** វេទនា-ចេតសិក ដែលកើតព្រមនឹងទោសមូលចិត្តនោះ ជាធំ ជាអ្នកគ្រប់គ្រងក្នុងការសោយអារម្មណ៍ ដែលមិនសប្បាយចិត្ត ហៅវេទនានោះថា **ទោមនស្សវេទនា** ។

**សេចក្តីដឹងខ្លួនព្រងើយ ។** ដែលប្រាកដបានចំពោះតាមផ្លូវចិត្តនោះ វេទនាចេតសិកដែលកើតព្រមនឹងឧបេក្ខាសហគតចិត្ត ជាធំជាអ្នកគ្រប់គ្រងក្នុងការសោយអារម្មណ៍ ដែលដឹងខ្លួនព្រងើយៗ ហៅវេទនានោះថា **ឧបេក្ខាវេទនា** ។

រួមសេចក្តីថា ភាពធំក្នុងការសោយអារម្មណ៍របស់សត្វទាំងឡាយដែលប្រាកដតាមផ្លូវកាយ និង តាមផ្លូវចិត្តនោះ មានវេទនាកើតបាន ៥ យ៉ាង គឺ :

## ១. តាមផ្លូវកាយ មាន ២ យ៉ាង

- សេចក្តីដឹងខ្លួនសប្បាយកាយ ហៅថា **សុខវេទនា** ។
- សេចក្តីដឹងខ្លួនមិនសប្បាយកាយ ហៅថា **ទុក្ខវេទនា** ។

## ២. តាមផ្លូវចិត្ត មាន ៣ យ៉ាង

- សេចក្តីដឹងខ្លួនសប្បាយចិត្ត ហៅថា **សោមនស្សវេទនា** ។
- សេចក្តីដឹងខ្លួនមិនសប្បាយចិត្ត ហៅថា **ទោមនស្សវេទនា**។
- សេចក្តីដឹងខ្លួនព្រងើយៗ ហៅថា **ឧបេក្ខាវេទនា** ។

# សម្តែងការចែកចិត្ត ១២១ ដោយវេទនា ៥

( ឥន្ទ្រិយភេទន័យ )

**១.** ចិត្តដែលកើតព្រមនឹង**សុខវេទនា** (សុខកាយ) មាន **១** ដួង បានដល់ :

- សុខសហគតកាយវិញ្ញាណចិត្ត ១ ដួង

**២.** ចិត្តដែលកើតព្រមនឹង**ទុក្ខវេទនា** (ទុក្ខកាយ) មាន ១ ដួង បានដល់ :

- ទុក្ខសហគតកាយវិញ្ញាណចិត្ត ១ ដួង

**៣.** ចិត្តដែលកើតព្រមនឹង**សោមនស្សវេទនា** (សុខចិត្ត) មាន ៦២ ដួង បានដល់ :-

- កាមសោមនស្សសហគតចិត្ត ១៨ ដួង
- ឈានសោមនស្សសហគតចិត្ត ៤៤ ដួង

រួមចិត្តដែលកើតព្រមនឹងសោមនស្សវេទនា ៦២ ដួង

**៤.** ចិត្តដែលកើតព្រមនឹងទោមនស្សវេទនា (ទុក្ខចិត្ត) មាន ២ ដួង បានដល់ :-

- ទោមនស្សសហគតចិត្ត (ទោសមូលចិត្ត) ២ ដួង

**៥.** ចិត្តដែលកើតព្រមនឹងឧបេក្ខាវេទនា (ព្រងើយៗ) មាន ៥៥ ដួង បានដល់ :-

- កាមឧបេក្ខាសហគតចិត្ត ៣២ ដួង
- ឈានឧបេក្ខាសហគតចិត្ត ២៣ ដួង

រួមចិត្តដែលកើតព្រមនឹងឧបេក្ខាវេទនា ៥៥ ដួង

--------- • ---------

# តារាង

# ចែកចិត្ត ១២១ ដោយវេទនា ៥

**ការចែក ចិត្ត ១២១ ដួង ដោយ វេទនា ៥**

- **-ចិត្តកើតព្រមនឹងសុខវេទនា ១ ដួង៖** សុខសហគតកាយវិញ្ញាណចិត្ត ១
- **-ចិត្តកើតព្រមនឹងទុក្ខវេទនា ១ ដួង៖** ទុក្ខសហគតកាយវិញ្ញាណចិត្ត ១
- **ចិត្តកើតព្រមនឹង សោ.វេទនា ៦២ ដួង**
  - -កាមសោ.១៨
    - -សោ.លោភមូលចិត្ត ៤
    - -សោ.សន្តីរណចិត្ត ១
    - -សោ.ហសិតុប្បាទចិត្ត ១
    - -សោ.មហាកុសលចិត្ត ៤
    - -សោ.មហាវិបាកចិត្ត ៤
    - -សោ.មហាកិរិយាចិត្ត ៤
  - -ឈានសោ.៤៤
    - -បឋមជ្ឈានចិត្ត ១១
    - -ទុតិយជ្ឈានចិត្ត ១១
    - -តតិយជ្ឈានចិត្ត ១១
    - -ចតុត្ថជ្ឈានចិត្ត ១១
- **-ចិត្តកើតព្រមនឹងទោ.វេទនា ២ ដួង** : ទោមនស្សសហគតចិត្ត ២ ដួង
- **-ចិត្តកើតព្រមនឹង ឧបេក្ខាវេទនា ៥៥ ដួង**
  - -កាមឧបេក្ខា
    - -ឧបេក្ខាលោភមូលចិត្ត ៤
    - -ឧបេក្ខាមោហមូលចិត្ត ២
    - -ឧបេក្ខាអហេតុកចិត្ត ១៤
    - -ឧបេក្ខាមហាកុសលចិត្ត ៤
    - -ឧបេក្ខាមហាវិបាកចិត្ត ៤
    - -ឧបេក្ខាមហាកិរិយាចិត្ត ៤
  - -ឈានឧបេក្ខា
    - -រូបាវចរបញ្ចមជ្ឈានចិត្ត ៣
    - -អរូបាវចរចិត្ត ១២
    - -លោកុត្តរបញ្ចមជ្ឈានចិត្ត ៨

# វេទនា និង ចេតសិក

វេទនានិងចេតសិកមានការសម្ដែងជា ២ ន័យ គឺ :

ក. សម្ដែងថា វេទនាណាកើតបាននឹងចេតសិកណាខ្លះ ។

ខ. សម្ដែងថា ចេតសិកណាកើតបាននឹងវេទនាណាខ្លះ ។

## ក. វេទនាកើតបាននឹងចេតសិក

**សុខវេទនា** កើតបាននឹងសព្វចិត្តសាធារណចេតសិក **៦** (វៀរវេទនាចេតសិក) ។

**ទុក្ខវេទនា** កើតបាននឹងសព្វចិត្តសាធារណចេតសិក **៦** (វៀរវេទនាចេតសិក) ។

**សោមនស្សវេទនា** កើតបាននឹងចេតសិក ៤៦ ដួង គឺ :-

-អញ្ញសមានាចេតសិក **១២**(វៀរវេទនាចេតសិក)

-អកុសលចេតសិក **៩**(វៀរទោចតុកៈ៤ វិចិកិច្ឆាចេតសិក១)

-សោភណចេតសិក **២៥** ។

**ទោមនស្សវេទនា** កើតបាននឹងចេតសិក **២១** ដួង គឺ :-

-អញ្ញសមានាចេតសិក **១១** ( វៀរ វេទនា បីតិ )

-អកុសលចេតសិក **១០** ( វៀរលោភិកៈ ៣ វិចិកិច្ឆា-
ចេតសិក ១ )

**ឧបេក្ខាវេទនា** កើតបាននឹងចេតសិក **៤៦** ដួង គឺ :-

-អញ្ញសមានាចេតសិក **១១** ( វៀរ វេទនា បីតិ )

-អកុសលចេតសិក **១០** ( វៀរ ទោចតុកៈ ៤ )

-សោភណចេតសិក **២៥**

# ខ. ចេតសិកដែលកើតព្រមនឹងវេទនា

**១.** ចេតសិកដែលកើតព្រមនឹងវេទនាតែមួយប្រភេទ មាន **៦** ដួង គឺ :-

**-បីតិចេតសិក** ១ កើតព្រមនឹងសោមនស្សវេទនាតែម្យ៉ាង

**-ទោចតុកចេតសិក** ៤ កើតព្រមនឹងទោមនស្សតែម្យ៉ាង

**-វិចិកិច្ឆាចេតសិក** ១ កើតព្រមនឹងឧបេក្ខាតែម្យ៉ាង

**២.** ចេតសិកដែលកើតព្រមនឹងវេទនា **២** មាន **២៨** ដួង គឺ :-

**-លោតិកចេតសិក ៣** ⎫ កើតព្រមនឹងសោមនស្សវេទនាក៏បាន
**-សោភណចេតសិក ២៥** ⎭ ឬ កើតព្រមនឹងឧបេក្ខាវេទនាក៏បាន

**៣.** ចេតសិកដែលកើតព្រមនឹងវេទនា **៣** មាន **១១** ដួង គឺ :

**-មោចត្តុកចេតសិក ៤**
**-ថីនមិទ្ធចេតសិក ២**
**-វិតក្កចេតសិក ១**
**-វិចារចេតសិក ១**
**-អធិមោក្ខចេតសិក ១**
**-វីរិយចេតសិក ១**

កើតព្រមនឹងសោមនស្សវេទនាក៏បាន ឬ ទោមនស្សវេទនា ឬ ឧបេក្ខាវេទនា យ៉ាងណាក៏បាន ។

**-ឆន្ទចេតសិក ១**

**៤.** ចេតសិកដែលកើតព្រមនឹងវេទនា **៥** មាន **៦** ដួង គឺ :

**-សព្វចិត្តសាធារណចេតសិក ៦** (វៀរវេទនាចេតសិក) ។

**៥.** ចេតសិកដែលមិនកើតព្រមនឹងវេទនា មាន **១** ដួង គឺ :

**-វេទនាចេតសិក ១**

( ចប់វេទនាសង្គហៈ )

# ហេតុសង្គហៈ

ការរួបរួមនូវចិត្តនិងចេតសិក ដោយប្រភេទនៃហេតុ ឈ្មោះថា **ហេតុសង្គហៈ** ។

## គាថាសង្គហៈ

៥. លោភោ ទោសោ ច មោហោ ច
ហេតូអកុសលា តយោ
អលោភោទោសោមោហា ច
កុសលា ព្យាកតា តថា

ប្រែថា លោភៈ ទោសៈ មោហៈ ជាអកុសលហេតុ អលោភៈ អទោសៈ អមោហៈ ជាកុសលហេតុ និងជាអព្យាកតហេតុ ក៏បានដែរ ។

# អធិប្បាយ

“ **ហេតុ** ” ជាធម្មជាតិដែលឲ្យផលធម៌កើតឡើង និងឲ្យផលធម៌នោះមានសភាពតាំងនៅក្នុងអារម្មណ៍ ព្រមទាំងញ៉ាំងផលធម៌នោះឲ្យសម្រេចក្រៃលែងឡើង ដូចជាដើមឈើ ដែលដុះនៅយ៉ាងមាំ និងល្វូតលាស់មានផ្លែផ្កាដូច្នោះ ។

ធម៌ដែលជាហេតុ ធ្វើឲ្យផលធម៌ប្រាកដឡើងមាន ៦ ប្រការ គឺ :

១. **លោភហេតុ** អង្គធម៌បានដល់ លោភចេតសិក
២. **ទោសហេតុ** អង្គធម៌បានដល់ ទោសចេតសិក
៣. **មោហហេតុ** អង្គធម៌បានដល់ មោហចេតសិក
៤. **អលោភហេតុ** អង្គធម៌បានដល់ អលោភចេតសិក
៥. **អទោសហេតុ** អង្គធម៌បានដល់ អទោសចេតសិក
៦. **អមោហហេតុ** អង្គធម៌បានដល់ បញ្ញាចេតសិក

**ផលធម៌ដែលកើតពីហេតុ** បានដល់ កុសលចិត្ត អកុសលចិត្ត អព្យាកតចិត្ត ឬ កាយកម្ម វចីកម្ម មនោកម្ម ឬក៏ខន្ធ

៥ ដែលប្រាកដឡើង ក្នុងបដិសន្ធិកាល និង ក្នុងបវត្តិកាល ។

**អារម្មណ៍** បានដល់ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ (សភាវៈដែលប្រាកដតាមផ្លូវចិត្ត ដែលទាក់ទងដោយវត្ថុមានជីវិត និងមិនមានជីវិត ឈ្មោះនាមផ្សេងៗ ពាក្យពោលផ្សេងៗ រឿងរ៉ាវផ្សេងៗ) ។

**ហេតុធ្វើឲ្យផលធម៌តាំងមាំបានក្នុងអារម្មណ៍** គឺកាលបើភ្នែកឃើញរូបក្តី ត្រចៀកឮសម្លេងក្តី រហូតដល់នឹកគិត រឿងរ៉ាវផ្សេងៗហើយ **អកុសលចិត្ត** ឬ **កុសលចិត្ត**ទាំងនេះ រមែងប្រាកដឡើង និងកាន់យកអារម្មណ៍ផ្សេងៗទាំងនោះ ទុកយ៉ាងមាំ ។

**ហេតុធ្វើឲ្យផលធម៌ចម្រើនឡើងបាន** គឺកាលអកុសលចិត្ត ឬ កុសលចិត្តជាដើម កាន់យកអារម្មណ៍ផ្សេងៗនោះទុកហើយ ក៏រមែងអាចមានកម្លាំងបន្តិចម្តងៗ ច្រើនឡើងៗ រហូតអាចឲ្យសម្រេចជាកាយកម្ម វចីកម្ម និងមនោកម្មបាន ដោយសេចក្តីថា លោភៈ ទោសៈ មោហៈ ក៏ដោយ ឬ អលោភៈ អទោសៈ អមោហៈ ក៏ដោយទាំងអស់នេះ កាលខណៈកើតឡើងដំបូងនោះ នៅមានកម្លាំងទន់ខ្សោយ មិនទាន់អាចធ្វើឲ្យការប្រព្រឹត្តិកន្លងល្មើសទៅជាទុច្ចរិតកម្ម ឬជាសុចរិតកម្មបានទេ លុះដល់បានតាំងមាំ និងមានកម្លាំងច្រើនឡើង

ហើយ ក៏រមែងអាចធ្វើឲ្យការប្រព្រឹត្តិនូវទុច្ចរិត ឬសុចរិត ដែលឈានដល់ជាកម្មបថ ទាំងកុសលកម្មបថ ឬទាំងអកុសលកម្មបថកើតឡើងបាន ។

# សម្តែងការចែកចិត្តដោយហេតុ

## គាថាសង្គហៈ

៦. អហេតុកដ្ឋារសេក ហេតុកា ទ្វេ ទ្វីវីសតិ
ទិហេតុកា មតា សត្ត ចត្តាឡីស តិហេតុកា

ប្រែថា អហេតុកចិត្ត មាន **១៨** ឯកហេតុកចិត្ត មាន **២** ទ្វិហេតុកចិត្ត មាន **២២** តិហេតុកចិត្ត មាន **៤៧** ។

## អធិប្បាយ

ក្នុងចំនួនចិត្ត **៨៩** ឬ **១២១** ដួងនោះ កាលណាពោលដល់ ចិត្តដែលប្រកបដោយហេតុ ចែកចេញបានជា **២** ប្រភេទ គឺ :-

**១. អហេតុកចិត្ត** គឺចិត្តដែលកើតឡើងដោយមិនប្រកបជាមួយនឹងហេតុណាៗ ក្នុងហេតុទាំង **៦** នោះឡើយ មានចំនួន **១៨** ដួង គឺ :-

| | | |
|---|---|---|
| - បញ្ចទ្វារាវជ្ជនចិត្ត | **១** | ដួង |
| - ទ្វិបញ្ចវិញ្ញាណចិត្ត | **១០** | ដួង |
| - សម្បដិច្ឆន្នចិត្ត | **២** | ដួង |
| - សន្តីរណចិត្ត | **៣** | ដួង |
| - មនោទ្វារាវជ្ជនចិត្ត | **១** | ដួង |
| - ហសិតុប្បាទចិត្ត | **១** | ដួង |
| រួមជាអហេតុកចិត្ត | **១៨** | ដួង |

**២. សហេតុកចិត្ត** គឺចិត្តដែលកើតឡើងដោយមាន ហេតុ **៦** ណាមួយ ឬច្រើនដែលប្រកបជាមួយ មានចំនួន **៧១** ដួង ឬ **១០៣** ដួង គឺ :-

| | | |
|---|---|---|
| - អកុសលចិត្ត | **១២** | ដួង |
| - កាមាវចរសោភណចិត្ត | **២៤** | ដួង |
| - មហគ្គតចិត្ត | **២៧** | ដួង |

- លោកុត្តរចិត្ត **៨** ឬ **៤០** ដួង

រួមសហេតុកចិត្ត **៧១** ដួង ឬ **១០៣** ដួង

ក្នុងសហេតុកចិត្ត **៧១** ឬ **១០៣** ប្រភេទទៀត គឺ :-

**១. ឯកហេតុកចិត្ត** គឺ ជាចិត្តដែលមានហេតុតែ **១** ប្រកបជាមួយ មាន **២** ដួង បានដល់ មោហមូលចិត្ត **២** ដួង ដែលមានមោហហេតុ ប្រកបជាមួយ ។

**២. ទ្វិហេតុកចិត្ត** គឺ ជាចិត្តដែលមានហេតុ **២** ប្រកបជាមួយ មាន **២២** ដួង បានដល់ :-

- លោភមូលចិត្ត **៨** មានហេតុ **២** ប្រកប គឺ លោភហេតុ និង មោហហេតុ ។

- ទោសមូលចិត្ត **២** មានហេតុ **២** ប្រកប គឺ ទោសហេតុ និង មោហហេតុ ។

- មហាកុសលញាណវិប្បយុត្តចិត្ត **៤** មានហេតុ **២** ប្រកប គឺ អលោភហេតុ និង អទោសហេតុ ។

- មហាវិបាកញាណវិប្បយុត្តចិត្ត **៤** មានហេតុ **២** ប្រកប គឺ អលោភហេតុ និង អទោសហេតុ ។

- មហាកិរិយាញាណវិប្បយុត្តចិត្ត **៤** មានហេតុ **២** ប្រកប

គឺ អលោភហេតុ និង អទោសហេតុ ។

**៣. តិហេតុកចិត្ត** គឺ ជាចិត្តដែលមានហេតុ **៣** ប្រកប ជាមួយ មាន **៤៧** ដួង ឬ **៧៩** ដួង បានដល់ :-

- មហាកុសលញាណសម្បយុត្តចិត្ត **៤** មានហេតុ **៣** ប្រកប គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

- មហាវិបាកញាណសម្បយុត្តចិត្ត **៤** មានហេតុ **៣** ប្រកប គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

- មហាកិរិយាញាណសម្បយុត្តចិត្ត **៤** មានហេតុ **៣** ប្រកប គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

- មហគ្គតចិត្ត **២៧** មានហេតុ **៣** ប្រកប គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

- លោកុត្តរចិត្ត **៨** ឬ **៤០** មានហេតុ **៣** ប្រកប គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

# ការចែកហេតុដោយប្រភេទ នៃសោភណៈ និង អសោភណៈ

**អសោភណហេតុ** មាន **៣** ហេតុ បានដល់ លោភហេតុ ទោសហេតុ មោហហេតុ ដែលប្រកបជាមួយនឹងអកុសលចិត្ត **១២** ដួង តាមសមគួរ ។

ចំណែកអហេតុកចិត្ត **១៨** សូម្បីតែហេតុមួយ ប្រកបជាមួយ ក៏គ្មានដែរ ។

**សោភណហេតុ** មាន **៣** ហេតុ បានដល់ អលោភហេតុ អទោសហេតុ អមោហហេតុ ដែលប្រកបក្នុងសោភណចិត្ត **៥៩** ឬ **៩១** ដួង តាមសមគួរ ។

# ហេតុជាមួយនឹងធម៌

**ហេតុ ៦ ប្រការ** គឺ លោភៈ ទោសៈ មោហៈ អលោភៈ អទោសៈ អមោហៈ ហេតុទាំងអស់នេះ ជានាមធម៌ រមែងជ្រោម ជ្រែងគាំទ្រនាមធម៌និងរូបធម៌ កើតឡើងក្នុងសន្តានរបស់សត្វទាំង-

ឡាយ ។ នាមធម៌ និងរូបធម៌ដែលកើតឡើងដល់សត្វទាំងឡាយនោះ កាល ណាចែកដោយប្រភេទនៃធម៌ហើយ ក៏មាន **៣** ប្រការ គឺ អកុសល ធម៌ កុសលធម៌ និងអព្យាកតធម៌ ។ កាលណាចែកហេតុ **៦** ដោយប្រភេទនៃធម៌ ដូចបានពោលមកហើយនេះ ក៏អាចចែក បានយ៉ាងនេះ គឺ :-

# ការចែកហេតុ
# ដោយប្រភេទនៃធម៌

**អកុសលហេតុ** មាន **៣** ហេតុ បានដល់ លោភហេតុ ទោសហេតុ មោហហេតុ ដែលប្រកបជាមួយនឹងអកុសលចិត្ត **១២** តាមសមគួរ ។

**កុសលហេតុ** មាន **៣** ហេតុ បានដល់ អលោភហេតុ អទោសហេតុ អមោហហេតុ ដែលប្រកបក្នុងកុសលចិត្ត **២១** តាមសមគួរ ។

**អព្យាកតហេតុ** មាន **៣** ហេតុ បានដល់ អលោភហេតុ អទោសហេតុ អមោហហេតុ

ដែលប្រកបក្នុងសហេតុកវិបាកចិត្ត **២១** តាមសមគួរ ហៅថា " **វិបាកអព្យាកតហេតុ** " ។

និងដែលប្រកបក្នុងសហេតុកកិរិយាចិត្ត **១៧** តាមសមគួរ ហៅថា " **កិរិយាអព្យាកតហេតុ** " ។

# ការចែកហេតុ
# ដោយប្រភេទនៃជាតិ

**ហេតុ ៦ ប្រការ** បានដល់ លោភៈ ទោសៈ មោហៈ អលោភៈ អទោសៈ អមោហៈនេះ បើចែកចេញទៅតាមជាតិ គឺការកើតនៃចិត្ត ហើយ គិតតាមជាតិ មាន **៤** ជាតិ និងគិតតាមហេតុ មាន **១២** ហេតុ គឺ :-

**អកុសលជាតិ** មាន **៣** ហេតុ បានដល់ លោភហេតុ ទោសហេតុ មោហហេតុ ។

**កុសលជាតិ** មាន **៣** ហេតុ បានដល់ អលោភហេតុ អទោសហេតុ អមោហហេតុ ។

**វិបាកជាតិ** មាន **៣** ហេតុ គឺ អលោភហេតុ អទោសហេតុ

អមោហហេតុ ។

**កិរិយាជាតិ** មាន ៣ ហេតុ បានដល់ អលោភហេតុ អទោសហេតុ អមោហហេតុ ។

# ការចែកហេតុ ដោយប្រភេទនៃភូមិ

ហេតុ ៦ ប្រការនេះ បើចែកចេញទៅតាមភូមិ គឺ ភូមិរបស់ចិត្តហើយ គិតតាមហេតុមាន ១៥ ហេតុ គឺ :-

**កាមភូមិ** មាន ៦ ហេតុ គឺ លោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ ។

**រូបាវចរភូមិ** មាន ៣ ហេតុ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

**អរូបាវចរភូមិ** មាន ៣ ហេតុ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

**លោកុត្តរភូមិ** មាន ៣ ហេតុ គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

# ការចែកហេតុដោយ ប្រភេទនៃបុគ្គល

**បុថុជ្ជន** មាន **៦** ហេតុ បានដល់ លោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ ។

**សោតាបន្នបុគ្គល** មាន **៦** ហេតុ បានដល់ លោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហ-ហេតុ ។

**សកទាគាមិបុគ្គល** មាន **៦** ហេតុ បានដល់ លោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ ។

**អនាគាមិបុគ្គល** មាន **៥** ហេតុ បានដល់ លោភហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ ។

**ព្រះអរហន្ត** មាន **៣** ហេតុ បានដល់ អលោភហេតុ អទោសហេតុ អមោហហេតុ ៕

**សង្កេត :**

**ក្នុងអសោភណចិត្ត** គឺ **អហេតុកចិត្ត ១៨** ដួង ជាចិត្តដែលមិនមានហេតុប្រកបជាមួយឡើយ ។ ឯ**អកុសលចិត្ត ១២** ដួង ជាចិត្តដែលមានហេតុប្រកបជាមួយ យ៉ាងច្រើន **២** ហេតុ យ៉ាង តិច **១** ហេតុ ប៉ុណ្ណោះ ៕

- អសោភណចិត្ត **៣០** ដួង
  - អកុសលចិត្ត ១២ ដួង ។
  - អហេតុកចិត្ត ១៨ ដួង ។

**ក្នុងសោភណចិត្ត** គឺជាចិត្តដែលមានហេតុយ៉ាងច្រើន **៣** ហេតុ យ៉ាងតិច **២** ហេតុ ។

**សោភណចិត្ត ៥៩ ដួង**
- កាមាវចរសោភណចិត្ត ២៤ ដ
  - មហាកុសលចិត្ត ៨ ដួង
  - មហាវិបាកចិត្ត ៨ ដួង
  - មហាកិរិយាចិត្ត ៨ ដួង
- រូបាវចរសោភណចិត្ត ១៥ ដ
  - រូបាវចរកុសលចិត្ត៥ ដួង
  - រូបាវចរវិបាកចិត្ត ៥ ដួង
  - រូបាវចរកិរិយាចិត្ត៥ ដួង
- អរូបាវចរសោភណចិត្ត ១២ ដ
  - អរូបាវចរកុសលចិត្ត ៤ ដួង
  - អរូបាវចរវិបាកចិត្ត ៤ ដួង
  - អរូបាវចរកិរិយាចិត្ត ៤ ដួង
- លោកុត្តរសោភណចិត្ត ៨ ដ
  - លោកុត្តរកុសលចិត្ត ៤ ដួង
  - លោកុត្តរវិបាកចិត្ត ៤ ដួង

ចំពោះចិត្តដែលប្រកបជាមួយហេតុ **៤-៥-៦** នោះ មិនមាន ព្រោះលោភៈ ទោសៈ មោហៈ ជាផ្នែកអសោភណហេតុ និងអលោភៈ អទោសៈ អមោហៈ ជាផ្នែកសោភណហេតុ ទាំង **២** ផ្នែកនេះ នឹងប្រកបជាមួយចិត្តរួមគ្នានោះ មិនបានឡើយ ៕

# សម្តែងហេតុជាមួយនឹងចេតសិក

**ហេតុ ៦** គឺ លោភៈ ទោសៈ មោហៈ អលោភៈ អទោសៈ អមោហៈ ដែលជាចេតសិកធម៌នេះ សុទ្ធតែត្រូវកើតព្រមជាមួយនឹងចិត្ត រលត់ព្រមជាមួយនឹងចិត្ត មានអារម្មណ៍ដូចគ្នានឹងចិត្ត និងមានទីអាស្រ័យដូចគ្នានឹងចិត្ត ។

ហេតុ **៦** ក្រៅពីការកើតព្រមនឹងចិត្ត ដូចបានពោលមកហើយ នៅមានការកើតព្រមនឹងចេតសិកដទៃៗទៀតដែរ តាមដែលអាចប្រកបបាន ។

ដូច្នេះ ចេតសិកណា កើតព្រម ឬប្រកបនឹងហេតុ **៦** ណាៗខ្លះ មានការសម្តែងជា ២ ន័យ គឺ :-

**១. អគហិតគហនន័យ** គឺចេតសិកដែលរាប់ហើយ មិនរាប់ទៀតទេ បានសេចក្តីថា ចេតសិកណា ដែលបានយកមក តាំង

សម្ដែងហើយ មិនរាប់ចេតសិកនោះដដែលទៀតទេ បានដល់ ការលើក យកចេតសិកទាំង **៥២** ដួង មកសម្ដែងនីមួយៗថា ប្រកបនឹងហេតុណាខ្លះ យកមកសម្ដែងរហូត គ្រប់ចំនួនទាំង **៥២** ដួង ដោយមិនមានការរាប់ដដែលគ្នាឡើយ ។

**២. គហិតគហនន័យ** គឺ ចេតសិកដែលរាប់ហើយ រាប់ទៀតបាន បានសេចក្ដីថា កាលណាលើកយកចេតសិកណា មកសម្ដែងដោយការប្រកបនឹងហេតុណាមួយហើយ ប្រសិនបើ ចេតសិកដែលយកមកសម្ដែងហើយនោះ នៅអាចប្រកបនឹងហេតុដទៃបានទៀត ក៏ត្រូវតែ លើកយកមកពោលអាងទៀត ដូចជាមោហចេតសិកដែលរាប់ដោយ ការប្រកបនឹងលោភមូលចិត្តហើយ នៅតែត្រូវយកមករាប់ដដែលទៀត កាលដែលមោហចេតសិកនោះ ប្រកបនឹងទោសមូលចិត្តបានទៀតផង ។

# សម្ដែងការចែកចេតសិកដែល ប្រកបនឹងហេតុ ដោយអគហិតគហនន័យ

ចេតសិកដែលរាប់ហើយ មិនរាប់ទៀត មានការសម្ដែង **៧** ន័យ គឺ :-

**១. អហេតុកចេតសិក** ចេតសិកដែលមិនមានហេតុប្រកប នោះ មិនមាន ។

**២. ឯកហេតុកចេតសិក** ចេតសិកដែលមានហេតុប្រកប **១** ហេតុ មាន ៣ ដួង គឺ :-

- លោភចេតសិក មានហេតុប្រកប ១ គឺ មោហហេតុ
- ទោសចេតសិក មានហេតុប្រកប ១ គឺ មោហហេតុ
- វិចិកិច្ឆាចេតសិក មានហេតុប្រកប ១ គឺ មោហហេតុ

**៣. ទ្វិហេតុកចេតសិក** ចេតសិកដែលមានហេតុប្រកប **២** ហេតុ មាន ៩ ដួង គឺ :-

- មោហចេតសិក មានហេតុប្រកប **២** គឺ លោភហេតុ ទោសហេតុ ។

- ទិដ្ឋិចេតសិក
- មានះចេតសិក

} មានហេតុប្រកប **២** គឺ លោភហេតុ មោហហេតុ ។

- ឥស្សាចេតសិក
- មច្ឆរិយចេតសិក
- កុក្កុច្ចចេតសិក

} មានហេតុប្រកប **២** គឺ ទោសហេតុ មោហហេតុ ។

- អលោភចេតសិក មានហេតុប្រកប **២** គឺ អទោសហេតុ អមោហហេតុ ។
- អទោសចេតសិក មានហេតុប្រកប **២** គឺ អលោភហេតុ អមោហហេតុ ។
- បញ្ញាចេតសិក មានហេតុប្រកប **២** គឺ អលោភហេតុ អទោសហេតុ ។

**៤. តិហេតុកចេតសិក** ចេតសិកដែលមានហេតុប្រកប **៣** ហេតុ មាន **២៧** ដួង គឺ :-

- អហិរិកចេតសិក
- អនោត្តប្បចេតសិក
- ឧទ្ធច្ចចេតសិក
- ថីនចេតសិក
- មិទ្ធចេតសិក

} មានហេតុប្រកប **៣** គឺ លោភហេតុ ទោសហេតុ មោហហេតុ ។

- សោភណចេតសិក **២២** (វៀរអលោភៈ អទោសៈ បញ្ញា) មានហេតុប្រកប **៣** គឺ អលោភហេតុ អទោសហេតុ អមោហ-ហេតុ ។

**៥. ចតុហេតុកចេតសិក** ចេតសិកដែលមានហេតុប្រកប

៤ ហេតុ មិនមាន ។

**៦. បញ្ចហេតុកចេតសិក** ចេតសិកដែលមានហេតុប្រកប ៥ ហេតុ មាន ១ ដួង គឺ :-

- បីតិចេតសិក មានហេតុប្រកប ៥ គឺ លោភហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ ។

**៧. ឆហេតុកចេតសិក** ចេតសិកដែលមានហេតុប្រកប ៦ ហេតុ មាន ១២ ដួង គឺ :-

- អញ្ញសមានាចេតសិក ១២ (វៀរបីតិ) មានហេតុប្រកប ៦ គឺ លោភហេតុ ទោសហេតុ មោហហេតុ អលោភហេតុ អទោសហេតុ អមោហហេតុ ។

រួមចេតសិកដែលមានហេតុប្រកប ១ ហេតុ មាន ៣ ដួង

រួមចេតសិកដែលមានហេតុប្រកប ២ ហេតុ មាន ៩ ដួង

រួមចេតសិកដែលមានហេតុប្រកប ៣ ហេតុ មាន ២៧ ដួង

រួមចេតសិកដែលមានហេតុប្រកប ៥ ហេតុ មាន ១ ដួង

រួមចេតសិកដែលមានហេតុប្រកប ៦ ហេតុ មាន ១២ ដួង

រួមចេតសិកដែលមានហេតុប្រកប ៥២ ដួង ។

ការរាប់ចេតសិកដែលប្រកបនឹងហេតុនេះ ហៅថា “ **អគហិតគហានន័យ** ” គឺ ចេតសិកដែលរាប់ហើយមិនរាប់ទៀត ។

# សម្ដែងការចំណែកចេតសិកដែលប្រកបនឹងហេតុដោយគហិតគហានន័យ

ចេតសិកដែលរាប់ហើយ រាប់ទៀតតាមដែលប្រកបនឹងចិត្ត មានការសម្ដែង ៤ ន័យ គឺ :-

**១. អហេតុកចេតសិក** ជាចេតសិកដែលមិនមានហេតុប្រកប មាន **១៣** ដួង គឺ :-

-អញ្ញសមានាចេតសិក **១២** ( វៀរឆន្ទៈ ) ដែលប្រកបនឹង អហេតុកចិត្ត **១៨** ដួង ។

-មោហចេតសិក **១** ដែលប្រកបនឹងមោហមូលចិត្ត ២ ។

**២. ឯកហេតុកចេតសិក** គឺចេតសិកដែលមានហេតុប្រកប **១** ហេតុ មានចំនួន ២០ ដួង គឺ :-

| | | |
|---|---|---|
| -អញ្ញសមានាចេតសិក | ១១ | ដែលប្រកបនឹងមោហមូលចិត្ត ២ មានហេតុ ១ គឺ មោហហេតុ ។ |
| -អហិរិកចេតសិក | ១ | |
| -អនោត្តប្បចេតសិក | ១ | |
| -ឧទ្ធច្ចចេតសិក | ១ | |
| -វិចិកិច្ឆាចេតសិក | ១ | |
| -លោភចេតសិក | ១ | ដែលប្រកបនឹងលោភមូលចិត្ត ៨ មានហេតុប្រកប ១ គឺ មោហហេតុ ។ |
| -ទោសចេតសិក | ១ | ដែលប្រកបនឹងទោសមូលចិត្ត ២ មានហេតុប្រកប ១ គឺ មោហហេតុ ។ |
| -មោហចេតសិក | ១ | បើប្រកបនឹងលោភមូលចិត្ត ៨ មានហេតុប្រកប ១ គឺ លោភហេតុ បើប្រកបនឹងទោសមូលចិត្ត ២ មានហេតុប្រកប ១ គឺ ទោសហេតុ ។ |
| -អលោភចេតសិក | ១ | ដែលប្រកបនឹងញាណវិប្បយុត្តចិត្ត ១២ មានហេតុប្រកប ១ គឺ អទោសហេតុ ។ |
| -អទោសចេតសិក | ១ | ដែលប្រកបនឹងញាណវិប្បយុត្តចិត្ត ១២ |

មានហេតុប្រកប ១ គឺ អលោភហេតុ ។

**៣. ទ្វិហេតុកចេតសិក** គឺ ចេតសិកដែលមានហេតុប្រកប ២ ហេតុ មានចំនួន ៤៨ ដួង គឺ :-

**ក.** ចេតសិក ៤៥ ( វៀរហេតុកចេតសិក ៦ និង វិចិកិច្ឆា ១ ) ដែលប្រកបនឹងទ្វិហេតុកចិត្ត ២២ បានដល់ :-

-អញ្ញសមានាចេតសិក ១៣ ឬ ១២ ដែលប្រកបនឹងលោភមូលចិត្ត ៨ មានហេតុប្រកប ២ គឺ លោភហេតុ មោហហេតុ ។
និងដែលប្រកបនឹងទោសមូលចិត្ត ២ មានហេតុប្រកប ២ គឺ ទោសហេតុ មោហហេតុ ។
និងប្រកបនឹងញាណវិប្បយុត្តចិត្ត ១២ មានហេតុប្រកប ២ គឺ អលោភហេតុ អទោសហេតុ ។

-អហិរិកៈ ១
-អនោត្តប្បៈ ១
-ឧទ្ធច្ចៈ ១

{ ដែលប្រកបនឹងលោភមូលចិត្ត មានហេតុប្រកប ២ គឺ លោភហេតុ មោហហេតុ ។
និងដែលប្រកបនឹងទោសមូលចិត្ត មានហេតុប្រកប ២ គឺ ទោសហេតុ មោហហេតុ ។

-ទិដ្ឋិចេតសិក ១ ដែលប្រកបនឹងទិដ្ឋគតសម្បយុត្តចិត្ត ៤ មានហេតុប្រកប ២ គឺលោភហេតុ មោហហេតុ

-មានចេតសិក ១ ដែលប្រកបនឹងទិដ្ឋិគតវិប្បយុត្តចិត្ត ៤ មានហេតុប្រកប ២ គឺ លោភហេតុ មោហ-ហេតុ ។

-ឥស្សា ១
-មច្ឆរិយៈ ១
-កុក្កុច្ចៈ ១
ដែលប្រកបនឹងទោសមូលចិត្ត ២ មានហេតុប្រកប ២ គឺ ទោសហេតុ មោហហេតុ ។

-ថីនៈ ១
-មិទ្ធៈ ១
ដែលប្រកបនឹងលោភមូលសសង្ខារិកចិត្ត មានហេតុប្រកប ២ គឺ លោភហេតុ មោហហេតុ និងដែលប្រកបនឹងទោសមូលសសង្ខារិកចិត្តមានហេតុប្រកប ២ គឺ ទោសហេតុ មោហហេតុ ។

-សោភណចេតសិក ២២ (វៀរអលោភៈ អទោសៈ បញ្ញា)ដែលប្រកបនឹងញាណវិប្បយុត្តចិត្ត ១២មានហេតុប្រកប ២ គឺ អលោភហេតុ អទោសហេតុ ។

**៦.** ចេតសិក **៣** ដួង គឺ អលោភៈ អទោសៈ និង បញ្ញាដែលប្រកបនឹងតិហេតុកចិត្ត **៤៧** ឬ **៧៩** បានដល់ :-

-អលោភចេតសិក១ ដែលប្រកបនឹងញាណសម្បយុត្តចិត្ត **៤៧** ឬ **៧៩** មានហេតុប្រកប **២** គឺ អទោស-ហេតុ អមោហហេតុ ។

-អទោសចេតសិក ១ ដែលប្រកបនឹងញាណសម្បយុត្តចិត្ត **៤៧** ឬ **៧៩** មានហេតុប្រកប **២** គឺ អលោភ-ហេតុ អមោហហេតុ ។

-បញ្ញាចេតសិក ១ ដែលប្រកបនឹងញាណសម្បយុត្តចិត្ត **៤៧** ឬ **៧៩** មានហេតុប្រកប **២** គឺ អលោភ-ហេតុ អទោសហេតុ ។

**៤. តិហេតុកចេតសិក** គឺ ចេតសិកដែលមានហេតុប្រកប **៣** ហេតុ មានចំនួន **៣៥** ដួង គឺ :-

-អញ្ញសមានាចេតសិក **១៣** ដែលប្រកបនឹងតិហេតុកចិត្ត **៤៧** ឬ **៧៩** មានហេតុប្រកប **៣** គឺ អលោភ-ហេតុ អទោសហេតុ អមោហហេតុ ។

-សោភណចេតសិក **២២** ( វៀរអលោភៈ អទោសៈ អមោហៈ )

ដែលប្រកបនឹងតិហេតុកចិត្ត **៤៧** ឬ **៧៩** មានហេតុប្រកប **៣** គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

# ការរាប់ចំនួនហេតុដោយពិស្តារ

| | | |
|---|---|---|
| **១. អកុសលហេតុ** | មានចំនួន **២២** | គឺ :- |
| លោភហេតុ | មាន | **៨** |
| ទោសហេតុ | មាន | **២** |
| មោហហេតុ | មាន | **១២** |
| រួមជាអកុសលហេតុ | មាន | **២២** ។ |
| **២. កុសលហេតុ** | មានចំនួន **១០៧** | គឺ :- |
| អលោភហេតុ | មាន | **៣៧** |
| អទោសហេតុ | មាន | **៣៧** |
| អមោហហេតុ | មាន | **៣៣** |
| រួមជាកុសលហេតុ | មាន | **១០៧** ។ |
| **៣. វិបាកហេតុ** | មានចំនួន **១០៧** | គឺ :- |

| | | |
|---|---|---|
| អលោភហេតុ | មាន | **៣៧** |
| អទោសហេតុ | មាន | **៣៧** |
| អមោហហេតុ | មាន | **៣៣** |
| រួមជាវិបាកហេតុ | មាន | **១០៧** ។ |

## ៤. កិរិយាហេតុ មានចំនួន **៤៧** គឺ :-

| | | |
|---|---|---|
| អលោភហេតុ | មាន | **១៧** |
| អទោសហេតុ | មាន | **១៧** |
| អមោហហេតុ | មាន | **១៣** |
| រួមជាកិរិយាហេតុ | មាន | **៤៧** ។ |

រួមចំនួនហេតុដោយពិស្តារ មាន :

**២២ + ១០៧ + ១០៧ + ៤៧ = ២៨៣** ។

## ចប់ ហេតុសង្គហៈ

---------- • ----------

# កិច្ចសង្គហៈ

ការរួបរួមនូវ ចិត្ត-ចេតសិក ដោយប្រភេទនៃកិច្ច ឈ្មោះថា **កិច្ចសង្គហៈ** ។

# គាថាសង្គហៈ

**៧. បដិសន្ធាទយោ នាម កិច្ចភេទេន ចុទ្ទស**
**ទសធា ឋានភេទេន ចិត្តុប្បាទ បកាសិតា**

ប្រែថា បណ្ដាចិត្តទាំងឡាយដែលប្រាកដឡើង មានបដិសន្ធិចិត្តជាដើម ពោលដោយប្រភេទនៃកិច្ច មាន **១៤** កិច្ច បើពោលដោយប្រភេទនៃស្ថាន មាន **១០** ស្ថាន ។

# អធិប្បាយ

ក្នុងបណ្ដាការងារទាំងឡាយ ដែលប្រព្រឹត្តទៅតាម កាយ វាចា ចិត្ត ផ្សេងៗទាំងនេះ នឹងសម្រេចទៅបានសុទ្ធតែត្រូវអាស្រ័យចិត្ត និងចេតសិកជាអ្នកគ្រប់គ្រង និងជាអ្នកបញ្ជា ទើបការងារទាំងនោះ

ប្រព្រឹត្តទៅបានសម្រេច ពោលគឺ :-

**តាមផ្លូវកាយ** ឲ្យសម្រេចជាការប្រព្រឹត្តិផ្សេង ។ មានការអង្គុយ ដេក ឈរ ដើរ ដុសជូត សរសេរជាដើម ។ ទាំងនេះសម្រេចទៅ បានព្រោះចិត្តនិងចេតសិកបញ្ជាឲ្យធ្វើ បើចិត្ត និងចេតសិកមិនបញ្ជាឲ្យធ្វើទេ ការងារនោះក៏នឹងសម្រេចទៅមិនបានឡើយ ។

**តាមផ្លូវវាចា** ឲ្យសម្រេចជាការនិយាយ ការអាន ច្រៀង យំសូត្រ ទន្ទេញ សម្ដែងធម៌ ជេរជាដើម ។ ទាំងនេះ សម្រេចទៅបាន ព្រោះចិត្តនិងចេតសិកបញ្ជាឲ្យធ្វើ បើចិត្ត និងចេតសិកមិនបញ្ជាឲ្យនិយាយទេ ការងារនោះ ក៏មិនអាចសម្រេចទៅបានឡើយ ។

**តាមផ្លូវចិត្ត** ចិត្តនិងចេតសិកមិនបានបញ្ជាឲ្យត្រឹមតែ កាយ ឬ វាចាប្រព្រឹត្តបានប៉ុណ្ណោះទេ សូម្បីការងារដែលទាក់ទងនឹងចិត្ត មានការនឹកគិតរឿងរ៉ាវផ្សេងៗ ចិត្ត និង ចេតសិកនោះ ក៏ជាអ្នកបញ្ជាដោយខ្លួនឯង ឲ្យធ្វើការនឹកគិតទាំងនោះដែរ ។

សេចក្ដីនេះបង្ហាញឲ្យឃើញថា ចិត្ត និង ចេតសិកកើតរលត់ទៅដូចជាក្រសែទឹក ស្ទុះទៅក្នុងអារម្មណ៍រាល់ពេលវេលា និងអាចញ៉ាំងកិច្ចការងារផ្សេងៗឲ្យសម្រេចយ៉ាងច្រើនប្រការ យ៉ាងនេះ ។

ចិត្តនិងចេតសិកនេះ ជាប្រធានក្នុងធម៌ទាំងពួង មានការអង្គុយ

ដេក ដើរ ឈរ និយាយ នឹកគិតជាដើម ។

ដូច្នេះ ចិត្តនិងចេតសិកគ្រប់ដួងដែលប្រាកដឡើងនោះ រមែងមាននាទីការងារ គឺ កិច្ចរៀងៗខ្លួនជានិច្ច ។ ចិត្ត និង ចេតសិកនឹងប្រាកដឡើង ដោយមិនមាននាទីការងារអ្វីណាៗ នោះ មិនមានឡើយ ៕

ម្យ៉ាងទៀត ការធ្វើកិច្ចការងាររបស់ចិត្ត-ចេតសិកនោះ ចាំបាច់ត្រូវមានស្ថានទី គឺ ទីតាំងនៃការងារនោះ ។ ស្ថានទីដែលធ្វើកិច្ចការរបស់ចិត្តនិងចេតសិកទាំងនេះ ឈ្មោះថា **ស្ថាន** ។

បើនឹងឧបមា **ចិត្ត-ចេតសិក** ប្រៀបដូចជាអ្នកធ្វើការងារ **កិច្ច** ប្រៀបដូចជាការងារផ្សេងៗ **ស្ថាន** ប្រៀបដូចជាស្ថានទីកន្លែងធ្វើការងារ ។

ដូច្នេះការសម្រេចនៃការងារផ្សេងៗនោះ ទើបរមែងប្រកបទៅដោយ ចិត្ត ចេតសិក កិច្ច និង ស្ថាន ដែលនឹងត្រូវសម្តែងដោយលំដាប់ ដូចតទៅនេះ :

# សម្តែងកិច្ចរបស់ចិត្ត ១៤

នាទីរបស់ ចិត្ត-ចេតសិក ដែលធ្វើកិច្ចការងារទាំងអស់នោះ

មាន ១៤ យ៉ាង គឺ :

| | |
|---|---|
| ១. បដិសន្ធិកិច្ច | ធ្វើនាទីកើតបន្តទៅក្នុងភពថ្មី ។ |
| ២. ភវង្គកិច្ច | ធ្វើនាទីរក្សានូវអង្គភព ។ |
| ៣. អាវជ្ជនកិច្ច | ធ្វើនាទីជញ្ជឹងរាវរកទទួលអារម្មណ៍ ដែលប្រាកដថ្មី ។ |
| ៤. ទស្សនកិច្ច | ធ្វើនាទីឃើញ ។ |
| ៥. សវនកិច្ច | ធ្វើនាទីឮ ។ |
| ៦. ឃាយនកិច្ច | ធ្វើនាទីដឹងក្លិន ។ |
| ៧. សាយនកិច្ច | ធ្វើនាទីដឹងរស ។ |
| ៨. ផុសនកិច្ច | ធ្វើនាទីដឹងផោដ្ឋព្វៈ ។ |
| ៩. សម្បដិច្ឆន្នកិច្ច | ធ្វើនាទីទទួលបញ្ចារម្មណ៍ ។ |
| ១០. សន្តីរណកិច្ច | ធ្វើនាទីពិចារណាបញ្ចារម្មណ៍ ។ |
| ១១. វោដ្ឋវនកិច្ច | ធ្វើនាទីកាត់សម្រេចសេចក្ដីក្នុងបញ្ចារម្មណ៍ ។ |
| ១២. ជវនកិច្ច | ធ្វើនាទីសេព ឬសោយអារម្មណ៍ ។ |
| ១៣. តទាលម្ពណកិច្ច | ធ្វើនាទីទទួលអារម្មណ៍ ដែលសល់អំពីជវនៈ ។ |

**១៤. ចុតិកិច្ច** ធ្វើនាទីឃ្លាត ឬរលត់ចាកភពចាស់ ។

# អធិប្បាយ

**១. បដិសន្ធិកិច្ច** គឺ នាទីរបស់ចិត្តដែល **ធ្វើនាទីកើតឡើងបន្តទៅក្នុងភពថ្មី** ជាខណៈចិត្តដំបូងដែលប្រាកដឡើងក្នុងភពថ្មីនោះ ហើយនឹងប្រាកដឡើងត្រឹមតែខណៈចិត្តមួយប៉ុណ្ណោះ ក្នុងភពជាតិនីមួយ ៗ ។

**២. ភវង្គកិច្ច** គឺចិត្តដែល **ធ្វើនាទីរក្សាអង្គនៃភព** (ការកើត) គឺរក្សាកម្មវិបាករបស់រូបធម៌នាមធម៌ បន្តអំពីបដិសន្ធិវិបាក-ចិត្តនិងបដិសន្ធិកម្មជរូប ឲ្យតម្រង់តាំងនៅបានក្នុងភពនោះៗជាដរាបតាមអំណាចនៃជវនកម្ម នឹងបញ្ជូនផលឲ្យប្រព្រឹត្តទៅ តាមអាយុសង្ខារដែលគប្បីតាំងនៅបាន ។

ភវង្គកិច្ចនេះ ជានាទីធម្មតារបស់ចិត្ត ដែលនឹងត្រូវធ្វើកិច្ចនេះជានិច្ច ។ ចិត្តនឹងឈប់ធ្វើកិច្ចនេះ លុះត្រាតែខណៈណាមានអារម្មណ៍ថ្មីក្នុងបច្ចុប្បន្ន មកឃាត់ឲ្យចិត្តឡើងកាន់វិថី ទទួលអារម្មណ៍ថ្មីក្នុងបច្ចុប្បន្នប៉ុណ្ណោះ ។ កាលណាផុតចាកការឡើងកាន់វិថីទទួលអារម្មណ៍ហើយ ចិត្តក៏ត្រូវធ្វើនាទីក្នុងការរក្សាអង្គនៃភពជានិច្ចគ្រប់វេលា ។

៣. **អាវជ្ជនកិច្ច** គឺចិត្តដែល **ធ្វើនាទីជញ្ជឹងរាវរក ទទួលអារម្មណ៍ដែលមកប្រាកដដល់ខ្លួន** ទាំងតាមបញ្ចទ្វារ ឬ ទាំងតាមមនោទ្វារ ។ គឺជាចិត្តខណៈដំបូងដែលផ្ដាច់ចេញពីភវង្គកិច្ច ហើយ ត្រូវធ្វើនាទីអាវជ្ជនកិច្ចនេះភ្លាម ឬម្យ៉ាងទៀត ជាចិត្តដែលធ្វើ នាទីទទួលនូវអារម្មណ៍ថ្មីក្នុងបច្ចុប្បន្នភព ពោលគឺ ជាចិត្តដែលឡើងកាន់ វិថីទទួលអារម្មណ៍ថ្មី ។

៤. **ទស្សនកិច្ច** គឺចិត្តដែល **ធ្វើនាទីឃើញរូបារម្មណ៍** ចិត្តនេះ មានឈ្មោះហៅថា ចក្ខុវិញ្ញាណចិត្ត ព្រោះអាស្រ័យចក្ខុវត្ថុ ទើបឃើញរូបារម្មណ៍ ។ បើមិនមានចក្ខុប្បសាទធ្វើនាទីជាចក្ខុវត្ថុទេ ទស្សនកិច្ច គឺ ចិត្តធ្វើនាទីឃើញក៏កើតឡើងមិនបាន ហើយចិត្តដែល ធ្វើនាទីឃើញនេះ ក្នុងវិថីចិត្តនីមួយៗ ទស្សនកិច្ចនឹងមាន បានត្រឹមតែ មួយខណៈចិត្ត គឺ ខណៈដែលចក្ខុវិញ្ញាណចិត្តកើតឡើងក្នុងចក្ខុទ្វារវិថី ប៉ុណ្ណោះ ។

៥. **សវនកិច្ច** គឺចិត្តដែល **ធ្វើនាទីឮសទ្ទារម្មណ៍** ចិត្តនេះ មានឈ្មោះថា សោតវិញ្ញាណចិត្ត ព្រោះអាស្រ័យសោតវត្ថុ ទើបកើត ឮសទ្ទារម្មណ៍ ។ បើមិនមានសោតប្បសាទ ធ្វើនាទីជាសោតវត្ថុទេ សវនកិច្ច គឺ ចិត្តធ្វើនាទីឮក៏កើតឡើងមិនបាន ។ ហើយចិត្តដែលធ្វើ នាទីឮនេះ ក្នុងវិថីចិត្តនីមួយ ៗ សវនកិច្ចនឹងមាន បានត្រឹមតែមួយ

ខណៈចិត្ត គឺ ខណៈដែលសោតវិញ្ញាណចិត្តកើតឡើង ក្នុងសោតទ្វារវិថីប៉ុណ្ណោះ ។

**៦. ឃាយនកិច្ច** គឺចិត្តដែល **ធ្វើនាទីដឹងគន្ធារម្មណ៍** ចិត្តនេះមាន ឈ្មោះថា ឃានវិញ្ញាណចិត្ត ព្រោះអាស្រ័យឃានវត្ថុទើបដឹងគន្ធារម្មណ៍ ។ បើមិនមានឃានប្បសាទធ្វើនាទីជាឃានវត្ថុទេ ឃាយនកិច្ច គឺ ចិត្តធ្វើនាទីដឹងក្លិនក៏កើតឡើងមិនបាន ។ ហើយចិត្តដែលធ្វើនាទីដឹងក្លិននេះ ក្នុងវិថីចិត្តនីមួយៗ ឃាយនកិច្ចនឹងមានបានត្រឹមតែមួយខណៈចិត្ត គឺ ខណៈដែលឃានវិញ្ញាណចិត្តកើតឡើងក្នុងឃានទ្វារវិថីប៉ុណ្ណោះ ។

**៧. សាយនកិច្ច** គឺចិត្តដែល **ធ្វើនាទីដឹងរសារម្មណ៍** ចិត្តនេះ មានឈ្មោះថា ជិវ្ហាវិញ្ញាណចិត្ត ព្រោះអាស្រ័យជិវ្ហាវត្ថុទើបកើតដឹងរសារម្មណ៍ ។ បើមិនមានជិវ្ហាបសាទធ្វើនាទីជាជិវ្ហាវត្ថុទេ សាយនកិច្ច គឺ ចិត្តធ្វើនាទីដឹងរសក៏កើតឡើងមិនបាន ។ ហើយចិត្តដែលធ្វើនាទីដឹងរសនេះ ក្នុងវិថីចិត្តនីមួយៗ សាយនកិច្ចនឹងមានបានត្រឹមតែមួយខណៈចិត្ត គឺ ខណៈដែលជិវ្ហាវិញ្ញាណចិត្តកើតឡើងក្នុងជិវ្ហាទ្វារវិថីប៉ុណ្ណោះ ។

**៨. ផុសនកិច្ច** គឺចិត្តដែល **ធ្វើនាទីដឹងការប៉ះខ្ទប់ផោដ្ឋព្វារម្មណ៍** ចិត្តនេះមានឈ្មោះថា កាយវិញ្ញាណចិត្ត ព្រោះ

អាស្រ័យកាយវត្ថុ ទើបកើតដឹងការប៉ះខ្ទប់ផោដ្ឋព្វារម្មណ៍ ។ បើមិនមានកាយប្បសាទធ្វើនាទីជាកាយវត្ថុទេ ផុសនកិច្ច គឺ ចិត្តធ្វើនាទីដឹងការប៉ះខ្ទប់ផោដ្ឋព្វៈ ក៏កើតឡើងមិនបាន ។ ហើយចិត្តដែលធ្វើនាទីផុសនកិច្ចនេះ ក្នុងវិថីចិត្តនីមួយៗ ផុសនកិច្ចនឹងមាន បានត្រឹមតែមួយខណៈចិត្ត គឺ ខណៈដែលកាយវិញ្ញាណចិត្តកើតឡើង ក្នុងកាយទ្វារវិថីប៉ុណ្ណោះ ។

**៩. សម្បដិច្ឆន្នកិច្ច** គឺចិត្តដែល **ធ្វើនាទីទទួលបញ្ចារម្មណ៍** តអំពីបញ្ចវិញ្ញាណចិត្ត ក្នុងបញ្ចទ្វារវិថីនីមួយៗ សម្បដិច្ឆន្នកិច្ចនឹងកើតឡើង បានត្រឹមតែមួយខណៈចិត្តប៉ុណ្ណោះ ។

**១០. សន្តីរណកិច្ច** គឺចិត្តដែល **ធ្វើនាទីពិចារណាបញ្ចារម្មណ៍** ដែលទទួលមកអំពីសម្បដិច្ឆន្នចិត្ត ក្នុងបញ្ចទ្វារវិថីចិត្តនីមួយៗ សន្តីរណកិច្ចនឹងកើតឡើងបានត្រឹមតែមួយខណៈចិត្តប៉ុណ្ណោះ។

**១១. វោដ្ឋវនកិច្ច** គឺចិត្តដែល **ធ្វើនាទីកាត់សម្រេចសេចក្តីក្នុងបញ្ចារម្មណ៍** ដោយភាពជាកុសល ឬអកុសលជាដើម។ ចិត្តនេះ ឈ្មោះថា មនោទ្វារាវជ្ជនចិត្ត ធ្វើនាទីវោដ្ឋវនកិច្ចតាមបញ្ចទ្វារវិថី ។ ក្នុងវិថីចិត្តដែលសម្បូណ៌ វិថីចិត្តនីមួយៗ វោដ្ឋវនៈរមែងកើតបានត្រឹមតែមួយខណៈ ប៉ុន្តែបើក្នុងវិថីចិត្តមិនសម្បូណ៌ គឺក្នុងវោដ្ឋវនវារៈ អាចកើត បានដល់ ២-៣ ខណៈ ។

**១២. ជវនកិច្ច** គឺចិត្តដែល **ធ្វើនាទីសេពអារម្មណ៍ ៦** ដោយកុសលចិត្ត អកុសលចិត្ត កិរិយាចិត្ត និងដោយលោកុត្តរចិត្ត ។ ក្នុងវិថីចិត្តនីមួយៗដែលជាកាមវិថី ចំណែកច្រើនកើតជាប់គ្នា ៧ ខណៈ បើក្នុងអប្បនាវិថី អាចកើតបានច្រើនៗខណៈ រហូតដល់រាប់មិនបានក៏មាន ។

**១៣. តទាលម្ពណកិច្ច** គឺចិត្តដែល **ធ្វើនាទីទទួលអារម្មណ៍** ដែលសល់អំពីជវនសេពហើយ ក្នុងកាមារម្មណ៍ទាំង ៦ ដែលមានកម្លាំងខ្លាំង ។ ក្នុងវិថីចិត្តដែលទទួលអតិមហន្តារម្មណ៍ ឬវិភូតារម្មណ៍ សុទ្ធតែមានចិត្តដែលឈ្មោះថា តទាលម្ពណចិត្ត ហើយនឹងធ្វើតទាលម្ពណកិច្ច ២ ខណៈ ចិត្តចុងក្រោយក្នុងវិថីចិត្តដែលជាតទាលម្ពណវារៈ ។

**១៤. ចុតិកិច្ច** គឺចិត្តដែល **ធ្វើនាទីឃ្លាតចាកភពបច្ចុប្បន្ន** ជាចិត្តដួងចុងក្រោយ ដែលនឹងប្រាកដក្នុងភពជាតិនោះ ហើយនឹងប្រាកដបានត្រឹមតែ ១ ខណៈចិត្តប៉ុណ្ណោះ ក្នុងភពជាតិនីមួយៗ ដូចគ្នានឹងបដិសន្ធិកិច្ចដែរ ។ ចិត្តដែលធ្វើនាទីចុតិនេះ ជាចិត្តប្រភេទតែមួយ ដូចគ្នានឹងបដិសន្ធិចិត្ត និង ភវង្គចិត្តនោះឯង ។

# សម្តែងការចែកកិច្ច ១៤ ដោយចិត្ត

**១. បដិសន្ធិកិច្ច** ចិត្តដែលធ្វើនាទីបន្តភពថ្មី មាន ១៩ ដួង គឺ :

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ២ ដួង
- មហាវិបាកចិត្ត ៨ ដួង
- មហគ្គតវិបាកចិត្ត ៩ ដួង

**២. ភវង្គកិច្ច** ចិត្តដែលធ្វើនាទីរក្សាអង្គនៃភព មាន ១៩ ដួង គឺ :

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ២ ដួង
- មហាវិបាកចិត្ត ៨ ដួង
- មហគ្គតវិបាកចិត្ត ៩ ដួង

**៣. អាវជ្ជនកិច្ច** ចិត្តដែលធ្វើនាទីរាវរកទទួលអារម្មណ៍ថ្មី មាន ២ ដួង គឺ :

-ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១

-ឧបេក្ខាមនោធាតុអហេតុកកិរិយាចិត្ត ១

៤. **ទស្សនកិច្ច** ចិត្តដែលធ្វើនាទីឃើញ មាន ២ ដួង គឺ :

-ចក្ខុវិញ្ញាណចិត្ត ២ ដួង

៥. **សវនកិច្ច** ចិត្តដែលធ្វើនាទីឮ មាន ២ ដួង គឺ :

-សោតវិញ្ញាណចិត្ត ២ ដួង

៦. **ឃាយនកិច្ច** ចិត្តដែលធ្វើនាទីដឹងក្លិន មាន ២ ដួង គឺ :

-ឃានវិញ្ញាណចិត្ត ២ ដួង

៧. **សាយនកិច្ច** ចិត្តដែលធ្វើនាទីដឹងរស មាន ២ ដួង គឺ :

-ជីវ្ហាវិញ្ញាណចិត្ត ២ ដួង

៨. **ផុសនកិច្ច** ចិត្តដែលធ្វើនាទីដឹងផោដ្ឋព្វៈ មាន ២ ដួង គឺ :

-កាយវិញ្ញាណចិត្ត ២ ដួង

៩. **សម្បដិច្ឆន្នកិច្ច** ចិត្តដែលធ្វើនាទីទទួលបញ្ចារម្មណ៍ មាន ២ ដួង គឺ :-

-ឧបេក្ខាមនោធាតុអហេតុកវិបាកចិត្ត ២ ដួង

១០. **សន្តីរណកិច្ច** ចិត្តដែលធ្វើនាទីពិចារណាបញ្ចារម្មណ៍ មាន ៣ ដួង គឺ :

-ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ២ ដួង

-សោមនស្សមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ១ ដួង

**១១. វោដ្ឋវនកិច្ច** ចិត្តដែលធ្វើនាទីកាត់សម្រេចសេចក្តីក្នុងបញ្ចារម្មណ៍ មាន ១ ដួង គឺ :-

-ឧបេក្ខាមនោវិញ្ញាណអហេតុកកិរិយាចិត្ត ១ ដួង

**១២. ជវនកិច្ច** ចិត្តដែលធ្វើនាទីសេពអារម្មណ៍ មាន **៥៥** ដួង គឺ :-

| | | |
|---|---|---|
| -អកុសលចិត្ត | ១២ | ដួង |
| -ហសិតុប្បាទចិត្ត | ១ | ដួង |
| -មហាកុសលចិត្ត | ៨ | ដួង |
| -មហាកិរិយាចិត្ត | ៨ | ដួង |
| -មហគ្គតកុសលចិត្ត | ៩ | ដួង |
| -មហគ្គតកិរិយាចិត្ត | ៩ | ដួង |
| -លោកុត្តរចិត្ត | ៨ | ដួង |

**១៣. តទាលម្ពណកិច្ច** ចិត្តដែលធ្វើនាទីទទួលអារម្មណ៍ ដែលសល់អំពីជវន មាន ១១ ដួង គឺ :-

-មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ៣ ដួង

-មហាវិបាកចិត្ត ៨ ដួង

**១៤. ចុតិកិច្ច** ចិត្តដែលធ្វើនាទីរលត់អស់ចាកភពបច្ចុប្បន្ន មាន **១៩** ដួង គឺ :-

-ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត **២** ដួង

-មហាវិបាកចិត្ត **៨** ដួង

-មហគ្គតវិបាកចិត្ត **៩** ដួង

# សម្តែងការចែកចិត្ត ៨៩ ឬ ១២១ ដោយកិច្ច ១៤

**១.** ចិត្តដែលអាចធ្វើនាទីបាន **៥** កិច្ច មាន **២** ដួង គឺ :

-ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត **២** ដួង ធ្វើកិច្ច **៥** យ៉ាង គឺ :-

(១) **បដិសន្ធិកិច្ច** (២) **ភវង្គកិច្ច**

(៣) **ចុតិកិច្ច** (៤) **សន្តីរណកិច្ច**

(៥) **តទាលម្ពណកិច្ច** ។

២. ចិត្តដែលអាចធ្វើនាទីបាន ៤ កិច្ច មាន ៨ ដួង បានដល់ :

-មហាវិបាក ៨ ដួង ធ្វើកិច្ច ៤ យ៉ាង គឺ :

(១) **បដិសន្ធិកិច្ច** (២) **ភវង្គកិច្ច**

(៣) **ចុតិកិច្ច** (៤) **តទាលម្ពណកិច្ច**

៣. ចិត្តដែលអាចធ្វើនាទីបាន ៣ កិច្ច មាន ៩ ដួង គឺ :-

- មហគ្គតវិបាក ៩ ដួង ធ្វើកិច្ច ៣ យ៉ាង គឺ :-

(១) **បដិសន្ធិកិច្ច** (២) **ភវង្គកិច្ច**

(៣) **ចុតិកិច្ច** ។

៤. ចិត្តដែលអាចធ្វើនាទីបាន ២ កិច្ច មាន ២ ដួង គឺ :-

-សោមនស្សមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ១ ដួង ធ្វើកិច្ច ២ យ៉ាង គឺ :-

(១) **សន្តីរណកិច្ច** (២) **តទាលម្ពណកិច្ច**

-ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១ ដួង ធ្វើកិច្ច ២ យ៉ាង គឺ :-

(១) **អាវជ្ជនកិច្ច**(ក្នុងមនោទ្វារវិថី) (២) **វោដ្ឋវនកិច្ច**

៥. ចិត្តដែលអាចធ្វើនាទីបានតែ ១ កិច្ច មាន ៦៨ ដួង ឬ

១00 ដួង គឺ :-

+ឧបេក្ខាមនោធាតុអហេតុកកិរិយាចិត្ត ១ ដួង ធ្វើកិច្ច ១ យ៉ាង គឺ :

**-អាវជ្ជនកិច្ច** (ក្នុងបញ្ចទ្វារវិថី) ។

+ចក្ខុវិញ្ញាណចិត្ត ២ ដួង ធ្វើកិច្ច ១ គឺ :

**-ទស្សនកិច្ច** ។

+សោតវិញ្ញាណចិត្ត ២ ដួង ធ្វើកិច្ច ១ គឺ :

**-សវនកិច្ច** ។

+ឃានវិញ្ញាណចិត្ត ២ ដួង ធ្វើកិច្ច ១ គឺ :

**-ឃាយនកិច្ច** ។

+ជីវ្ហាវិញ្ញាណចិត្ត ២ ដួង ធ្វើកិច្ច ១ គឺ :

**-សាយនកិច្ច** ។

+កាយវិញ្ញាណចិត្ត ២ ដួង ធ្វើកិច្ច ១ គឺ :

**-ផុសនកិច្ច** ។

+ឧបេក្ខាមនោធាតុអហេតុកវិបាកចិត្ត ២ ដួងធ្វើកិច្ច ១ គឺ :

**-សម្បដិច្ឆន្នកិច្ច** ។

+អកុសលចិត្ត **១២**
+ហសិតុប្បាទចិត្ត **១**
+មហាកុសលចិត្ត **៨**
+មហាកិរិយាចិត្ត **៨**
+មហគ្គតកុសលចិត្ត **៩**
+មហគ្គតកិរិយាចិត្ត **៩**
+លោកុត្តរចិត្ត **៨** ឬ **៤០**

} ធ្វើកិច្ច ១ យ៉ាង គឺ **ជវនកិច្ច** ។

# សម្តែងការចែកចេតសិក ៥២ ដោយកិច្ច ១៤

**១.** ចេតសិកដែលធ្វើនាទីបាន **១** កិច្ច មាន **១៧** ដួង គឺ :-

-អកុសលចេតសិក **១៤**
-វិរតិចេតសិក **៣**

} ១៧ ដួងនេះ ធ្វើនាទី ១ យ៉ាង គឺ **ជវនកិច្ច**

# អធិប្បាយ

-អកុសលចេតសិក ១៤ ប្រកបបានតែជាមួយនឹងអកុសលចិត្ត **១២** ដួងប៉ុណ្ណោះ ហើយអកុសលចិត្ត **១២** ដួង នោះ ធ្វើនាទី សេពអារម្មណ៍ ជា **ជវនកិច្ច** តែម្យ៉ាង ។

-វិរតិចេតសិក **៣** ដួង ប្រកបបានតែជាមួយនឹងមហាកុសលចិត្ត **៨** ដួង និងលោកុត្តរចិត្ត **៨** ឬ **៤០** ដួង ហើយចិត្តទាំងនោះធ្វើនាទីសេពអារម្មណ៍ ជា **ជវនកិច្ច** តែម្យ៉ាងដូចគ្នា ។

**២.** ចេតសិកដែលធ្វើនាទីបាន **៤** កិច្ច មាន **២** ដួង គឺ :-

-អប្បមញ្ញាចេតសិក **២** ដួង ធ្វើនាទី **៤** យ៉ាង គឺ :-

(១) **បដិសន្ធិកិច្ច** (២) **ភវង្គកិច្ច**

(៣) **ចុតិកិច្ច** (៤) **ជវនកិច្ច**

# អធិប្បាយ

អប្បមញ្ញាចេតសិក **២** ដួងនេះ

-បើប្រកបជាមួយនឹងមហាកុសលចិត្ត **៨** ដួង មហាកិរិយាចិត្ត

**៨** ដួង រូបាវចរកុសលចិត្ត **៤** ដួង រូបាវចរកិរិយាចិត្ត **៤** ដួង ធ្វើនាទី **ជវនកិច្ច** តែម្យ៉ាង ។

-បើប្រកបជាមួយនឹងរូបាវចរវិបាកចិត្ត **៤** ដួង ធ្វើនាទី **៣** យ៉ាង គឺ **បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច** ។

រួមទាំងអស់ អប្បមញ្ញាចេតសិក **២** ដួង ធ្វើកិច្ចបាន **៤** កិច្ច ។

**៣.** ចេតសិកដែលអាចធ្វើនាទីបាន **៥** កិច្ច មាន **២១** ដួង គឺ :

-ឆន្ទចេតសិក **១** ដួង
-សោភណសាធារណចេតសិក **១៩** ដួង
-បញ្ញាចេតសិក **១** ដួង } ធ្វើនាទី **៥** យ៉ាង

គឺ :-

(១) **បដិសន្ធិកិច្ច** (២) **ភវង្គកិច្ច**
(៣) **ចុតិកិច្ច** (៤) **ជវនកិច្ច**
(៥) **តទាលម្ពណកិច្ច** ។

# អធិប្បាយ

ឆន្ទចេតសិក **១** ដួង សោភណសាធារណចេតសិក **១៩** ដួង

បញ្ញាចេតសិក **១** ដួង រួមជាចេតសិក **២១** ដួងនេះ មិនប្រកបក្នុងអហេតុកចិត្ត **១៨** ដួង ទើបវៀរកិច្ចដែលអហេតុកចិត្ត ធ្វើនាទី **៩** កិច្ច គឺ អាវជ្ជនកិច្ច ១ ទស្សនកិច្ច ១ សវនកិច្ច ១ ឃាយនកិច្ច ១ សាយនកិច្ច ១ ផុសនកិច្ច ១ សម្បដិច្ឆន្នកិច្ច ១ សន្តីរណកិច្ច ១ និង វោដ្ឋវនកិច្ច ១ ដែលកិច្ចទាំង **៩** នេះ ជានាទីរបស់អហេតុកចិត្តដោយចំពោះ ដូច្នេះទើបធ្វើនាទីបានត្រឹមតែ **៥** កិច្ចប៉ុណ្ណោះ ដូចបានពោលនោះឯង ។

**៤.** ចេតសិកដែលធ្វើនាទីបាន **៦** កិច្ច មាន **៦** ដួង គឺ :-

-បីតិចេតសិក **១** ដួង ធ្វើនាទី **៦** យ៉ាង គឺ :-

(១) **បដិសន្ធិកិច្ច** (២) **ភវង្គកិច្ច**

(៣) **ចុតិកិច្ច** (៤) **សន្តីរណកិច្ច**

(៥) **ជវនកិច្ច** (៦) **តទាលម្ពណកិច្ច**

# អធិប្បាយ

បីតិចេតសិកនេះ

-កាលបើប្រកបជាមួយនឹងសោមនស្សសហគតចិត្ត ដែលជាអកុសល កុសល កិរិយា និង ផលចិត្ត រមែងធ្វើនាទី **ជវនកិច្ច** ។

-កាលបើប្រកបជាមួយនឹងសោមនស្សមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ធ្វើនាទី **សន្តីរណកិច្ច** និង**តទាលម្ពណកិច្ច** ។

-បើប្រកបជាមួយនឹងសោមនស្សសហគតចិត្ត ដែលជារូបាវចរវិបាកចិត្ត **៣** ដួង ធ្វើនាទី **បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច** ។

-បើប្រកបជាមួយនឹងសោមនស្សសហគតចិត្ត ដែលជាមហាវិបាកចិត្ត ៤ ដួង ធ្វើនាទី **បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច** និង **តទាលម្ពណកិច្ច** ។

រួមទាំងអស់ បីតិចេតសិកធ្វើនាទីបាន **៦** កិច្ច គឺ **បដិ-សន្ធិកិច្ច ១ ភវង្គកិច្ច ១ ចុតិកិច្ច ១ សន្តីរណកិច្ច ១ ជវនកិច្ច ១** និង **តទាលម្ពណកិច្ច ១** ។

**៥.** ចេតសិកដែលធ្វើនាទីបាន **៧** កិច្ច មាន **១** ដួង គឺ :-

-វិរិយចេតសិក ធ្វើនាទី **៧** កិច្ច គឺ :-

(១) **បដិសន្ធិកិច្ច** (២) **ភវង្គកិច្ច**
(៣) **ចុតិកិច្ច** (៤) **អាវជ្ជនកិច្ច**
(៥) **វោដ្ឋវនកិច្ច** (៦) **ជវនកិច្ច**
(៧) **តទាលម្ពណកិច្ច** ។

# អធិប្បាយ

វិរិយចេតសិកនេះ

-ប្រកបជាមួយនឹងអកុសលចិត្ត កុសលចិត្ត កិរិយាចិត្ត និង ផលចិត្ត ធ្វើនាទី **ជវនកិច្ច** ។

-កាលប្រកបជាមួយនឹង មនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ធ្វើនាទី **អាវជ្ជនកិច្ច** និង **វោដ្ឋវនកិច្ច** ។

កាលប្រកបជាមួយនឹង មហាវិបាកចិត្ត ធ្វើនាទី បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច និង តទាលម្ពណកិច្ច ។

-កាលប្រកបជាមួយនឹងមហគ្គតវិបាកចិត្ត ធ្វើនាទី **បដិសន្ធិ-កិច្ច** **ភវង្គកិច្ច** និង **ចុតិកិច្ច** ។

រួមទាំងអស់ វិរិយចេតសិក ធ្វើនាទីបាន **៧** កិច្ច ដូចបាន ពោលហើយនោះ ។

៦. ចេតសិកដែលធ្វើនាទីបាន ៩ កិច្ច មាន ៣ ដួង គឺ :-

-វិតក្កចេតសិក
-វិចារចេតសិក
-អធិមោក្ខចេតសិក　} ធ្វើនាទី ៩ យ៉ាង គឺ :-

(១) **បដិសន្ធិកិច្ច**　(២) **ភវង្គកិច្ច**
(៣) **ចុតិកិច្ច**　(៤) **អាវជ្ជនកិច្ច**
(៥) **សម្បដិច្ឆន្នកិច្ច**　(៦) **សន្តីរណកិច្ច**
(៧) **វោដ្ឋវនកិច្ច**　(៨) **ជវនកិច្ច**
(៩) **តទាលម្ពណកិច្ច** ។

# អធិប្បាយ

វិតក្កចេតសិក វិចារចេតសិក អធិមោក្ខចេតសិក ៣ ដួង នេះ

-កាលប្រកបជាមួយនឹង អកុសលចិត្ត កុសលចិត្ត កិរិយាចិត្ត និងផលចិត្ត ធ្វើនាទី **ជវនកិច្ច** ។

-កាលប្រកបជាមួយនឹង ឧបេក្ខាមនោវិញ្ញាណធាតុអហេតុក-កិរិយាចិត្ត ធ្វើនាទី **អាវជ្ជនកិច្ច** និង **វោដ្ឋវនកិច្ច** ។

-កាលប្រកបជាមួយនឹង ឧបេក្ខាមនោធាតុអហេតុកវិបាកចិត្ត

ធ្វើនាទី **សម្បដិច្ឆន្នកិច្ច** ។

-កាលប្រកបជាមួយនឹង មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ធ្វើនាទី **សន្តីរណកិច្ច តទាលម្ពណកិច្ច បដិសន្ធិកិច្ច ភវង្គកិច្ច** និង **ចុតិកិច្ច** ។

-កាលប្រកបជាមួយនឹងមហាវិបាកចិត្ត ធ្វើនាទី **បដិសន្ធិ-កិច្ច ភវង្គកិច្ច ចុតិកិច្ច** និង **តទាលម្ពណកិច្ច** ។

-កាលប្រកបជាមួយនឹងមហគ្គតវិបាកចិត្ត ធ្វើនាទី **បដិសន្ធិ-កិច្ច ភវង្គកិច្ច** និង **ចុតិកិច្ច** ។

រួមទាំងអស់ ចេតសិកទាំង **៣** ដួងនេះ ធ្វើនាទីបាន **៩** កិច្ច ដូចបានពោលហើយនោះ ។

**៧.** ចេតសិកដែលធ្វើនាទីបាន **១៤** កិច្ច មាន **៧** ដួង គឺ :-

-សព្វចិត្តសាធារណចេតសិក **៧** ដួង ធ្វើនាទី **១៤** កិច្ច គឺ

(១) **បដិសន្ធិកិច្ច** (២) **ភវង្គកិច្ច**

(៣) **ចុតិកិច្ច** (៤) **អាវជ្ជនកិច្ច**

(៥) **ទស្សនកិច្ច** (៦) **សវនកិច្ច**

(៧) **ឃាយនកិច្ច** (៨) **សាយនកិច្ច**

(៩) **ផុសនកិច្ច** (១០) **សម្បដិច្ឆន្នកិច្ច**
(១១) **សន្តីរណកិច្ច** (១២) **វោដ្ឋវនកិច្ច**
(១៣) **ជវនកិច្ច** (១៤) **តទាលម្ពណកិច្ច**

# អធិប្បាយ

សព្វចិត្តសាធារណចេតសិក **៧** ដួង ប្រកបជាមួយនឹងចិត្ត បានទាំងអស់ ដូច្នេះទើបធ្វើនាទី **១៤** យ៉ាង បានទាំងអស់ ។

តទៅនេះ នឹងសម្តែង **ស្ថាន** គឺស្ថានទីកន្លែងធ្វើការងាររបស់ ចិត្ត និង ចេតសិក ដែលមានដោយសង្ខេប **១០** ស្ថាន ។

# ស្ថានទាំង ១០ នោះ គឺ :

**១. បដិសន្ធិស្ថាន** គឺ ស្ថានទីដែលចិត្តធ្វើការបន្តភពថ្មី ។
**២. ភវង្គស្ថាន** ស្ថានទីដែលចិត្តធ្វើការរក្សាអង្គនៃភព ។
**៣. អាវជ្ជនស្ថាន** គឺ ស្ថានទីដែលចិត្តធ្វើការទទួលរាវរក អារម្មណ៍ថ្មី ។

**៤. បញ្ចវិញ្ញាណស្ថាន** គឺស្ថានទីដែលចិត្ត ធ្វើការ ឃើញ ឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ ។

**៥. សម្បដិច្ឆន្នស្ថាន** គឺស្ថានទីដែលចិត្ត ធ្វើការទទួលនូវបញ្ចារម្មណ៍ ។

**៦. សន្តីរណស្ថាន** គឺ ស្ថានទីដែលចិត្ត ធ្វើការពិចារណាបញ្ចារម្មណ៍ ។

**៧. វោដ្ឋវនស្ថាន** គឺស្ថានទីដែលចិត្ត ធ្វើការកាត់សម្រេចសេចក្តីក្នុងបញ្ចារម្មណ៍ ។

**៨. ជវនស្ថាន** ស្ថានទីដែលចិត្តធ្វើការសេពអារម្មណ៍ ។

**៩. តទាលម្ពណស្ថាន** គឺ ស្ថានទីដែលចិត្ត ធ្វើការទទួលនូវអារម្មណ៍ ដែលសល់ពីជវនៈ ។

**១០. ចុតិស្ថាន** គឺស្ថានទីដែលចិត្ត ធ្វើការរលត់អស់ចាកភព ។

# សម្តែងការចែកស្ថាន ១០ ដោយចិត្ត

**១. បដិសន្ធិស្ថាន** ជាស្ថានទីធ្វើការងារបន្តភពថ្មី របស់ចិត្ត ១៩ ដួង គឺ :-

-ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត　២ ដួង ។
-មហាវិបាកចិត្ត　៨ ដួង ។
-មហគ្គតវិបាកចិត្ត　៩ ដួង ។

២. **ភវង្គស្ថាន** ជាស្ថានទីធ្វើការងាររក្សាអង្គនៃភព របស់ចិត្ត ១៩ ដួង គឺ :-

-ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត　២ ដួង ។
-មហាវិបាកចិត្ត　៨ ដួង ។
-មហគ្គតវិបាកចិត្ត　៩ ដួង ។

៣. **អាវជ្ជនស្ថាន** ជាស្ថានទីធ្វើការងារទទួលរាវរកអារម្មណ៍ របស់ចិត្ត ២ ដួង គឺ :-

-ឧបេក្ខាមនោធាតុអហេតុកកិរិយាចិត្ត　១ ដួង ។
-ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត　១ ដួង ។

៤. **បញ្ចវិញ្ញាណស្ថាន** ជាស្ថានទីធ្វើការងារ ឃើញ ឮ ដឹងក្លិន ដឹងរស ដឹងផោដ្ឋព្វៈ របស់ចិត្ត ១០ ដួង គឺ :-

- ទ្វិបញ្ចវិញ្ញាណចិត្ត　១០ ដួង

**៥. សម្បដិច្ឆន្នស្ថាន** ជាស្ថានទីធ្វើការងារទទួលអារម្មណ៍ របស់ចិត្ត **២** ដួង គឺ :-

-ឧបេក្ខាមនោធាតុអហេតុកវិបាកចិត្ត **២** ដួង

**៦. សន្តីរណស្ថាន** ជាស្ថានទីធ្វើការងារពិចារណា បញ្ចារម្មណ៍ របស់ចិត្ត **៣** ដួង គឺ :-

-មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត **៣** ដួង

**៧. វោដ្ឋវនស្ថាន** ជាស្ថានទីធ្វើការងារកាត់សម្រេចសេចក្តី ក្នុងបញ្ចារម្មណ៍ របស់ចិត្ត **១** ដួង គឺ :-

-ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត **១** ដួង

**៨. ជវនស្ថាន** គឺ ស្ថានទីធ្វើការងារសេពនូវអារម្មណ៍ របស់ចិត្ត **៥៥** ដួង គឺ :-

-អកុសលចិត្ត **១២** ដួង

-ហសិតុប្បាទចិត្ត **១** ដួង

-មហាកុសលចិត្ត **៨** ដួង

-មហាកិរិយាចិត្ត **៨** ដួង

-មហគ្គតកុសលចិត្ត ៩ ដួង

-មហគ្គតកិរិយាចិត្ត ៩ ដួង

-លោកុត្តរចិត្ត ៨ ដួង

៩. **តទាលម្ពណស្ថាន** ជាស្ថានទីធ្វើការងារទទួលអារម្មណ៍ ដែលសល់ពីជវនៈ របស់ចិត្ត ១១ ដួង គឺ :-

-មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ៣ ដួង

-មហាវិបាកចិត្ត ៨ ដួង

១០. **ចុតិស្ថាន** ជាស្ថានទីធ្វើការងាររលត់អស់ចាកភព របស់ចិត្ត ១៩ ដួង គឺ :-

-ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ២ ដួង

-មហាវិបាកចិត្ត ៨ ដួង

-មហគ្គតវិបាកចិត្ត ៩ ដួង

# សម្តែងការចែកចិត្តដោយកិច្ច និងស្ថាន

## គាថាសង្គហៈ

៨. អដ្ឋសដ្ឋី តថា ទ្វេ ច នវដ្ឋ ទ្វេ យថាក្កមំ
ឯក ទ្វិតិ ចតុ បញ្ច កិច្ចដ្ឋានានិ និទ្ទិសេ

ប្រែថា សម្តែងចំនួនចិត្តដោយ កិច្ច និង ស្ថាន តាមលំដាប់ មានយ៉ាងនេះ គឺ :-

- ចិត្តមានកិច្ច ១ និងស្ថាន ១ មានចំនួន ៦៨ ដួង
- ចិត្តមានកិច្ច ២ និងស្ថាន ២ មានចំនួន ២ ដួង
- ចិត្តមានកិច្ច ៣ និងស្ថាន ៣ មានចំនួន ៩ ដួង
- ចិត្តមានកិច្ច ៤ និងស្ថាន ៤ មានចំនួន ៨ ដួង
- ចិត្តមានកិច្ច ៥ និងស្ថាន ៥ មានចំនួន ២ ដួង

## អធិប្បាយ

ចិត្តដែលធ្វើនាទី ១ យ៉ាង ត្រង់ស្ថាន ១ ស្ថាន មាន ចំនួន ៦៨ ដួង គឺ :-

-ចក្ខុវិញ្ញាណចិត្ត ២ ធ្វើនាទីទស្សនកិច្ច ត្រង់បញ្ចវិញ្ញាណស្ថាន
-សោតវិញ្ញាណចិត្ត ២ ធ្វើនាទីសវនកិច្ច ត្រង់បញ្ចវិញ្ញាណស្ថាន
-ឃានវិញ្ញាណចិត្ត ២ ធ្វើនាទីឃាយនកិច្ច ត្រង់បញ្ចវិញ្ញាណស្ថាន
-ជីវ្ហាវិញ្ញាណចិត្ត ២ ធ្វើនាទីសាយនកិច្ច ត្រង់បញ្ចវិញ្ញាណស្ថាន
-កាយវិញ្ញាណចិត្ត ២ ធ្វើនាទីផុសនកិច្ច ត្រង់បញ្ចវិញ្ញាណស្ថាន
-ឧបេក្ខាមនោធាតុអហេតុកកិរិយា ជាបញ្ចទ្វារាវជ្ជនចិត្ត ១
ធ្វើនាទីអាវជ្ជនកិច្ច ត្រង់អាវជ្ជនស្ថាន
-ឧបេក្ខាមនោធាតុអហេតុកវិបាក ជាសម្បដិច្ឆន្នចិត្ត ២
ធ្វើនាទីសម្បដិច្ឆន្នកិច្ច ត្រង់សម្បដិច្ឆន្នស្ថាន

-អកុសលចិត្ត ១២
-ហសិតុប្បាទចិត្ត ១
-មហាកុសលចិត្ត ៨
-មហាកិរិយាចិត្ត ៨
-មហគ្គតកុសលចិត្ត ៩
-មហគ្គតកិរិយាចិត្ត ៩
-លោកុត្តរចិត្ត ៨

} ជាជវនចិត្ត ៥៥ ធ្វើនាទីជវនកិច្ច ត្រង់ជវនស្ថាន

**ចិត្តដែលធ្វើនាទី ២ យ៉ាង ត្រង់ស្ថាន ២ ស្ថាន មានចំនួន ២ ដួង គឺ :-**

-សោមនស្សមនោវិញ្ញាណធាតុអហេតុកវិបាក ជាសោមនស្សសន្តីរណចិត្ត ១

ធ្វើនាទី សន្តីរណកិច្ច ត្រង់សន្តីរណស្ថាន

ធ្វើនាទី តទាលម្ពណកិច្ច ត្រង់តទាលម្ពណស្ថាន

-ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយា ជាមនោទ្វារាវជ្ជនចិត្ត ១

ធ្វើនាទី អាវជ្ជនកិច្ច ត្រង់អាវជ្ជនស្ថាន

ធ្វើនាទី វោដ្ឋវនកិច្ច ត្រង់វោដ្ឋវនស្ថាន

**ចិត្តដែលធ្វើនាទី ៣ យ៉ាង ត្រង់ស្ថាន ៣ ស្ថាន មានចំនួន ៩ ដួង គឺ :-**

-មហគ្គតវិបាកចិត្ត ៩

ធ្វើនាទី បដិសន្ធិកិច្ច ត្រង់បដិសន្ធិស្ថាន

ធ្វើនាទី ភវង្គកិច្ច ត្រង់ភវង្គស្ថាន

ធ្វើនាទី ចុតិកិច្ច ត្រង់ចុតិស្ថាន

**ចិត្តដែលធ្វើនាទី ៤ យ៉ាង ត្រង់ស្ថាន ៤ ស្ថាន មានចំនួន ៨ ដួង គឺ :-**

- មហាវិបាកចិត្ត **៨**

ធ្វើនាទី បដិសន្ធិកិច្ច ត្រង់បដិសន្ធិស្ថាន
ធ្វើនាទី ភវង្គកិច្ច ត្រង់ភវង្គស្ថាន
ធ្វើនាទី ចុតិកិច្ច ត្រង់ចុតិស្ថាន
ធ្វើនាទី តទាលម្ពណកិច្ច ត្រង់តទាលម្ពណស្ថាន

**ចិត្តដែលធ្វើនាទី ៥ យ៉ាង ត្រង់ស្ថាន ៥ ស្ថាន មានចំនួន ២ ដួង គឺ :-**

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាក ជាឧបេក្ខាសន្តីរណចិត្ត **២** ដួង

ធ្វើនាទី បដិសន្ធិកិច្ច ត្រង់បដិសន្ធិស្ថាន
ធ្វើនាទី ភវង្គកិច្ច ត្រង់ភវង្គស្ថាន
ធ្វើនាទី ចុតិកិច្ច ត្រង់ចុតិស្ថាន
ធ្វើនាទី សន្តីរណកិច្ច ត្រង់សន្តីរណស្ថាន
ធ្វើនាទី តទាលម្ពណកិច្ច ត្រង់តទាលម្ពណស្ថាន

# សម្តែងស្ថានដោយពិស្តារ
# មាន ២៥ ស្ថាន

**សន្ធិឯកំ ឆភវង្គំ　　　ទ្វារជួនំ បញ្ចាឡេកំ**
**ទ្វេវោជោឆ តទាទ្វេតិ　　ចុតីតិ បញ្ចវីសតិ ។**

ប្រែថា បដិសន្ធិស្ថានមាន ១ ភវង្គស្ថានមាន ៦ អាវជ្ជនស្ថានមាន ២ បញ្ចវិញ្ញាណស្ថានមាន ១ សម្បដិច្ឆន្នស្ថានមាន ១ សន្តីរណស្ថានមាន ១ វោដ្ឋវនស្ថានមាន ២ ជវនស្ថានមាន ៦ តទាលម្ពណស្ថានមាន ២ ចុតិស្ថានមាន ៣ ។

រួមទាំងអស់ មាន ២៥ ស្ថាន ។

ការសម្តែងស្ថានដោយពិស្តារ ២៥ ស្ថាននេះ ជាការសម្តែងតាមន័យនៃវិថីចិត្ត ដោយត្រង់សភាពនៃចិត្តនិងចេតសិក នោះ ជានាមធម៌ដែលមានការកើត ការរលត់ជាប់បន្តគ្នាជាខ្សែ ដូចជាក្រសែនៃទឹក ។

ចិត្តមួយដួងដែលប្រាកដឡើង ដើម្បីធ្វើកិច្ចយ៉ាងណាមួយ គប្បី

ជ្រាបថា ចិត្តនោះ ធ្វើកិច្ចការងារត្រង់ស្ថាននោះៗ ដែលឈ្មោះរបស់ **កិច្ច** និង ឈ្មោះរបស់ **ស្ថាន** ច្រើនតែជាឈ្មោះដូចៗគ្នា វៀរតែ ទស្សនកិច្ច សវនកិច្ច ឃាយនកិច្ច សាយនកិច្ច ផុសនកិច្ច ស្ថាន ដែលធ្វើកិច្ចទាំង **៥** នេះ រួមមកហៅថា **បញ្ចវិញ្ញាណស្ថាន** ។ ក្រៅអំពីស្ថានរបស់កិច្ចទាំង **៥** នេះហើយ **កិច្ច** មានឈ្មោះយ៉ាងណា **ស្ថាន** ក៏មានឈ្មោះយ៉ាងនោះដែរ ប៉ុន្តែកាលណានឹងសម្តែង ស្ថានទីរបស់ចិត្តដែលប្រាកដឡើង ដើម្បីធ្វើកិច្ចនាទីដោយត្រង់ហើយ តែងមានការលំបាកនឹងចង្អុលបង្ហាញចំពោះស្ថានដែលកើត របស់ចិត្ត ដោយត្រង់ ។ ទាំងនេះ ព្រោះចិត្តជានាមធម៌ដែលមានការប្រាកដ ឡើង ដោយការបន្តជាប់គ្នាជាអនន្តរប្បច្ច័យ ងាយស្រួលជាទីបំផុត ដែលអាចចង្អុលបង្ហាញនូវស្ថានរបស់ចិត្តបាន គឺមានតែប្រាប់ថា នៅ ក្នុងរវាងក្នុងចន្លោះនៃចិត្ត ដួងមួយនិងចិត្តដួងមួយទៀត ក្នុងវិថីចិត្ត ប៉ុណ្ណោះ ។

ដូច្នេះ កាលណានឹងសម្តែងស្ថានរបស់ចិត្តដោយពិស្តារហើយ ចាំបាច់ត្រូវអាស្រ័យវិថីចិត្តជាគោលតែម្យ៉ាង ៕

# សម្តែងការចែកស្ថាន ២៥ ដោយន័យនៃវិថីចិត្ត

គប្បីជ្រាបថា ស្ថាន **២៥** ដោយពិស្តារ កាលណាចែកដោយវិថីចិត្តហើយ មានយ៉ាងនេះ គឺ :

**១. បដិសន្ធិស្ថាន** មាន **១** ស្ថាន គឺ :

-រវាង **ចុតិចិត្ត** និង **ភវង្គចិត្ត** ដែលកើតបន្តមកពីមរណាសន្នវិថី ។

**២. ភវង្គស្ថាន** មាន **៦** ស្ថាន គឺ :

១- រវាង **បដិសន្ធិចិត្ត** និង **អាវជ្ជនចិត្ត** ដែលកើតបន្តមកពីមរណាសន្នវិថីរហូតដល់ភវនិកន្តលោភជវនវិថី ។

២- រវាង **តទាលម្ពណចិត្ត** និង **អាវជ្ជនចិត្ត** ក្នុងរវាងតទាលម្ពណវារៈវិថី និងវិថីដទៃៗ ដែលកើតបន្តជាប់គ្នា។

៣- រវាង **ជវនចិត្ត** និង **អាវជ្ជនចិត្ត** ក្នុងរវាងជវនវារៈវិថី និង វិថីដទៃៗ ដែលកើតបន្តជាប់គ្នា ។

៤- រវាង **វោដ្ឋវនចិត្ត** និង **អាវជ្ជនចិត្ត** ក្នុងរវាងបញ្ច-

ទ្វារវិថី ដែលជាវោដ្ឋវនវារៈនិងវិថីចិត្តដទៃៗ ដែលកើតបន្តជាប់គ្នា ។

៥- រវាង **តទាលម្ពណចិត្ត** និង **ចុតិចិត្ត** ក្នុងមរណាសន្នវិថី ដែលជាតទាលម្ពណវារៈ ។

៦- រវាង **ជវនចិត្ត** និង **ចុតិចិត្ត** ក្នុងមរណាសន្នវិថី ដែលជាជវនវារៈ ។

**៣. អាវជ្ជនស្ថាន** មាន **២** ស្ថាន គឺ :

១- រវាង **ភវង្គចិត្ត** និង **បញ្ចវិញ្ញាណចិត្ត** ក្នុងបញ្ចទ្វារវិថី ។

២- រវាង **ភវង្គចិត្ត** និង **ជវនចិត្ត** ក្នុងមនោទ្វារវិថី ។

**៤. បញ្ចវិញ្ញាណស្ថាន** មាន ១ ស្ថាន គឺ :

- រវាង **បញ្ចទ្វារាវជ្ជនចិត្ត** និង **សម្បដិច្ឆន្នចិត្ត** ក្នុងបញ្ចទ្វារវិថី ។

**៥. សម្បដិច្ឆន្នស្ថាន** មាន ១ ស្ថាន គឺ :

- រវាង **បញ្ចវិញ្ញាណចិត្ត** និង **សន្តីរណចិត្ត** ក្នុងបញ្ចទ្វារវិថី ។

**៦. សន្តីរណស្ថាន** មាន ១ ស្ថាន គឺ :

- រវាង **សម្បដិច្ឆន្នចិត្ត** និង **វោដ្ឋវនចិត្ត** ក្នុងបញ្ចទ្វារវិថី ។

**៧. វោដ្ឋវនស្ថាន** មាន **២** ស្ថាន គឺ :

១- រវាង **សន្តីរណចិត្ត** និង **ជវនចិត្ត** ក្នុងបញ្ចទ្វារវិថី ដែលជា តទាលម្ពណវារៈ និង ជវនវារៈ ។

២- រវាង **សន្តីរណចិត្ត** និង **ភវង្គចិត្ត** ក្នុងបញ្ចទ្វារវិថី ដែលជា វោដ្ឋវនវារៈ ។

**៨. ជវនស្ថាន** មាន **៦** ស្ថាន គឺ :

១- រវាង **វោដ្ឋវនចិត្ត** និង **តទាលម្ពណចិត្ត** ក្នុងបញ្ចទ្វារវិថី ដែលជា តទាលម្ពណវារៈ ។

២- រវាង **វោដ្ឋវនចិត្ត** និង **ភវង្គចិត្ត** ក្នុងបញ្ចទ្វារវិថី ដែលជា ជវនវារៈ ។

៣- រវាង **វោដ្ឋវនចិត្ត** និង **ចុតិចិត្ត** ក្នុងបញ្ចទ្វារមរណាសន្នវិថី ដែលជា ជវនវារៈ ។

៤- រវាង **មនោទ្វារាវជ្ជនចិត្ត** និង **តទាលម្ពណចិត្ត** ក្នុងកាមជវនមនោទ្វារវិថី ដែលជា តទាលម្ពណវារៈ ។

៥- រវាង **មនោទ្វារាវជ្ជនចិត្ត** និង **ភវង្គចិត្ត** ក្នុង

មនោទ្វារវិថី ដែលជាជវនវារៈ ។

៦- រវាង **មនោទ្វារាវជ្ជនចិត្ត** និង **ចុតិចិត្ត** ក្នុង មនោទ្វារមរណាសន្នវិថី ដែលជាជវនវារៈ ។

**៩. តទាលម្ពណស្ថាន** មាន **២** ស្ថាន គឺ :

១- រវាង **ជវនចិត្ត** និង **ភវង្គចិត្ត** ក្នុងបញ្ចទ្វារវិថី និង មនោទ្វារវិថី ដែលជាតទាលម្ពណវារៈ ។

២- រវាង **ជវនចិត្ត** និង **ចុតិចិត្ត** ក្នុងមរណាសន្នវិថី ដែលជាតទាលម្ពណវារៈ ។

**១០. ចុតិស្ថាន** មាន **៣** ស្ថាន គឺ :

១- រវាង **ជវនចិត្ត** និង **បដិសន្ធិចិត្ត** ក្នុងមរណាសន្នវិថី ដែលជាជវនវារៈ ។

២- រវាង **តទាលម្ពណចិត្ត** និង **បដិសន្ធិចិត្ត** ក្នុង មរណាសន្នវិថី ដែលជាតទាលម្ពណវារៈ ។

៣- រវាង **ភវង្គចិត្ត** និង **បដិសន្ធិចិត្ត** ក្នុងមរណាសន្នវិថី។

( ចប់ កិច្ចសង្គហៈ )

----------●----------

# ទ្វារសង្គហៈ

ការសង្គ្រោះនូវចិត្ត និងចេតសិកដោយប្រភេទនៃទ្វារ ឈ្មោះថា **ទ្វារសង្គហៈ** ។

ពាក្យថា **ទ្វារ** ប្រែថា ច្រកសម្រាប់ចេញចូលនៃជនទាំងឡាយ ដើម្បីធ្វើកិច្ចការងារផ្សេងៗ ។ ឯចំពោះចិត្ត និងចេតសិក ដែលនឹងអាចធ្វើកិច្ចការងារដឹងអារម្មណ៍ផ្សេងៗបាននោះ ក៏ត្រូវអាស្រ័យច្រក គឺ ទ្វារដូចគ្នា មានចក្ខុបសាទជាដើម ឈ្មោះថា **ទ្វារ** ព្រោះដូចជាច្រកដែលជាទីចេញចូលរបស់វិថីចិត្តទាំងឡាយ ឲ្យកើតកិច្ចឃើញអារម្មណ៍បាន ។ ប្រសិនបើ មិនមានចក្ខុបសាទ គឺ ចក្ខុទ្វារហើយ អាចឃើញអារម្មណ៍ណាៗនោះក៏មិនបាន ។ ធម្មតា សត្វទាំងឡាយ បើមិនមានបសាទរូបទាំង **៥** និងភវង្គចិត្តហើយ វិថីចិត្តក៏កើតឡើងមិនបាន កាលណាវិថីចិត្តកើតឡើងមិនបាន **កម្ម** គឺ ការធ្វើ ការនិយាយ ការនឹកគិតល្អក្តី មិនល្អក្តី រមែងមិនអាចកើតឡើងបានឡើយ សត្វទាំងឡាយក៏នឹងមិនខុសអ្វីនឹងរុក្ខជាតិ ឬ វត្ថុនានាដូច្នោះដែរ ។

ទ្វារដែលចិត្ត និងចេតសិក ដឹងអារម្មណ៍ផ្សេងៗបាននោះ មាន **៦** ទ្វារ គឺ :-

# ទ្វារ

| | | |
|---|---|---|
| **១. ចក្ខុទ្វារ** | អង្គធម៌បានដល់ | ចក្ខុបសាទ |
| **២. សោតទ្វារ** | ” ” | សោតបសាទ |
| **៣. ឃានទ្វារ** | ” ” | ឃានបសាទ |
| **៤. ជិវ្ហាទ្វារ** | ” ” | ជិវ្ហាបសាទ |
| **៥. កាយទ្វារ** | ” ” | កាយបសាទ |
| **៦. មនោទ្វារ** | ” ” | ភវង្គចិត្ត **១៩** |

កាលទ្វារចេញ-ចូលរបស់ចិត្ត-ចេតសិក មានច្រើនយ៉ាងនេះ ទើបព្រះអនុរុទ្ធាចារ្យ បានចាត់លំដាប់នៃចិត្ត-ចេតសិក ដែលកើតឡើងក្នុងទ្វារនីមួយៗទុក ដូចមានគាថាតទៅនេះ :

# គាថាសង្គហៈ

**៩. ឯកទ្វារិកចិត្តានិ បញ្ចឆទ្វារិកានិ ច**
**ឆទ្វារិកវិមុត្តានិ វិមុត្តានិ ច សព្វថា**

ប្រែថា ចិត្តអាស្រ័យកើតឡើងបានតែក្នុងទ្វារ ១ ក៏មាន

អាស្រ័យកើតឡើងបានក្នុងទ្វារ **៥** ក៏មាន អាស្រ័យកើតឡើងបានក្នុងទ្វារទាំង **៦** ក៏មាន កើតឡើងបានជួនកាលអាស្រ័យទ្វារទាំង **៦** ជួនកាលក៏មិនអាស្រ័យទ្វារក៏មាន ហើយនិងចិត្តខ្លះ ក៏កើតឡើងដោយផុតចាកទ្វារទាំង **៦** តែម្តងក៏មាន ។

# អធិប្បាយ

ការកើតឡើងនៃចិត្ត ចេតសិក ទាំងអាស្រ័យទ្វារ និងទាំងមិនអាស្រ័យទ្វារ ក្នុងគាថាសង្គហៈទី **៩** នេះ មាន **៥** ប្រការ គឺ :-

**១-ឯកទ្វារិកចិត្ត** គឺ ចិត្ត-ចេតសិក ដែលអាស្រ័យកើតបានក្នុងទ្វារតែ **១** ។

**២-បញ្ចទ្វារិកចិត្ត** គឺ ចិត្ត-ចេតសិក ដែលអាស្រ័យកើតបានក្នុងទ្វារ **៥** ។

**៣-ឆទ្វារិកចិត្ត** គឺ ចិត្ត-ចេតសិក ដែលអាស្រ័យកើតបានក្នុងទ្វារទាំង **៦** ។

**៤-ឆទ្វារិកវិមុត្តចិត្ត** គឺ ចិត្ត-ចេតសិក ដែលអាស្រ័យកើតបានជួនកាលអាស្រ័យទ្វារទាំង **៦** ជួនកាល

មិនអាស្រ័យទ្វារ ។

**៥.ទ្វារវិមុត្តចិត្ត** គឺ ចិត្ត-ចេតសិក ដែលកើតឡើង ដោយ មិនបាច់អាស្រ័យទ្វារណាៗនោះឡើយ ។

ចិត្តដែលអាស្រ័យកើតឡើងតាមទ្វារផ្សេងៗទាំង **៦** នោះ បើកើតតាមបញ្ចទ្វារ គឺអាស្រ័យកើតតាមផ្លូវ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ទ្វារនោះ ។ អង្គធម៌បានដល់ បសាទរូប **៥** ជា **រូបទ្វារ** ដែលជាផ្លូវឲ្យទ្វិបញ្ចវិញ្ញាណចិត្តកើតឡើងទទួលដឹងបញ្ចារម្មណ៍ ដែលបានដល់ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈផង និង ជាហេតុឲ្យវិថីចិត្តកើតឡើងតាមបញ្ចទ្វារវិថីទៀតផង ។

ចំណែកឯចិត្តដែលកើតឡើងតាមមនោទ្វារនោះ ជា **នាមទ្វារ** បានដល់ ភវង្គចិត្ត ដែលជាផ្លូវឲ្យមនោវិញ្ញាណធាតុកើតឡើង ទទួលដឹងអារម្មណ៍ទាំង **៦** ផង និង ជាហេតុឲ្យវិថីចិត្តកើតឡើងតាមមនោទ្វារវិថីផង ។

ក្នុងគាថាសង្គហៈ ទី **៩** នេះ គ្រាន់តែសម្តែងអំពីចិត្តចេតសិកដែលកើតឡើងដោយអាស្រ័យរូបទ្វារ **៥** ទ្វារ នាមទ្វារ **១** ទ្វារ ប៉ុណ្ណោះ ។ ឯការសម្តែងដល់ចំនួនរបស់ចិត្ត ដែលអាស្រ័យកើតឡើងតាមទ្វារណាៗមួយនោះ មានក្នុងគាថាសង្គហៈដូចតទៅនេះ :

# គាថាសង្គហៈ

**១០. ឆត្តឹសតិ តថាតិណិ ឯកត្តឹស យថាក្កមំ**
**ទសធានវធាចេតិ បញ្ចធា បរិទីបយេ**

ប្រែថា កាលកំណត់នូវចំនួនចិត្តទាំង **៥** ប្រភេទ នោះតាមលំដាប់ មានដូចតទៅ គឺ **៣៦-៣-៣១-១០-៩** ។

# អធិប្បាយ

គាថាសង្គហៈទី ១០ នេះ សម្តែងអំពីចំនួនចិត្ត ដែលអាស្រ័យកើតឡើងតាមទ្វារផ្សេងៗ **៥** ប្រភេទ ដូចដែលសម្តែងទុកក្នុងគាថាសង្គហៈ ទី **៩** មានចំនួនយ៉ាងនេះ គឺ :

**១. ឯកទ្វារិកចិត្ត** ចិត្តដែលអាស្រ័យកើតឡើងបានទ្វារ តែ **១** មាន **៣៦** ឬ **៦៨** ដួង គឺ :

- ទ្វិបញ្ចវិញ្ញាណចិត្ត **១០**
- អប្បនាជវនចិត្ត **២៦** ឬ **៥៨**

**២. បញ្ចទ្វារិកចិត្ត** ចិត្តដែលអាស្រ័យកើតឡើងតាមបញ្ចទ្វារមាន

៣ ដួង គឺ :

- ឧបេក្ខាមនោធាតុអហេតុកកិរិយាចិត្ត ១
- ឧបេក្ខាមនោធាតុអហេតុកវិបាកចិត្ត ២ ឬមនោធាតុ ៣

**៣. ឆទ្វារិកចិត្ត** ចិត្តដែលអាស្រ័យកើតឡើងបានទាំង ៦ ទ្វារ មាន ៣១ ដួង គឺ :

- សោមនស្សមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ១
- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
- កាមជវនចិត្ត ២៩

**៤.ឆទ្វារិកវិមុត្តចិត្ត** ចិត្តដែលកើតឡើង ជួនកាលអាស្រ័យទ្វារទាំង ៦ ជួនកាលមិនអាស្រ័យទ្វារ មាន ១០ ដួង គឺ :

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ២
- មហាវិបាកចិត្ត ៨

ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ២ ដួង កាលធ្វើនាទីសន្តីរណកិច្ច និង តទាលម្ពណកិច្ច និង មហាវិបាកចិត្ត ៨ ដួង ធ្វើនាទីតទាលម្ពណកិច្ច ចិត្ត ១០ ដួង នេះ ត្រូវអាស្រ័យទ្វារ

ប៉ុន្តែ បើធ្វើនាទី បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច ណាមួយ មិនបាន អាស្រ័យទ្វារឡើយ ។

**៥. ទ្វារវិមុត្តចិត្ត** ចិត្តដែលកើតឡើងផុតចាកទ្វារទាំង **៦** ដោយ មិនអាស្រ័យទ្វារណាមួយ មាន **៩** ដួង គឺ :

- មហគ្គតវិបាកចិត្ត **៩**

ការសម្តែងចំនួនចិត្ត ដែលអាស្រ័យទ្វារកើត និង មិនបាច់អាស្រ័យទ្វារកើត នេះជាការសម្តែងនូវការប្រាកដ(ឯកន្តៈ) តែម្យ៉ាង ប៉ុន្តែបើនឹងសម្តែងរាយល្អិតនៃចំនួនចិត្ត ដែលកើតឡើងតាមទ្វារនីមួយៗ ទាំងកើតឡើងប្រាកដ(ឯកន្តៈ) និង កើតឡើងមិនប្រាកដ (អនេកន្តៈ) នោះ រមែងសម្តែងយ៉ាងនេះ គឺ :

# សម្តែងទ្វារិកចិត្ត និង ទ្វារវិមុត្តចិត្ត ដោយឯកន្តៈ និង អនេកន្តៈ

## ១. ឯកទ្វារិកចិត្ត មានចំនួន ៨០ ដួង

**+ ឯកន្តៈ** មាន **៣៦** ដួង បានដល់ :

- ទ្វិបញ្ចវិញ្ញាណ **១០**

- អប្បនាជវនចិត្ត ២៦

+ **អនេកន្តៈ** មាន **៤៤** ដួង បានដល់ :

- មនោធាតុ ៣
- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
- កាមជវនចិត្ត ២៩
- តទាលម្ពណចិត្ត ១១

ការសម្តែងចំនួនឯកទ្វារិកចិត្តនេះ ជាការសម្តែងរួមទាំង **៦** ទ្វារ ប៉ុន្តែបើរាប់ចំពោះចិត្តតាមទ្វារនីមួយៗដោយពិស្តារ ក៏អាចចែកចេញ បានទៀត គឺ :

## ក. ចក្ខុទ្វារិកចិត្ត មាន ៤៦ ដួង

+ **ឯកន្តៈ** មាន **២** ដួង បានដល់ :

- ចក្ខុវិញ្ញាណចិត្ត ២

+ **អនេកន្តៈ** មាន **៤៤** ដួង បានដល់ :

- មនោធាតុ ៣
- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
- កាមជវនចិត្ត ២៩

- តទាលម្ពណចិត្ត ១១

## ខ. សោតទ្វារិកចិត្ត មាន ៤៦ ដួង

+ **ឯកន្តៈ** មាន ២ ដួង បានដល់ :
  - សោតវិញ្ញាណចិត្ត ២
+ **អនេកន្តៈ** មាន ៤៤ ដួង បានដល់ :
  - មនោធាតុ ៣
  - ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
  - កាមជវនចិត្ត ២៩
  - តទាលម្ពណចិត្ត ១១

## គ. ឃានទ្វារិកចិត្ត មាន ៤៦ ដួង

+ **ឯកន្តៈ** មាន ២ ដួង បានដល់ :
  - ឃានវិញ្ញាណចិត្ត ២
+ **អនេកន្តៈ** មាន ៤៤ ដួង បានដល់ :
  - មនោធាតុ ៣
  - ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
  - កាមជវនចិត្ត ២៩

- តទាលម្ពណចិត្ត ១១

## ឃ. ជីវ្ហាទ្វារិកចិត្ត មាន ៤៦ ដួង

+ **ឯកន្តៈ** មាន **២** ដួង បានដល់ :
  - ជីវ្ហាវិញ្ញាណចិត្ត ២
+ **អនេកន្តៈ** មាន **៤៤** ដួង បានដល់ :
  - មនោធាតុ ៣
  - ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
  - កាមជវនចិត្ត ២៩
  - តទាលម្ពណចិត្ត ១១

## ង. កាយទ្វារិកចិត្ត មាន ៤៦ ដួង

+ **ឯកន្តៈ** មាន **២** ដួង បានដល់ :
  - កាយវិញ្ញាណចិត្ត ២
+ **អនេកន្តៈ** មាន **៤៤** ដួង បានដល់ :
  - មនោធាតុ ៣
  - ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
  - កាមជវនចិត្ត ២៩

- គោចរសញ្ញាណចិត្ត ១១

## ២. មនោទ្វារិកចិត្ត មាន ៦៧ ដួង

+ **ឯកន្តៈ** មាន **២៦** ដួង បានដល់ :

- អប្បនាជវនចិត្ត

+ **អនេកន្តៈ** មាន ៤១ ដួង បានដល់ :

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
- កាមជវនចិត្ត ២៩
- គោចរសញ្ញាណចិត្ត ១១

## ២. បញ្ចទ្វារិកចិត្ត មាន ៤៤ ដួង

+ **ឯកន្តៈ** មាន ៣ ដួង បានដល់ :

- មនោធាតុ ៣

+ **អនេកន្តៈ** មាន ៤១ ដួង បានដល់ :

- ឧបេក្ខាមនោធាតុអហេតុកកិរិយាចិត្ត ១
- កាមជវនចិត្ត ២៩
- គោចរសញ្ញាណចិត្ត ១១

## ៣. ឆទ្វារិកចិត្ត មាន ៤១ ដួង

+ **ឯកន្តៈ** មាន **៣១** ដួង បានដល់ :

- សោមនស្សមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ១
- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
- កាមជវនចិត្ត ២៩

+ **អនេកន្តៈ** មាន **១០** ដួង បានដល់ :

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ២
- មហាវិបាកចិត្ត ៨

### ៤. ទ្វារវិមុត្តចិត្ត មាន ១៩ ដួង

+ **ឯកន្តៈ** មាន **៩** ដួង បានដល់ :

- មហគ្គតវិបាកចិត្ត ៩

+ **អនេកន្តៈ** មាន **១០** ដួង បានដល់ :

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ២
- មហាវិបាកចិត្ត ៨

## ចេតសិក និង ទ្វារ

**១. វិរតិចេតសិក ៣ ដួង** គឺ សម្មាវាចា សម្មាកម្មន្តៈ

សម្មាអាជីវៈ កាលណាប្រកបជាមួយនឹងលោកុត្តរចិត្ត រមែងកើតបានចំពោះតែតាមមនោទ្វារ ។

**២. អប្បមញ្ញាចេតសិក ២ ដួង** គឺ ករុណា និងមុទិតាចេតសិក កាលណាប្រកបជាមួយនឹងរូបាវចរចិត្ត ( វៀររូបាវចរវិបាកចិត្ត ៥ ) ឬកាមាវចរចិត្ត រមែងកើតបានចំពោះតែតាមមនោទ្វារប៉ុណ្ណោះ ដូចគ្នា ។

**៣. ចេតសិក ៥២ ដួង** កាលណាប្រកបជាមួយនឹងចិត្ត **៨០** ដួង ( វៀរមហគ្គតវិបាកចិត្ត **៩** ) រមែងកើតនឹងចិត្តក្នុងទ្វារទាំង **៦** ទាំងដែលប្រាកដ(ឯកន្តៈ) និងមិនប្រាកដ(អនេកន្តៈ) ។

**៤. ចេតសិក ៣៥ ដួង** គឺ អញ្ញសមានាចេតសិក **១៣** សោភណចេតសិក **២២** ( វៀរវិរតិ ៣ ) ដែលប្រកបជាមួយនឹងមហគ្គតវិបាកចិត្ត **៩** ដួងនោះ ជាចេតសិកដែលកើតឡើងដោយផុតចាកទ្វារទាំង **៦** (ទ្វារវិមុត្តិ) ។

ការដែលនឹងអាចដឹងថា ចេតសិកណាកើតតាមទ្វារណាៗ នោះគឺ ដោយការពិចារណាយ៉ាងនេះថា ចេតសិកណាប្រកបជាមួយនឹងចិត្តណាខ្លះ បើចិត្តនោះអាស្រ័យកើតឡើងក្នុងទ្វារណា ចេតសិកដែលប្រកបនឹងចិត្តនោះៗ ក៏អាស្រ័យកើតឡើងក្នុងទ្វារនោះដូចគ្នា ។

# ការចែកចេតសិកដោយទ្វារជា ឯកន្តៈ និង អនេកន្តៈ

## ១. ឯកទ្វារិកចេតសិក មាន ៥២ ដួង

+ **ឯកន្តៈ** មាន **២** ដួង បានដល់ :
  - អប្បមញ្ញាចេតសិក **២** ដួង
+ **អនេកន្តៈ** មាន **៥០** ដួង បានដល់ :
  - ចេតសិក **៥០** ដួង

( វៀរអប្បមញ្ញា ២ )

# អធិប្បាយ

ឯកទ្វារិកចេតសិក មានអប្បមញ្ញាចេតសិក **២** កើតបានតែតាមមនោទ្វារប៉ុណ្ណោះដោយប្រាកដ ព្រោះចេតសិក **២** ដួង នេះកើតឡើងទទួលនូវសត្វបញ្ញត្តិជាអារម្មណ៍ ។ ឯវិថីចិត្តដែលអាចទទួលសត្វបញ្ញត្តិអារម្មណ៍បាននោះ បានតែវិថីដែលកើតតាមមនោ-ទ្វារមួយប៉ុណ្ណោះ ដូច្នេះហើយទើប អប្បមញ្ញាចេតសិក **២** ដួង នេះ

កើតបានតែតាម មនោទ្វារដោយប្រាកដ (ជាឯកន្តៈ) ។ ការដែលពោលយ៉ាងនេះ សំដៅយកតែអប្បមញ្ញាចេតសិក ដែលប្រកបជាមួយនឹងកុសល និង កិរិយា ប៉ុណ្ណោះ ប៉ុន្តែបើ អប្បមញ្ញាចេតសិក **២** ដួងនេះប្រកបជាមួយនឹង រូបាវចរវិបាកចិត្ត **៤** ដួង ក៏ជាទ្វារវិមុត្តិ ។

ចំណែកឯកទ្វារិកចេតសិក មានចេតសិក **៥០** ដួង ទៀតនោះ កើតបានក្នុងទ្វារដោយមិនប្រាកដ (ជាអនេកន្តៈ) គឺអាចកើតក្នុងទ្វារដទៃៗទៀតក៏បាន ។

## ២. បញ្ចទ្វារិកចេតសិក មាន ៥០ ដួង

**+ ឯកន្តៈ** មិនមាន ។

**+ អនេកន្តៈ** មាន **៥០** ដួង បានដល់ :

- ចេតសិក **៥០** ដួង

( វៀរអប្បមញ្ញា ២ )

# អធិប្បាយ

បញ្ចទ្វារិកចេតសិក ចេតសិកដែលកើតបានចំពោះតែក្នុងបញ្ចទ្វារ គឺ ប្រកបជាមួយនឹងមនោធាតុ **៣** ដោយចំពោះនោះ មិនមាន ។

ចំណែកចេតសិក **៥០** ដួង ( វៀរអប្បមញ្ញា ២ ) រមែងកើត

បានក្នុងបញ្ចទ្វារដោយមិនប្រាកដ គឺ អាចកើតក្នុងទ្វារដទៃៗទៀតក៏បាន ។

## ៣. ឆទ្វារិកចេតសិក មាន ៥០ ដួង

**+ ឯកន្តៈ** មាន **១៧** ដួង បានដល់ :

- អកុសលចេតសិក **១៤** ដួង
- វិរតិចេតសិក **៣** ដួង

**+ អនេកន្តៈ** មាន **៣៣** ដួង បានដល់ :

- អញ្ញសមានាចេតសិក **១៣** ដួង
- សោភណចេតសិក **២០** ដួង

( វៀរអប្បមញ្ញា ២ ដួង)

# អធិប្បាយ

ឆទ្វារិកចេតសិក សំដៅយកចេតសិកដែលកើតឡើងផុតចាកទ្វារទាំង **៦** ណាមួយមិនបាន គឺ :

អកុសលចេតសិក **១៤** ព្រោះ កាលណាប្រកបជាមួយនឹងអកុសលចិត្ត **១២** តែងកើតបានក្នុងទ្វារ **៦** ជានិច្ច ។

និង វិរតិចេតសិក **៣** កាលប្រកបជាមួយនឹងមហាកុសលចិត្ត

**៨** តែងកើតបានក្នុងទ្វារ **៦** ជានិច្ច ដូចគ្នា ។

ចំណែកចេតសិក **៣៣** ដួង គឺ អញ្ញសមានាចេតសិក **១៣** និង សោភណចេតសិក **២០** ( វៀរវិរតិ **៣** អប្បមញ្ញា **២** ) រមែងប្រកបជាមួយនឹងចិត្តដែលកើតក្នុងទ្វារទាំង ៦ ក៏បាន ប្រកបជាមួយនឹងចិត្តដែលកើតផុតចាកទ្វារក៏បាន ទើបចេតសិក **៣៣** ដួងនេះ ជាឆទ្វារិកចេតសិកមិនប្រាកដ ( ជាអនេកន្តៈ ) ។

## ៤. ទ្វារិកចេតសិក មាន ៥២ ដួង

\+ **ឯកន្តៈ** មាន **១៧** ដួង បានដល់ :

- អកុសលចេតសិក **១៤** ដួង
- វិរតិចេតសិក **៣** ដួង

\+ **អនេកន្តៈ** មាន **៣៥** ដួង បានដល់ :

- អញ្ញសមានាចេតសិក **១៣** ដួង
- សោភណចេតសិក **២២** ដួង ( វៀរវិរតិ ៣ )

# អធិប្បាយ

ចេតសិក **១៧** ដួង ( គឺ អកុសលចេតសិក **១៤** វិរតិចេតសិក **៣** ) គឺ កើតឡើងដោយអាស្រ័យទ្វារដោយប្រាកដនោះ ព្រោះប្រកបជាមួយនឹងចិត្តណាៗ ចិត្តនោះ ( គឺ អកុសលចិត្ត មហាកុសលចិត្ត លោកុត្តរចិត្ត ) ធ្វើជវនកិច្ច ជានិច្ចក្នុងទ្វារ ។

ចំណែកចេតសិក **៣៥** ដួង ( គឺ អញ្ញសមានាចេតសិក **១៣** សោភណចេតសិក **២២** ) នេះវិញ អាចប្រកបនឹងចិត្ត ផុតចាកទ្វារ(ភវង្គចិត្ត **១៩**) ផង និងអាចប្រកបនឹងចិត្តដទៃទៀត ។

## ៥. ទ្វារវិមុត្តចេតសិក មាន ៣៥ ដួង

+ **ឯកន្តៈ** មិនមាន ។

+ **អនេកន្តៈ** មាន **៣៥** ដួង បានដល់ :

   - អញ្ញសមានាចេតសិក **១៣** ដួង
   - សោភណចេតសិក **២២** ដួង

( វៀរវិរតិ ៣ )

# អធិប្បាយ

ទ្វារវិមុត្តចេតសិក ចេតសិកដែលកើតផុតចាកទ្វារដោយប្រាកដនោះ មិនមានឡើយ ព្រោះចេតសិកដែលប្រកបនឹង មហគ្គតវិបាក-ចិត្ត **៩** ដួង ដោយចំពោះនោះ មិនមាន ។

ប៉ុន្តែចំពោះចេតសិក **៣៥** ដួង គឺ អញ្ញសមានាចេតសិក ១៣ ដួង សោភណចេតសិក ២២ ដួង ( វៀរវិរតិ ៣ ) នេះ កើតផុតចាកទ្វារដោយមិនប្រាកដបាន ព្រោះអាចប្រកបនឹងមហគ្គត-វិបាកចិត្ត **៩** ដួងក៏បាន អាចប្រកបនឹងចិត្តដទៃផ្សេងទៀតក៏បាន ៕

( ចប់ទ្វារសង្គហៈ )

---------- • ----------

# អារម្មណសង្គហៈ

ការសម្តែងនូវការរួបរួមនៃចិត្ត និង ចេតសិក ដោយប្រភេទនៃអារម្មណ៍ ឈ្មោះថា “ **អារម្មណសង្គហៈ** ” ។

**អារម្មណ៍** គឺ ធម្មជាតិដែលជាទីត្រេកអររបស់ចិត្តនិងចេតសិក ឬជាធម្មជាតិដែលជាទីតោង របស់ចិត្តនិងចេតសិកទាំងឡាយ ដូចមានវចនត្ថៈថា :

## អា អភិមុខំ រមន្តិ ឯត្ថាតិ អារម្មណំ

ចិត្ត និង ចេតសិកទាំងឡាយ មកត្រេកអរដំណាលគ្នាក្នុងធម្មជាតិណា ដូច្នេះ ធម្មជាតិនោះ ឈ្មោះថា **អារម្មណ៍** ។

## ចិត្តចេតសិកេហិ អាលម្ពិយតីតិ = អាលម្ពណំ

ធម្មជាតិណា ដែល ចិត្ត និង ចេតសិកទាំងឡាយរមែងតោង ដូច្នេះ ធម្មជាតិនោះ ឈ្មោះថា **អាលម្ពណៈ** ។

ដូច្នេះធម្មជាតិណា ដែលធ្វើឲ្យចិត្តនិងចេតសិកទាំងឡាយជាប់ជំពាក់ដោយអាការជាទីគួរត្រេកអរ ឬ ជាទីឲ្យតោងនៅបាន ធម្មជាតិនោះ ហៅថា **អារម្មណ៍** ឬ **អាលម្ពណៈ** បានដល់ អារម្មណ៍

៦ យ៉ាង គឺ :

# អារម្មណ៍ ៦ ប្រភេទ

**១.រូបារម្មណ៍** អង្គធម៌បានដល់ វណ្ណរូប គឺ ពណ៌ផ្សេងៗ

**២.សទ្ទារម្មណ៍** អង្គធម៌បានដល់ សទ្ទរូប គឺ សម្លេងផ្សេងៗ

**៣.គន្ធារម្មណ៍** អង្គធម៌បានដល់ គន្ធរូប គឺ ក្លិនផ្សេងៗ

**៤.រសារម្មណ៍** អង្គធម៌បានដល់ រសរូប គឺ រសផ្សេងៗ

**៥.ផោដ្ឋព្វារម្មណ៍** អង្គធម៌បានដល់ បឋវី ( គឺ រឹង ទន់ ) តេជោ( គឺ ក្តៅ ត្រជាក់ ) វាយោ( គឺ តឹង ញ័រ ) ។

**៦.ធម្មារម្មណ៍** អង្គធម៌បានដល់ ចិត្ត **៨៩** ចេតសិក **៥២** រូប **២១** និព្វាន បញ្ញត្តិ ។

# អធិប្បាយ

ក្នុងបណ្តាសត្វទាំងឡាយដែលមានជីវិតនោះ បើមិនមាន អារម្មណ៍ជាទីអាស្រ័យ ជាទីតោងទេ ចិត្តនិងចេតសិកនៃសត្វទាំង-ឡាយទាំងនោះ ក៏មិនអាចកើតឡើងបាន ឧបមាដូចជា មនុស្សចាស់

ជរាទុព្វលភាព តែងត្រូវអាស្រ័យឈើច្រត់ ឬ ឈើស្នួរ ជាគ្រឿងតោងទប់ខ្លួន ទើបងើបឡើងដើរទៅបាន យ៉ាងណា ចិត្តចេតសិកទាំងឡាយ ត្រូវមានអារម្មណ៍ជាគ្រឿងតោងអាស្រ័យ ទើបប្រាកដឡើងបាន ក៏យ៉ាងនោះ ។

ដូច្នេះកាលណាពោលអំពីអារម្មណ៍ រមែងត្រូវពាក់ព័ន្ធទៅនឹងចិត្ត និងកាលណានឹងពោលអំពីចិត្ត ក៏នឹងត្រូវមានអារម្មណ៍ដូចគ្នា ។ ចិត្តឯណាមួយ ដែលមិនមានអារម្មណ៍នោះ មិនមានឡើយ ។

អារម្មណ៍ដែលជាអាហាររបស់ចិត្តនោះ កាលណាចែកតាមអំណាចនៃការទទួលអារម្មណ៍ផ្សេងៗ ដោយអាស្រ័យតាមទ្វារនោះ មាន **៦** ប្រការ គឺ :

**១. រូបារម្មណ៍** សំដៅយក រូបជាអារម្មណ៍ រូបក្នុងសេចក្ដីនេះ បានដល់ វណ្ណរូប គឺពណ៌ផ្សេងៗ ជាគ្រឿងតោងរបស់ចិត្ត និងចេតសិកបាន តាមទ្វារភ្នែក ។

**២. សទ្ទារម្មណ៍** សំដៅយក សម្លេងជាអារម្មណ៍ បានដល់ សទ្ទរូប ដែលជាគ្រឿងតោងរបស់ចិត្តនិងចេតសិកបាន តាមទ្វារត្រចៀក ។

**៣. គន្ធារម្មណ៍** សំដៅយក ក្លិនជាអារម្មណ៍ បានដល់ គន្ធរូប ដែលជាគ្រឿងតោងរបស់ចិត្តនិងចេតសិកបានតាមទ្វារច្រមុះ ។

**៤. រសារម្មណ៍** សំដៅយក រសជាអារម្មណ៍ បានដល់ រសរូប ដែលជាគ្រឿងគោងរបស់ចិត្តនិងចេតសិកបាន តាមទ្វារអណ្តាត ។

**៥. ផោដ្ឋព្វារម្មណ៍** សំដៅយក ការប៉ះពាល់ត្រូវកាយ ជាអារម្មណ៍ បានដល់ រូបបឋវី-តេជោ-វាយោ គឺ រឹង-ទន់ ក្តៅ-ត្រជាក់ តឹង-ញ័រ ដែលជាគ្រឿងគោងរបស់ចិត្ត និងចេតសិកបាន តាមទ្វារកាយ ។

**៦. ធម្មារម្មណ៍** សំដៅយក សភាវៈដែលដឹងបានចំពោះតែមនោទ្វារវិថីចិត្ត បានដល់ សភាវធម៌ **៦** ប្រការ គឺ ចិត្ត **៨៩** ចេតសិក **៥២** បសាទរូប **៥** សុខុមរូប **១៦** និព្វាន និង បញ្ញត្តិ ដែលជាគ្រឿងគោងរបស់ចិត្តនិងចេតសិកបានតាមទ្វារចិត្ត ។

រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ និង ផោដ្ឋព្វារម្មណ៍ អារម្មណ៍ទាំង **៥** នេះ រួមមកហៅថា **បញ្ចារម្មណ៍** ដែលជា **រូបធម៌** ។

ចំណែក ធម្មារម្មណ៍ ជាអារម្មណ៍ទី **៦** អង្គធម៌ បានដល់ ចិត្ត ចេតសិក និង និព្វាន នោះជានាមធម៌ ។ ចំពោះ បសាទរូប **៥** សុខុមរូប **១៦** នោះជា រូបធម៌ ។ ចំពោះបញ្ញត្តិ មិនមែនជា

រូបធម៌ ទាំងមិនមែនជានាមធម៌ទេ ប៉ុន្តែជាបញ្ញត្តិធម៌ប៉ុណ្ណោះ ។

បញ្ចារម្មណ៍ និង ធម្មារម្មណ៍ រួមមកហៅថា **អារម្មណ៍ ៦** ឬ **ឆអារម្មណ៍** ។

# អំណាចរបស់អារម្មណ៍

ក្នុងអារម្មណ៍ ៦ នេះ កាលណា ចែកដោយអំណាចកម្លាំងរបស់អារម្មណ៍ហើយ អាចចែកចេញជា **២** យ៉ាង គឺ :

**១. សាមញ្ញអារម្មណ៍** គឺ អារម្មណ៍ **៦** បែបដែលទូទៅជាសាមញ្ញធម្មតា ក្នុងការទាញយកចិត្តនិងចេតសិក មកកាន់អារម្មណ៍នោះៗ ។

**២. អធិបតីអារម្មណ៍** គឺ អារម្មណ៍បែបពិសេស មានកម្លាំងខ្លាំងក្លាណាស់ មានអំណាចគ្រប់គ្រងចិត្ត និងចេតសិក និងទាញយក ចិត្តនិងចេតសិកទាំងឡាយនោះ ឲ្យចូលមករកខ្លួន ហើយចិត្តចេតសិកនោះ ក៏តោងចាប់អារម្មណ៍នោះទុក យ៉ាងណែន យ៉ាងធ្ងន់ ។ អារម្មណ៍ដែលមានកម្លាំងខ្លាំងក្លានោះ ហៅថា **អារម្មណា-ធិបតី** ឬ **អធិបតីអារម្មណ៍** ។

អារម្មណ៍ដែលជាអធិបតីបាននេះ ក៏ត្រូវតែជាអារម្មណ៍គួរជាទី

ប្រាថ្នា គឺ ឥដ្ឋារម្មណ៍ ។

ឥដ្ឋារម្មណ៍ ចែកចេញជា ២ ប្រភេទ គឺ :

**ក. សភាវឥដ្ឋារម្មណ៍** សំដៅយក អារម្មណ៍ដែលគួរជាទីត្រេកអរ ដោយធម្មជាតិ ឬដោយសភាវៈ ដូចជា រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ជាដើម ដែលជាទីត្រេកអរដល់បុគ្គលទូទៅ ។

**ខ. បរិកប្បឥដ្ឋារម្មណ៍** សំដៅយក អារម្មណ៍ដែលគួរជាទីត្រេកអរ ចូលចិត្តចំពោះបុគ្គល មិនមែនដល់សត្វទូទៅទាំងអស់ទេ ។ អារម្មណ៍ បែបនេះមិនមែនជាអារម្មណ៍ដែលគួរជាទីត្រេកអរដោយធម្មជាតិ ឬ ដោយសភាវៈទេ និងមិនមែនជាអារម្មណ៍ ដែលគួរជាទីត្រេកអររបស់បុគ្គលភាគច្រើនដែរ ប៉ុន្តែជាអារម្មណ៍ដែលគួរត្រេកអរគាប់ចិត្តរបស់បុគ្គលខ្លះ ៗ ឬ ពួកសត្វខ្លះ ៗ ឬ ចំពោះតែខ្លួនឯងប៉ុណ្ណោះ ។

**សភាវៈឥដ្ឋារម្មណ៍** ឬ **បរិកប្បឥដ្ឋារម្មណ៍** នេះកាលណាអាចធ្វើឲ្យនាមធម៌កើតឡើងបាន ដោយអាការទាញយកអារម្មណ៍នោះជាពិសេសហើយ បានឈ្មោះថា ជាអធិបតីអារម្មណ៍ ដូចមានវចនត្ថៈ ថា **ចិត្តចេតសិកេ អាលម្ពតីតិ អាលម្ពណំ** ប្រែថា ធម្មជាតិណា តែងទាញយកចិត្តនិងចេតសិកទាំងឡាយ ធម្មជាតិនោះឈ្មោះថា **អាលម្ពណៈ** បានដល់ អារម្មណ៍ ៦ ដែលជាអធិបតី ។

# ការចែកទ្វារិកចិត្តនិងទ្វារវិមុត្តចិត្ត ដោយអារម្មណ៍ ៦

| | | | |
|---|---|---|---|
| ១.ចក្ខុទ្វារិកចិត្ត | ៤៦ | ដួង | ទទួលរូបារម្មណ៍ ដែលជាបច្ចុប្បន្នតែម្យ៉ាង ។ |
| ២.សោតទ្វារិកចិត្ត | ៤៦ | ដួង | ទទួលសទ្ទារម្មណ៍ ដែលជាបច្ចុប្បន្នតែម្យ៉ាង ។ |
| ៣.ឃានទ្វារិកចិត្ត | ៤៦ | ដួង | ទទួលគន្ធារម្មណ៍ដែលជាបច្ចុប្បន្នតែម្យ៉ាង ។ |
| ៤.ជិវ្ហាទ្វារិកចិត្ត | ៤៦ | ដួង | ទទួលរសារម្មណ៍ដែលជាបច្ចុប្បន្នតែម្យ៉ាង ។ |
| ៥.កាយទ្វារិកចិត្ត | ៤៦ | ដួង | ទទួលផោដ្ឋព្វារម្មណ៍ ដែលជាបច្ចុប្បន្នតែម្យ៉ាង ។ |
| ៦.មនោទ្វារិកចិត្ត | ៦៧ | ដួង | ទទួលអារម្មណ៍ ៦ ដែលជា |
| ឬ | ៩៩ | ដួង | បច្ចុប្បន្ន អតីត អនាគត និងកាលវិមុត្តិ តាមសមគួរដល់អារម្មណ៍ ។ |

**៧.ទ្វារវិមុត្តចិត្ត ១៩ ដួង** ដែលធ្វើនាទីបដិសន្ធិ ភវង្គ ចុតិ ទទួលអារម្មណ៍ណាមួយ ក្នុងបណ្តាអារម្មណ៍ទាំង ៦ អារម្មណ៍នោះ ហៅថា **កម្មអារម្មណ៍ កម្មនិមិត្តអារម្មណ៍** និង**គតិនិមិត្តអារម្មណ៍** ដែលជាបច្ចុប្បន្ន អតីត និងបញ្ញត្តិ ត្រង់ឆទ្វារិកមរណាសន្នជវនៈ ទទួលយកមកពីភពមុន ក្នុងកាលដែលជិតនឹងស្លាប់ជាចំណែកច្រើន ។

# អធិប្បាយ

**១-៥.** ចក្ខុទ្វារិកចិត្ត សោតទ្វារិកចិត្ត ឃានទ្វារិកចិត្ត ជីវ្ហាទ្វារិកចិត្ត កាយទ្វារិកចិត្ត មានចិត្តកើតបាន **៤៦** ដួង គឺ កាមាវចរចិត្ត **៤៦** ដួង (វៀរចិត្ត ៨ ដួងក្នុងទ្វិបញ្ចវិញ្ញាណចិត្ត ដែលកើតមិនបានដោយចំពោះក្នុងទ្វារនោះៗ) មានរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ដែលជាបច្ចុប្បន្ន

តែម្យ៉ាងនោះ បានសេចក្តីថា ចក្ខុទ្វារិកចិត្តជាដើម នឹងអាចដឹងនូវរូបារម្មណ៍បាន ចាំបាច់ត្រូវតែរូបារម្មណ៍ ដែលកំពុងប្រាកដនៅចំពោះមុខប៉ុណ្ណោះ សោតទ្វារិកចិត្តរហូតដល់កាយទ្វារិកចិត្ត ក៏មានន័យដូចគ្នា ។ សេចក្តីនេះព្រោះថា ចក្ខុទ្វារិកចិត្តជាដើម នឹងអាចកើតឡើងបាននោះ ត្រូវអាស្រ័យអារម្មណ៍ជាធំ បើមិនមានអារម្មណ៍មកចំពោះមុខទេ ចិត្តទាំងនេះក៏កើតឡើងមិនបាន ។

**៦.** មនោទ្វារិកចិត្ត **៦៧** ឬ **៩៩** ដួង គឺ :

- កាមាវចរចិត្ត **៤១** ដួង ( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ )
- មហគ្គតចិត្ត **១៨** ដួង ( វៀរមហគ្គតវិបាកចិត្ត ៩ )
- លោកុត្តរចិត្ត **៨** ឬ **៤០** ដួង

បើអារម្មណ៍នោះជាចិត្ត ចេតសិក រូប កំពុងប្រាកដចំពោះមុខក្តី កន្លងទៅហើយក្តី នឹងប្រាកដខាងមុខក្តី មនោទ្វារិកចិត្តទាំងនេះអាចដឹងបានទាំងអស់ សូម្បីកាលវិមុត្តិអារម្មណ៍ គឺនិព្វាន និងបញ្ញត្តិចិត្តទាំងនេះក៏អាចទទួលដឹងបានដែរ ។

ដូច្នេះមនោទ្វារិកចិត្ត រមែងដឹងអារម្មណ៍បានទាំងអស់ ជាបរមត្ថក្តី ជាបញ្ញត្តិក្តី ព្រោះចិត្តទាំងនេះដែលកើតឡើងបាន មិនបានអាស្រ័យអារម្មណ៍ជាធំទេ គឺអាស្រ័យចិត្ត ចេតសិកជាធំ ក្នុងការកើត

ឡើងដឹងអារម្មណ៍ទាំងអស់នោះបាន ។

**៧.** ទ្វារវិមុត្តិចិត្ត **១៩** ដួង គឺ :

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត **២** ដួង
- មហាវិបាកចិត្ត **៨** ដួង
- មហគ្គតវិបាកចិត្ត **៩** ដួង

អារម្មណ៍ទាំង ៦ គឺ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ បឋវី-តេជោ-វាយោផោដ្ឋព្វារម្មណ៍ និង ធម្មារម្មណ៍ ដូចដែលបានពោលមកហើយ កាលណាសង្គ្រោះដោយកាលហើយ ក៏ចែកចេញបានជា ២ ប្រភេទ ។ អារម្មណ៍ ២ ប្រភេទនោះ គឺ តេកាលិកអារម្មណ៍ និង កាលវិមុត្តិអារម្មណ៍ ។

**១. តេកាលិកអារម្មណ៍** គឺ អារម្មណ៍ ៦ ដែលទាក់ទង ជាមួយនឹងកាលទាំង ៣ គឺ អតីត បច្ចុប្បន្ន អនាគត អង្គធម៌ បានដល់ **ចិត្ត ចេតសិក រូប** ។

- ចិត្ត ចេតសិក រូប ដែលជាអតីតអារម្មណ៍នោះ សំដៅ យក ចិត្ត ចេតសិក រូប ដែលជាអារម្មណ៍ទាំងនោះ បានកន្លងទៅ ហើយ គឺ បានឃើញហើយ បានឮហើយ បានធុំក្លិនហើយ បាន ដឹងរស ហើយបានប៉ះពាល់ត្រូវហើយ និងនឹកគិតដល់អារម្មណ៍ដែល

បានកន្លងទៅហើយ ទាំងនេះហៅថា **អតីតអារម្មណ៍** ។

- ចិត្ត ចេតសិក រូប ដែលជាអារម្មណ៍បច្ចុប្បន្ននោះ សំដៅយកចិត្ត ចេតសិក រូប ខណៈដែលកំពុងប្រាកដជាអារម្មណ៍មាននៅចំពោះមុខ គឺ កំពុងឃើញ កំពុងឮ កំពុងធុំក្លិន កំពុងដឹងរស កំពុងប៉ះពាល់ត្រូវ និងកំពុងនឹកគិត ក្នុងអារម្មណ៍ដែលប្រាកដតាមមនោទ្វារមិនទាន់រលត់ ទាំងនេះហៅថា **បច្ចុប្បន្នអារម្មណ៍** ។

- ចិត្ត ចេតសិក រូប ដែលជាអនាគតអារម្មណ៍នោះ សំដៅយកអារម្មណ៍ផ្សេង ៗ គឺ ចិត្ត ចេតសិក រូប ទាំងនោះ នឹងមកប្រាកដ តាមផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត គឺ នឹងឃើញ នឹងឮ នឹងធុំក្លិន នឹងដឹងរស នឹងប៉ះពាល់ត្រូវ នឹងនឹកគិតដល់អារម្មណ៍ដែលនឹងមកប្រាកដតាមមនោទ្វារ ទាំងនេះឈ្មោះថា **អនាគតអារម្មណ៍** ។

រួមអារម្មណ៍ទាំង ៣ ប្រភេទនេះ ហៅថា **តេកាលិក-អារម្មណ៍** ។

**២. កាលវិមុត្តិអារម្មណ៍** សំដៅយកអារម្មណ៍ដែលមិនទាក់ទងជាមួយនឹងកាលទាំង ៣ បានដល់ **និព្វាន** និង **បញ្ញត្តិ-អារម្មណ៍** ។

និព្វាន និង បញ្ញត្តិ ដែលជាកាលវិមុត្តិអារម្មណ៍នោះ ព្រោះធម៌ទាំង ២ ពួកនេះ ជាអសង្ខតធម៌ មិនបានត្រូវតាក់តែងដោយបច្ច័យ ៤ គឺ កម្ម ចិត្ត ឧតុ និង អាហារទេ ដូច្នេះការកើតឡើងនៃធម៌ទាំង ២ ពួកនេះ ព្រោះបច្ច័យតាក់តែង ទើបមិនមាន ។ កាលណាមិនមានការកើតឡើងហើយ ក៏មិនអាចពោលថា និព្វាន ឬ បញ្ញត្តិទាំងនេះជា បច្ចុប្បន្ន អតីត អនាគតបានឡើយ បើមិនអាចប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន អតីត អនាគតយ៉ាងនេះហើយ ទើបហៅថា **កាលវិមុត្តិអារម្មណ៍** ៕

# សម្ដែងចិត្ត ដែលទទួលអារម្មណ៍ដោយ ឯកន្តៈ ៤ ប្រភេទ និងដោយអនេកន្តៈ ៣ ប្រភេទ

# គាថាសង្គហៈ

១១. បញ្ចវីស បរិត្តម្ហិ ឆចិត្តានិ មហគ្គតេ
ឯកវីសតិ វោហារេ អដ្ឋ និព្វានគោចរេ

## ១២.វីសានុត្តរ មុត្តម្ហិ អគ្គមគ្គផលុជ្ឈិតេ
## បញ្ចសព្វត្ថ ឆ ចេតិ សត្តធា តត្ថ សង្គហោ

គាថាទី ១១ ប្រែថា :

- ចិត្ត **២៥** ដួង កើតឡើងទទួលអារម្មណ៍ ៦ ដែលជា
  កាមធម៌ តែម្យ៉ាង ។
- ចិត្ត **៦** ដួង កើតឡើងទទួលធម្មារម្មណ៍ ដែលជា
  មហគ្គត តែម្យ៉ាង ។
- ចិត្ត **២១** ដួង កើតឡើងទទួលធម្មារម្មណ៍ ដែលជា
  បញ្ញត្តិ តែម្យ៉ាង ។
- ចិត្ត **៨** ដួង កើតឡើងទទួលធម្មារម្មណ៍ ដែលជា
  និព្វាន តែម្យ៉ាង ។

គាថាទី ១២ ប្រែថា :

- ចិត្ត **២០** ដួង កើតឡើងបានក្នុងអារម្មណ៍ ៦ ដែលជា
  កាមធម៌ មហគ្គតធម៌ និងបញ្ញត្តិធម៌
  ( វៀរលោកុត្តរធម៌ ៩ ) ។
- ចិត្ត **៥** ដួង កើតឡើងបានក្នុងអារម្មណ៍ ៦ ដែលជា

កាមធម៌ មហគ្គតធម៌ បញ្ញត្តិធម៌ និង លោកុត្តរធម៌ ( វៀរ អរហត្តមគ្គ អរហត្តផល ) ។

- ចិត្ត ៦ ដួង កើតឡើងបានក្នុងអារម្មណ៍ ៦ ដែលជា កាមធម៌ មហគ្គតធម៌ បញ្ញត្តិធម៌ និង លោកុត្តរធម៌ ទាំងអស់ ។

ក្នុងអារម្មណ៍សង្គហៈនេះ សង្គ្រោះការទទួលអារម្មណ៍របស់ចិត្ត បាន ៧ នោះ ដោយប្រភេទទទួលអារម្មណ៍ប្រាកដ (ឯកន្តៈ) ៤ និង មិនប្រាកដ (អនេកន្តៈ) ៣ ដោយប្រការយ៉ាងនេះ គឺ :

# អធិប្បាយ

អារម្មណ៍ទាំង ៦ នេះ កាលចែកដោយប្រភេទធំៗហើយ មាន ៤ ប្រភេទ គឺ :

**១. កាមារម្មណ៍** បានដល់ អារម្មណ៍ ៦ ។

**២. មហគ្គតារម្មណ៍** បានដល់ ធម្មារម្មណ៍ ។

**៣. បញ្ញត្តិអារម្មណ៍** បានដល់ ធម្មារម្មណ៍ ។

**៤. លោកុត្តរអារម្មណ៍** បានដល់ ធម្មារម្មណ៍ ។

**១. កាមារម្មណ៍** អង្គធម៌បានដល់ កាមាវចរចិត្ត ៥៤ ចេតសិក ៥២ រូប ២៨ ពោលគឺ កាលខណៈនៃចិត្តណា តោងយក កាមចិត្ត ៥៤ ដួងណាមួយជាអារម្មណ៍ក្តី ឬ តោងយករូប ២៨ ណាមួយជាអារម្មណ៍ក្តី ក៏បានសេចក្តីថា ចិត្តនោះតោងនូវកាមារម្មណ៍ ឬ មានអារម្មណ៍ជាកាមធម៌ ។

**២. មហគ្គតារម្មណ៍** អង្គធម៌បានដល់ មហគ្គតចិត្ត ២៧ ចេតសិក ៣៥ ពោលគឺ កាលខណៈនៃចិត្តណា តោងយកមហគ្គត-ចិត្ត ២៧ ដួង ណាមួយជាអារម្មណ៍ បានសេចក្តីថា ចិត្តនោះតោង នូវមហគ្គតារម្មណ៍ ឬ មានអារម្មណ៍ជាមហគ្គតធម៌ ។

កាមអារម្មណ៍ និង មហគ្គតអារម្មណ៍នេះ កាលនៅជាអារម្មណ៍ ចងរួបរឹតនៅក្នុងលោកទាំង ៣ គឺ កាមលោក រូបលោក អរូបលោក ទើបរួមហៅអារម្មណ៍ទាំង ២ ប្រភេទនេះ ថា **លោកិយអារម្មណ៍** ហើយកាលខណៈនៃចិត្តណា តោងនូវលោកិយអារម្មណ៍ ក៏ឈ្មោះថា ចិត្តនោះមានអារម្មណ៍ជា **លោកិយធម៌** ។

**៣. បញ្ញត្តិអារម្មណ៍** អង្គធម៌បានដល់ បញ្ញត្តិធម៌ ២ ប្រការ គឺ អត្ថប្បញ្ញត្តិ និង សទ្ទប្បញ្ញត្តិ ៖

- **អត្ថប្បញ្ញត្តិ** បានដល់ សម្មតិប្បញ្ញត្តិ ដោយអាស្រ័យរូបរាងសណ្ឋាន ឬ លក្ខណៈ អាការៈ ដើម្បីឲ្យដឹងសេចក្តី ដឹងការសំគាល់នៃបញ្ញត្តិនោះៗ ដូចជា រូបរាងលក្ខណៈ របស់ភ្នំ-ដើមឈើ-ទន្លេ ស្ទឹងអូរ-ស្រែចំការ-កសិណប្បញ្ញត្តិ អានាបានប្បញ្ញត្តិ សត្វប្បញ្ញត្តិ ទាំងនេះជាដើម ។

- **សទ្ទប្បញ្ញត្តិ** បានដល់ សម្លេងដែលពោលចេញមក ជាពាក្យ ជាឃ្លា ប្រើសម្រាប់ហៅឈ្មោះសម្មតិប្បញ្ញត្តិ វត្ថុ របស់របរនោះៗឲ្យដឹងសេចក្តីបាន ដូចជា ពេលនិយាយ អំពីភ្នំ ដើមឈើ តុកៅអី ស្រី ប្រុស ឬ ប្រាប់ថា ងាកឆ្វេង ទៅមុខ ចុះមក ទាំងនេះជាដើម សូម្បីមិនបានឃើញ របស់ដែលនិយាយក្នុងខណៈនោះមែន ប៉ុន្តែក៏អាចដឹង អាចយល់នូវន័យសេចក្តីបាន ពីសម្លេងពាក្យនោះ ពីសម្លេងឃ្លានោះ ដែលថ្លែងចេញមកនោះបាន សម្លេងនោះឯងដែលហៅថា **សទ្ទប្បញ្ញត្តិ** ។

ដូច្នេះកាលខណៈនៃចិត្តណា តោងយកបញ្ញត្តិណាមួយ មកជាអារម្មណ៍ហើយ ក៏បានឈ្មោះថា ចិត្តនោះតោងបញ្ញត្តិអារម្មណ៍ ឬមានអារម្មណ៍ជាបញ្ញត្តិ ។

**៤. លោកុត្តរអារម្មណ៍** អង្គធម៌បានដល់ មគ្គចិត្ត ៤ ផលចិត្ត ៤ ចេតសិក ៣៦ និងនិព្វាន ១ ។ កាលខណៈនៃចិត្ត

ណា តោងយក មគ្គចិត្ត ផលចិត្ត ឬ និព្វាន ណាមួយមកជាអារម្មណ៍ហើយ បានសេចក្តីថា ចិត្តនោះតោងលោកុត្តរអារម្មណ៍ ឬ មានអារម្មណ៍ជា **លោកុត្តរធម៌** ។

តទៅនេះ នឹងបានសម្តែងនូវការចែកចិត្ត ដែលកើតឡើងជាមួយនឹងអារម្មណ៍ទាំង ៤ ប្រភេទ ក្នុងគាថា សង្គហៈទី ១១ និងលំដាប់មកជាមួយនឹងអារម្មណ៍ទាំង ៣ ប្រភេទ ក្នុងគាថាសង្គហៈទី ១២ :

# ការចែកចិត្ត ៦០ ឬ ៩២ ដួង ដែលទទួលអារម្មណ៍ ប្រាកដដោយអារម្មណ៍ ៦ និង កាល ៣

**១.** ចិត្តដែលទទួល**កាមារម្មណ៍ដោយប្រាកដ(ជាឯកន្តៈ)** មាន **២៥** ដួង " **បញ្ចវីស បរិត្តម្ហិ** " :

- ចក្ខុវិញ្ញាណចិត្ត **២** ទទួលរូបារម្មណ៍ ដែលជាបច្ចុប្បន្នតែម្យ៉ាង ។
- សោតវិញ្ញាណចិត្ត **២** ទទួលសទ្ទារម្មណ៍ ដែលជាបច្ចុប្បន្នតែម្យ៉ាង ។

- ឃានវិញ្ញាណចិត្ត ២ ទទួលគន្ធារម្មណ៍ ដែលជាបច្ចុប្បន្ន តែម្យ៉ាង ។
- ជីវ្ហាវិញ្ញាណចិត្ត ២ ទទួលរសារម្មណ៍ ដែលជាបច្ចុប្បន្ន តែម្យ៉ាង ។
- កាយវិញ្ញាណចិត្ត ២ ទទួលផោដ្ឋព្វារម្មណ៍ ដែលជាបច្ចុប្បន្ន តែម្យ៉ាង ។
- មនោធាតុ ៣ ទទួលបញ្ចារម្មណ៍ ដែលជាបច្ចុប្បន្ន តែម្យ៉ាង ។
- មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ៣ ទទួលអារម្មណ៍ ៦ ដែលជា បច្ចុប្បន្ន អតីត អនាគត ។
- មហាវិបាកចិត្ត ៨
- ហសិតុប្បាទចិត្ត ១

} ទទួលអារម្មណ៍ ៦ ដែលជា បច្ចុប្បន្ន អតីត អនាគត ។

**២.** ចិត្តដែលទទួល **មហគ្គតារម្មណ៍ដោយប្រាកដ** មាន **៦** ដួង “ **ឆចិត្តានិ មហគ្គតេ** ” :

- វិញ្ញាណញ្ចាយតនកុសលចិត្ត ១
- វិញ្ញាណញ្ចាយតនវិបាកចិត្ត ១

} ទទួលអាកាសានញ្ចាយតនកុសលជាអារម្មណ៍ ដែលជាអតីត តែម្យ៉ាង ។

-វិញ្ញាណញ្ចាយតនកិរិយាចិត្ត ១ ទទួលអាកាសានញ្ចាយតនកុសល និងកិរិយាជាអារម្មណ៍ ដែលជាអតីត តែម៉្យាង ។

-នេវសញ្ញានាសញ្ញាយតន-កុសលចិត្ត ១
-នេវសញ្ញានាសញ្ញាយតន-វិបាកចិត្ត ១
ទទួលអាកិញ្ចញ្ញាយតនកុសលជាអារម្មណ៍ដែលជាអតីតតែម៉្យាង ។

-នេវសញ្ញានាសញ្ញាយតន-កិរិយាចិត្ត ១ ទទួល អាកិញ្ចញ្ញាយតនកុសល និង កិរិយាជាអារម្មណ៍ ដែលជាអតីត តែម៉្យាង ។

**៣.** ចិត្តដែលទទួល **បញ្ញត្តិអារម្មណ៍ដោយប្រាកដ** មាន **២១** ដួង " **ឯកវិសតិ វោហារេ** " :

- រូបាវចរបឋមជ្ឈានចិត្ត ៣ មានបញ្ញត្តិធម្មារម្មណ៍ ២៥ យ៉ាង គឺ កសិណបញ្ញត្តិ ១០ អសុភ-បញ្ញត្តិ ១០ កោដ្ឋាសបញ្ញត្តិ ១ អានាបានបញ្ញត្តិ ១ បិយមនា-បសត្វបញ្ញត្តិ ១ ទុក្ខិតសត្វ-

| | |
|---|---|
| | បញ្ញត្តិ ១ សុខិតសត្វបញ្ញត្តិ ១ ដែលជាកាលវិមុត្តិ តែម្យ៉ាង ។ |
| -រូបាវចរទុតិយជ្ឈានចិត្ត ៣<br>-រូបាវចរតតិយជ្ឈានចិត្ត ៣<br>-រូបាវចរចតុត្ថជ្ឈានចិត្ត ៣ | មានបញ្ញត្តិធម្មារម្មណ៍ ១៤ យ៉ាង គឺ កសិណបញ្ញត្តិ ១០ អានាបានបញ្ញត្តិ ១ បិយមនាបសត្វបញ្ញត្តិ ១ ទុក្ខិតសត្វបញ្ញត្តិ ១ សុខិតសត្វបញ្ញត្តិ ១ ដែលជាកាលវិមុត្តិ តែម្យ៉ាង ។ |
| -រូបាវចរបញ្ចមជ្ឈានចិត្ត ៣ | មានបញ្ញត្តិធម្មារម្មណ៍ ១២ យ៉ាង គឺ កសិណបញ្ញត្តិ ១០ អានាបានបញ្ញត្តិ ១ មជ្ឈត្តសត្វបញ្ញត្តិ ១ ដែលជាកាលវិមុត្តិតែម្យ៉ាង ។ |
| -អាកាសានញ្ចាយតនជ្ឈានចិត្ត ៣ | មានបញ្ញត្តិធម្មារម្មណ៍ គឺ កសិណុគ្ឃាដិមាកាសបញ្ញត្តិ ដែលជាកាលវិមុត្តិតែម្យ៉ាង ។ |
| -អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣ | មានបញ្ញត្តិធម្មារម្មណ៍ គឺ នត្ថិភាវបញ្ញត្តិ ដែលជាកាលវិមុត្តិ តែម្យ៉ាង ។ |

៤. ចិត្តដែលទទួល **លោកុត្តរារម្មណ៍ដោយប្រាកដមាន ៨ ឬ ៤០ ដួង “ អដ្ឋ និព្វាន គោចរា ” :**

-លោកុត្តរចិត្ត **៨ ឬ ៤០** មាននិព្វានធម្មារម្មណ៍ ដែលជាកាលវិមុត្តិតែម្យ៉ាង ៕

# ការចែកចិត្ត ៣១ ដួង ដែលទទួលអារម្មណ៍ មិនប្រាកដ ដោយ អារម្មណ៍ ៦ និង កាល ៣

៥. ចិត្តដែលទទួល**អារម្មណ៍ ៦ វៀរចាកលោកុត្តរធម៌ មាន ២០ ដួង “ វីសានុត្តរមុត្តម្ហិ ” :**

-អកុសលចិត្ត **១២**
-មហាកុសលញាណវិប្បយុត្តចិត្ត **៤**
-មហាកិរិយាញាណវិប្បយុត្តចិត្ត **៤**

} មានអារម្មណ៍ ៦ ដែលជាកាមារម្មណ៍ មហគ្គតារម្មណ៍ និង បញ្ញត្តិអារម្មណ៍ ដែលជា បច្ចុប្បន្ន អតីត អនាគត និងកាលវិមុត្តិ ។

**៦.** ចិត្តដែលទទួល**អារម្មណ៍ ៦ វៀរចាកអរហត្តមគ្គ អរហត្តផលមាន ៥ ដួង "អគ្គមគ្គផលុជ្ឈិតេ បញ្ច" ៖**

| | | |
|---|---|---|
| -មហាកុសលញាណសម្បយុត្តចិត្ត | ៤ | មានអារម្មណ៍ ៦ ដែលជាលោកិយ បញ្ញត្តិ និងលោកុត្តរៈ(វៀរអរហត្តមគ្គ អរហត្តផល ) ដែលជាបច្ចុប្បន្ន អតីត អនាគត និង កាលវិមុត្តិ ។ |
| -អភិញ្ញាកុសលចិត្ត | ១ | |

**៧.**ចិត្តដែលទទួល**អារម្មណ៍បានទាំងអស់មាន ៦ ដួង** គឺ

| | | |
|---|---|---|
| -ឧបេក្ខាមនោវិញ្ញាណធាតុអហេតុក-កិរិយាចិត្ត | ១ | មានអារម្មណ៍ ៦ ដែលជាលោកិយ បញ្ញត្តិ និងលោកុត្តរៈ បានទាំងអស់ ដែលជា បច្ចុប្បន្ន អតីត អនាគត និងកាលវិមុត្តិ ។ |
| -មហាកិរិយាញាណសម្បយុត្តចិត្ត | ៤ | |
| -អភិញ្ញាកិរិយាចិត្ត | ១ | |

# អធិប្បាយក្នុងគាថាទី ១១
# កាមារម្មណ៍

១. ចិត្តដែលទទួល**កាមារម្មណ៍ដោយប្រាកដមាន ២៥ ដួង** គឺ :

**ក. ទ្វិបញ្ចវិញ្ញាណចិត្ត ១០ គឺ :**

-ចក្ខុវិញ្ញាណចិត្ត ២ ទទួលរូបារម្មណ៍ ដែលជាបច្ចុប្បន្នតែម្យ៉ាង ។

-សោតវិញ្ញាណចិត្ត ២ ទទួលសទ្ទារម្មណ៍ ដែលជាបច្ចុប្បន្នតែម្យ៉ាង ។

-ឃានវិញ្ញាណចិត្ត ២ ទទួលគន្ធារម្មណ៍ ដែលជាបច្ចុប្បន្នតែម្យ៉ាង ។

-ជីវ្ហាវិញ្ញាណចិត្ត ២ ទទួលរសារម្មណ៍ ដែលជាបច្ចុប្បន្នតែម្យ៉ាង ។

-កាយវិញ្ញាណចិត្ត ២ ទទួលផោដ្ឋព្វារម្មណ៍ ដែលជាបច្ចុប្បន្នតែម្យ៉ាង ។

ដូច្នេះ ទ្វិបញ្ចវិញ្ញាណចិត្ត **១០** ទើបអាចទទួលអារម្មណ៍ដោយចំពោះ ដែលជាកាមធម៌ និងជាបច្ចុប្បន្នតែម៉្យាងប៉ុណ្ណោះ ។

**ខ. មនោធាតុ ៣** បានដល់ :

-ឧបេក្ខាមនោធាតុអហេតុកកិរិយាចិត្ត ១
-ឧបេក្ខាមនោធាតុអហេតុកវិបាកចិត្ត ២

ចិត្ត ៣ ដួង នេះ ទទួលបញ្ចារម្មណ៍ ណាមួយ ជាអារម្មណ៍ មិនកំណត់ចំពោះអារម្មណ៍មួយ ដូចចក្ខុ-វិញ្ញាណជាដើមទេ ប៉ុន្តែអារម្មណ៍នោះ ៗ នឹងត្រូវប្រាកដចំពោះមុខ ជាបច្ចុប្បន្នដូចគ្នា ។

**គ. ចិត្ត ១២ ដួង** បានដល់ :

-មនោវិញ្ញាណធាតុអហេតុក-វិបាកចិត្ត ៣
-មហាវិបាកចិត្ត ៨
-ហសិតុប្បាទចិត្ត ១

ចិត្តទាំង ១២ នេះ ទទួលអារម្មណ៍ ៦ ណាមួយ ចំពោះតែកាមធម៌ ជាអា-រម្មណ៍បច្ចុប្បន្នតែម៉្យាង ក៏

ទេដែរ អារម្មណ៍នោះនឹង
អាចជា បច្ចុប្បន្នក៏បាន
អតីតក៏បាន អនាគតក៏
បាន ។

សរុបមក ចិត្តទាំង ២៥ ដួង ដែលតោងយកនូវអារម្មណ៍ ៦ សុទ្ធតែជាកាមធម៌តែម្យ៉ាង ដោយចំពោះយ៉ាងនេះ ទើបឈ្មោះថា ចិត្ត ២៥ ដួងនេះ តោងកាមារម្មណ៍ដោយប្រាកដ ៕

# មហគ្គតារម្មណ៍

**២.** ចិត្តដែលទទួល **មហគ្គតារម្មណ៍ដោយប្រាកដ មាន ៦** ដួង គឺ :

**ក. វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣ ដួង** មានអាកាសានញ្ចាយតនកុសលចិត្ត ១ អាកាសានញ្ចាយតនកិរិយាចិត្ត ១ ជាអារម្មណ៍ គឺថា :

**១.** បុគ្គលអ្នកបាន អាកាសានញ្ចាយតនជ្ឈានហើយ នឹងអាចចម្រើនសមថភាវនា ដើម្បីឲ្យបានវិញ្ញាណញ្ចាយតនជ្ឈាន ឬក៏អ្នកដែល

បានសម្រេចនូវវិញ្ញាណញ្ចាយតនជ្ឈានហើយ នឹងចូលវិញ្ញាណញ្ចាយតនជ្ឈានសមាបត្តិទៀត ត្រូវតែអាស្រ័យអាកាសានញ្ចាយតនជ្ឈានកុសល ឬអាកាសានញ្ចាយតនជ្ឈានកិរិយា ដែលធ្លាប់បានកើតហើយដល់ខ្លួននោះ មកជាអារម្មណ៍យ៉ាងណែនជានិច្ច ទើបវិញ្ញាណញ្ចាយតនជ្ឈាន នឹងអាចកើតបាន ។

**២.** តិហេតុកបុថុជ្ជន ឬផលសេក្ខបុគ្គល ដែលបានវិញ្ញាណញ្ចាយតនជ្ឈានហើយ បើមានបំណងនឹងចូលវិញ្ញាណញ្ចាយតនជ្ឈានកុសល ក៏ត្រូវមានអាកាសានញ្ចាយតនជ្ឈានកុសល ដែលបានកើតហើយដល់ខ្លួនក្នុងភពនេះ ជាអារម្មណ៍ ។

**៣.** កាលដែល តិហេតុកបុថុជ្ជន ឬ ផលសេក្ខបុគ្គលបានធ្វើកាលកិរិយាទៅ ហើយនឹងអាចទៅកើតជាអរូបព្រហ្ម ក្នុងវិញ្ញាណញ្ចាយតនភូមិ គឺបដិសន្ធិដោយវិញ្ញាណញ្ចាយតនវិបាកចិត្ត ដោយមានអាកាសានញ្ចាយតនកុសល ដែលធ្លាប់កើតដល់ខ្លួនក្នុងភពមុននោះមកជាអារម្មណ៍ ។ សូម្បីខណៈដែលវិញ្ញាណញ្ចាយតនវិបាក ធ្វើនាទីភវង្គកិច្ច ឬចុតិកិច្ច ក៏ត្រូវមានអាកាសានញ្ចាយតនកុសលដែលធ្លាប់កើតដល់ខ្លួនហើយក្នុងភពមុន មកជាអារម្មណ៍ដូចគ្នា ។

**៤.** តិហេតុកបុថុជ្ជនក្តី ឬ ផលសេក្ខបុគ្គលក្តី កាលណាបាន

ចម្រើនវិបស្សនាតទៅ រហូតបានសម្រេចអរហត្តមគ្គ អរហត្តផល ជាព្រះអសេក្ខបុគ្គលក្នុងជាតិនេះហើយ កាលបើចូលវិញ្ញាណញ្ចាយតនជ្ឈាន ឈានចិត្តដែលកើតថ្មីនេះ ជាវិញ្ញាណញ្ចាយតនកិរិយា ហើយវិញ្ញាណញ្ចាយតនកិរិយា ដែលកើតឡើងនេះ តែងតែមានអារម្មណ៍ ជាអាកាសានញ្ចាយតនកុសល ដែលធ្លាប់កើតដល់ខ្លួនហើយក្នុងភពនេះ ជាអារម្មណ៍ ។

**៥.** ព្រះអរហន្តដែលជា ឈានលាភីបុគ្គល កាលបើបានរួចរវាងបញ្ចមជ្ឈានហើយ មានបំណងនឹងចម្រើនឈានតទៅ ត្រូវចូលអាកាសានញ្ចាយតនជ្ឈានសិន កាលអាកាសានញ្ចាយតនជ្ឈានចិត្តកើត តែងតែជាអាកាសានញ្ចាយតនកិរិយា រួចហើយចម្រើនវិញ្ញាណញ្ចាយតនជ្ឈានតទៅ ដោយមានអាកាសានញ្ចាយតនកិរិយា ជាអារម្មណ៍ ។

ដូច្នេះ កាលបើវិញ្ញាណញ្ចាយតនកិរិយាចិត្តកើត រមែងមានអាកាសានញ្ចាយតនកិរិយា ដែលធ្លាប់បានកើតដល់ខ្លួនក្នុងភពនេះ ជាអារម្មណ៍ ។

រួមសេចក្តីមក វិញ្ញាណញ្ចាយតនកុសល ១ - វិបាក ១ - កិរិយា ១ ជា ៣ ដូងនេះ មានអាកាសានញ្ចាយតនកុសល ១ - វិបាក ១ - កិរិយា ១ ជា ៣ ដូងនេះ មានអាកាសានញ្ចាយតន-

កុសល ដែលកើតដល់ខ្លួនក្នុងភពនេះ ឬ ភពមុន មកជាអារម្មណ៍ និងមានអាកាសានញ្ចាយតនកិរិយា ដែលកើតក្នុងភពនេះជាអារម្មណ៍

**ខ. នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣ ដួង** មាន អាកិញ្ចញ្ញាយតនកុសល ១ និង អាកិញ្ចញ្ញាយតនកិរិយា ១ ជាអារម្មណ៍ គឺថា :

នេវសញ្ញានាសញ្ញាយតនកុសលចិត្ត ១ - វិបាកចិត្ត ១ - កិរិយាចិត្ត ១ មានអាកិញ្ចញ្ញាយតនកុសល ១ ឬ កិរិយា ១ ដែលធ្លាប់បានកើតដល់ខ្លួនមកហើយក្នុងភពនេះ ឬ ភពមុន ជាអារម្មណ៍ ។

ពាក្យអធិប្បាយ មានបែបបទដូចគ្នានឹងសេចក្ដីអធិប្បាយក្នុងវិញ្ញាណញ្ចាយតនជ្ឈានចិត្ត ។

រួមសេចក្ដីមក ចិត្ត ៦ ដួង គឺ វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣ និងនេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣ មានមហគ្គតចិត្ត ៤ ដួង ( គឺ អាកាសានញ្ចាយតនកុសល ១ - កិរិយា ១ និង អាកិញ្ចញ្ញាយតនកុសល ១ កិរិយា ១ ) ជាអារម្មណ៍ ទើបបាន ឈ្មោះថា ចិត្ត ៦ ដួង តោងមហគ្គតារម្មណ៍ ៕

# បញ្ញត្តិអារម្មណ៍

**៣.** ចិត្តដែលទទួល **បញ្ញត្តិអារម្មណ៍ដោយប្រាកដ មាន ២១ ដួង** គឺ :

**ក. រូបាវចរចិត្ត ១៥ ដួង** មានបញ្ញត្តិជាអារម្មណ៍ គឺ រូបាវចរចិត្ត ១៥ ដួងនោះ ជាចិត្តដែលកើតឡើងអំពីការសម្លឹងអារម្មណ៍ បញ្ញត្តិកម្មដ្ឋាន ២៦ ប្រការ បានដល់ កសិណប្បញ្ញត្តិ ១០ អសុភប្បញ្ញត្តិ ១០ អានាបានប្បញ្ញត្តិ ១ កោដ្ឋាសប្បញ្ញត្តិ ១ បិយមនាបសត្វប្បញ្ញត្តិ ១ ទុក្ខិតសត្វប្បញ្ញត្តិ ១ សុខិតសត្វប្បញ្ញត្តិ ១ និងមជ្ឈត្តសត្វប្បញ្ញត្តិ ១ ( សត្វប្បញ្ញត្តិអារម្មណ៍ របស់ព្រហ្មវិហារធម៌ ៤ ) ។

**ខ. អាកាសានញ្ចាយតនជ្ឈានចិត្ត ៣ ដួង** មាន កសិណុគ្ឃាដិមាកាសប្បញ្ញត្តិ ជាអារម្មណ៍តែម្យ៉ាង ។

កសិណុគ្ឃាដិមាកាសប្បញ្ញត្តិនេះ សំដៅដល់ អាកាសល្ហល្ហេវដែលបានដកចេញ ឬ ដែលបានបើកចេញអំពីកសិណ ៩ ( វៀរអាកាសកសិណ ) ។ បញ្ញត្តិអាកាសល្ហល្ហេវនេះឯង កាលកំណត់មកជាអារម្មណ៍ហើយ ទើបបានឈ្មោះថា កសិណុគ្ឃាដិមាកាស-

ប្បញ្ញត្តិ និងចិត្តដែលមានអារម្មណ៍ជាកសិណុគ្ឃាដិមាកាសប្បញ្ញត្តិនេះ ឈ្មោះថា អាកាសានញ្ចាយតនជ្ឈានចិត្ត មានចំនួន ៣ ដួង គឺ អាកាសានញ្ចាយតនកុសលចិត្ត ១ - វិបាកចិត្ត ១ - កិរិយាចិត្ត ១ ដែលមានអារម្មណ៍ជាបញ្ញត្តិយ៉ាងនេះ ដោយចំពោះតែម្យ៉ាងប៉ុណ្ណោះ។

**គ. អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣ ដួង** មាន នត្ថិភាវប្បញ្ញត្តិ ជាអារម្មណ៍តែម្យ៉ាង ។ នត្ថិភាវប្បញ្ញត្តិនេះ សំដៅដល់ សភាពមិនមានអ្វី អ្វីបន្តិចបន្តួចក៏មិនមាន កំណត់យក បញ្ញត្តិសញ្ញាដែលសម្មតិ ថាមិនមានអ្វីឡើយ បង្អោនមកជាអារម្មណ៍ នេះឯង ចិត្តដែលទទួលអារម្មណ៍បញ្ញត្តិនេះ ទើបបានឈ្មោះថា អាកិញ្ចញ្ញាយតនកុសលចិត្ត ១ - វិបាកចិត្ត ១ - កិរិយាចិត្ត ១។

រួមសេចក្ដីមក ចិត្ត ២១ ដួង គឺ រូបាវចរចិត្ត ១៥ ដួង អាកាសានញ្ចាយតនចិត្ត ៣ ដួង អាកិញ្ចញ្ញាយតនចិត្ត ៣ ដួង សុទ្ធ តែមានបញ្ញត្តិអារម្មណ៍ទាំងអស់ ។

# និព្វានារម្មណ៍

**៤.** ចិត្តដែលទទួល **និព្វានអារម្មណ៍ដោយប្រាកដមាន ៨ ដួង** គឺៈ

-លោកុត្តរចិត្ត ៨ ដួង គឺ មគ្គចិត្ត ៤ ផលចិត្ត ៤ មាន
និញ្វាន ជាអារម្មណ៍តែម៉្យាង ។

និញ្វាននោះ សំដៅដល់ សភាពអស់ទៅនៃតណ្ហាដែលជាគ្រឿងចងរួបរឹតសត្វទាំងឡាយទុក មិនឲ្យរួចផុតពីសង្សារវដ្ត ។ មគ្គចិត្ត ៤ ផលចិត្ត ៤ នេះ ជាចិត្តដែលកាត់ផ្តាច់នូវចំណង ដូច្នេះចិត្តទាំងនេះមិនបានមកពាក់ព័ន្ធ ប្រាស្រ័យជាមួយនឹងអារម្មណ៍ ៦ យ៉ាងណាមួយឲ្យជាប់ជំពាក់នឹងការប្រព្រឹត្តទៅក្នុងលោកនេះឡើយ ទើបត្រូវតោងយកអារម្មណ៍ពិសេស ដែលសត្វណាៗ ក្នុងលោកមិនធ្លាប់បានជួប មិនធ្លាប់បានឃើញដោយខ្លួនឯងមកពីមុន វៀរតែព្រះអរិយបុគ្គលប៉ុណ្ណោះ ។

ដូច្នេះលោកុត្តរចិត្ត **៨** ដួងនេះ នឹងមានភារៈយ៉ាងដទៃជាអារម្មណ៍មិនបានឡើយ ក្រៅពីមានព្រះនិញ្វានជាអារម្មណ៍តែម៉្យាងប៉ុណ្ណោះ ។

# កាលវិមុត្តារម្មណ៍

កាមារម្មណ៍ តែងជាអារម្មណ៍ដែលប្រព្រឹត្តទៅបាន ក្នុងបច្ចុប្បន្នផង អតីតផង និងអនាគតផង គឺបានក្នុងកាលទាំង ៣ បរិបូណ៌ ។

ចំណែក មហគ្គតារម្មណ៍ ប្រព្រឹត្តទៅបានទាំង ៣ កាល

ប៉ុន្តែត្រង់អារម្មណ៍របស់វិញ្ញាណញ្ចាយតនជ្ឈាន និង នេវសញ្ញានាសញ្ញាយតនជ្ឈាននោះ ត្រូវតែជាអតីតកាលម្យ៉ាងប៉ុណ្ណោះ ។

ចំណែក បញ្ញត្តិអារម្មណ៍ និង និព្វានអារម្មណ៍ នោះ មិនមានក្នុងកាលទេ គឺ មិនជាបច្ចុប្បន្ន-អតីត-អនាគត ។ បញ្ញត្តិអារម្មណ៍ជាធម៌ដែល **មិនមានសភាវៈ** មិនមានសភាពប្រែប្រួល មិនមានការកើត ការរលត់ មិនមានសភាពមិនទៀង យ៉ាងនេះហើយ ទើបមិនបានចូលក្នុងកាលទាំង ៣ អាស្រ័យដោយការមិនមាន អតីត-បច្ចុប្បន្ន-អនាគត ទើបបញ្ញត្តិអារម្មណ៍ជាកាលវិមុត្តិ ។

ឯនិព្វានវិញ ជាធម៌ **មានសភាវៈ** យ៉ាងក្រៃលែង ជាធម៌មានសភាពទៀង ឋិតថេរ មិនប្រែប្រួល និងមិនមានការកើត ការរលត់ យ៉ាងនេះហើយ ទើបមិនចាត់ចូលក្នុងកាលទាំង ៣ អាស្រ័យដោយការមិនមានអតីត-បច្ចុប្បន្ន-អនាគត ទើបនិព្វានជាកាលវិមុត្តិ ។

រួមសេចក្តីមក ធម៌ដែលជាកាលវិមុត្តិ ឬ អារម្មណ៍ជាកាលវិមុត្តិ នោះមាន **២** ប្រការ គឺ បញ្ញត្តិ និង និព្វាន ។

ក្នុងគាថាទី **១១** សម្តែងអំពីការចែកចិត្ត **៦០** ដួង ទទួលអារម្មណ៍ ៦ ក្នុងកាលទាំង ៣ និងកាលវិមុត្តិនោះ ទទួលអារម្មណ៍បានប្រាកដ (ជាឯកន្តៈ) តាមលំដាប់នៃចិត្តនោះ គឺ :

ចិត្ត ទទួលកាមារម្មណ៍ប្រាកដមាន **២៥** ដួង

ចិត្ត ទទួលមហគ្គតារម្មណ៍ប្រាកដមាន ៦ ដួង
ចិត្ត ទទួលបញ្ញត្តិអារម្មណ៍ប្រាកដមាន **២១** ដួង
ចិត្ត ទទួលនិព្វានារម្មណ៍ប្រាកដមាន **៨** ដួង

ចំនួនចិត្តទាំងអស់មាន **៨៩** ឬ **១២១** ដួង កាលដែលទទួលអារម្មណ៍ប្រាកដជាឯកន្តៈបាន **៦០** ដួង ដូច្នេះ នៅសល់ **២៩** ដួងទៀត ទទួលអារម្មណ៍បានច្រើនយ៉ាងមិនប្រាកដ ( ជាអនេកន្តៈ ) ហើយអារម្មណ៍ច្រើនយ៉ាងដែលជាអារម្មណ៍របស់ចិត្ត **២៩** ដួងនោះហៅថា **សព្វារម្មណ៍** ។

# អធិប្បាយក្នុងគាថាទី ១២
# សព្វារម្មណ៍

ចំនួនចិត្ត ២៩ ដួងដែលសល់អំពីចិត្ត ៦០ ដួង ដែលបានពោលរួចមកហើយ ក្នុងគាថាសង្គហៈទី ១១ ជាចិត្តដែលអាចទទួលអារម្មណ៍ផ្សេងៗ បានច្រើនអារម្មណ៍នោះ នៅមានរាប់បញ្ចូលចិត្តពិសេស ២ ដួងទៀត គឺ អភិញ្ញាកុសលចិត្ត ១ ដួង និងអភិញ្ញា-កិរិយាចិត្ត ១ ដួង ទើបបានជាចិត្ត ៣១ ដួង ។

ដូច្នេះក្នុងគាថាទី ១២ នេះ ដែលសម្តែងថា ចំនួនចិត្ត ៣១

ដួងនេះ ជាចិត្តដែលទទួលអារម្មណ៍ផ្សេងៗ បានច្រើនយ៉ាង បានច្រើនកាល មិនថាជាអតីត - បច្ចុប្បន្ន - អនាគត ឬសូម្បីកាលវិមុត្តិផងដែរ ទើបហៅអារម្មណ៍ដែលចិត្ត ៣១ ដួងទទួលដឹងនេះ ថា **សព្វារម្មណ៍** ។

## ៥. ចិត្ត ២០ ដួង ដែលទទួលដឹងសព្វារម្មណ៍បាន

វៀរតែលោកុត្តរអារម្មណ៍នោះ បានដល់ :

| | | |
|---|---|---|
| - អកុសលចិត្ត | ១២ | ២០ ដួង |
| - មហាកុសលញាណវិប្បយុត្តចិត្ត | ៤ | |
| - មហាកិរិយាញាណវិប្បយុត្តចិត្ត | ៤ | |

ចិត្ត ២០ ដួងនេះ រមែងទទួលអារម្មណ៍ទាំង ៦ ណាមួយដែលជា លោកិយអារម្មណ៍ គឺ ជាកាមអារម្មណ៍ មហគ្គតអារម្មណ៍ ឬបញ្ញត្តិអារម្មណ៍ក៏បាន វៀរតែលោកុត្តរអារម្មណ៍ម្យ៉ាងប៉ុណ្ណោះ ។

ព្រោះអកុសលចិត្ត ១២ ជាចិត្តដែលមិនល្អ មិនសោភណៈ ប្រកបជាមួយនឹង លោភៈ ទោសៈ មោហៈ ទើបមិនអាចមានលោកុត្តរធម៌ ៩ គឺ មគ្គចិត្ត ៤ ផលចិត្ត ៤ និងនិព្វាន ១ មកជាអារម្មណ៍បានឡើយ ។

ចំពោះមហាកុសលចិត្ត ៤ មហាកិរិយាចិត្ត ៤ ដែលជាញាណវិប្បយុត្ត ក៏មិនអាចទទួលលោកុត្តរអារម្មណ៍បានដែរ ព្រោះ

ចិត្តទាំង ៨ ដួងនេះ ជាចិត្តមិនប្រកបដោយបញ្ញា ចិត្តដែលមិនបាន ប្រកបដោយបញ្ញា រមែងទទួលលោកុត្តរធម៌ គឺ មគ្គចិត្ត ៤ ផលចិត្ត ៤ និង និព្វាន ១ មិនបានដូចគ្នា ។

**៦. ចិត្ត ៥ ដួង ដែលទទួលដឹងសព្វារម្មណ៍បាន** វៀរតែ អរហត្តមគ្គ អរហត្តផលនោះ បានដល់ :

- មហាកុសលញាណសម្បយុត្តចិត្ត **៤**
- អភិញ្ញាកុសលចិត្ត **១**

} **៥** ដួង

ចិត្ត ៥ ដួង នេះ រមែងទទួលអារម្មណ៍ទាំង ៦ ណាមួយ ដែលជាលោកិយ និង បញ្ញត្តិ រហូតដល់លោកុត្តរអារម្មណ៍ក៏បាន ប៉ុន្តែវៀរអរហត្តមគ្គ អរហត្តផលចេញ ពីព្រោះអ្នកដែលបង្អោនយក អរហត្តមគ្គ អរហត្តផល មកជាអារម្មណ៍បាននោះ បុគ្គលនោះត្រូវ បានសម្រេចជាព្រះអរហន្តហើយ ។

**៧. ចិត្ត ៦ ដួងដែលទទួលដឹងសព្វារម្មណ៍បានទាំងអស់** បានដល់ :

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
- មហាកិរិយាញាណសម្បយុត្តចិត្ត ៤
- អភិញ្ញាកិរិយាចិត្ត ១

} ៦ ដួង

ចិត្ត **៦** ដួង នេះទទួលអារម្មណ៍បានទាំងអស់ មិនវៀរអារម្មណ៍ណាមួយឡើយ ព្រោះជាចិត្តរបស់ព្រះអរហន្ត ។

ចិត្តទាំង **៣១** ដួង ដូចបានពោលក្នុងគាថាសង្គហៈ ទី ១២ នេះ ជាចិត្តដែលទទួលអារម្មណ៍ច្រើនយ៉ាង ទើបហៅចិត្តដែលទទួលអារម្មណ៍នោះៗថា **ជាអនេកន្តះ** គឺ ទទួលអារម្មណ៍បាន មិនប្រាកដ ។

# អារម្មណ៍របស់ទ្វារវិមុត្តិចិត្ត

ក្នុងចំនួនចិត្តទាំងអស់នោះ ដោយច្រើនចាំបាច់ត្រូវអាស្រ័យទ្វារកើត ចិត្តដែលអាស្រ័យទ្វារកើតនេះ ហៅថា **ទ្វារិកចិត្ត** ។

ប៉ុន្តែនៅមានចិត្ត **១៩** ដួងទៀត ជាចិត្តដែលកើត ដោយមិនបាច់អាស្រ័យទ្វារណាឡើយ ចិត្ត ១៩ ដួងនោះ បានដល់ :

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត **២**
- មហាវិបាកចិត្ត **៨**
- មហគ្គតវិបាកចិត្ត **៩**

} **១៩** ដួង

ចិត្តទាំង **១៩** នេះ ខណៈធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច

ទាំង ៣ យ៉ាងនេះ សូម្បីមិនបាច់អាស្រ័យទ្វារណាមួយ ព្រោះកើតឡើងដោយអំណាចនៃកម្មអតីតដោយពិត យ៉ាងណាក៏ដោយ ប៉ុន្តែត្រូវទទួលអារម្មណ៍ណាមួយ ក្នុងបណ្តាអារម្មណ៍ ៦ ជានិច្ច ដែលអារម្មណ៍ទាំងនេះមិនបានទាក់ទង ក្នុងបច្ចុប្បន្នភពនេះទេ ជាអារម្មណ៍ដែលបានមកអំពីភពមុន ត្រង់មរណាសន្នជវនៈ ( ចិត្តដែលសេពអារម្មណ៍ កាលជិតនឹងស្លាប់ ) ស្រេចហើយតែការសេពអារម្មណ៍ កាលជិតនឹងស្លាប់នៃបុគ្គលនោះ តើបានទទួលអារម្មណ៍ណា ប្រសិនបើកាលជិតនឹងស្លាប់នោះ ទទួលរូបារម្មណ៍ **រូបារម្មណ៍នោះ** ក៏ជាអារម្មណ៍របស់ ទ្វារវិមុត្តិចិត្ត ឬក៏ កាលជិតនឹងស្លាប់នោះ មរណាសន្នជវនៈទទួល សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ធម្មារម្មណ៍ សទ្ទារម្មណ៍ជាដើមនោះ ក៏ជាអារម្មណ៍របស់ទ្វារវិមុត្តិចិត្ត ទើបពោលបានថា **អារម្មណ៍របស់ទ្វារវិមុត្តិចិត្ត** គឺ ជាអារម្មណ៍ណាមួយ ក្នុងបណ្តាអារម្មណ៍ទាំង ៦ នោះឯង ។

អារម្មណ៍របស់ទ្វារវិមុត្តិចិត្ត ដែលទាក់ទងជាមួយនឹងមរណាសន្នជវនៈនោះ មានឈ្មោះពិសេសហៅថា កម្មអារម្មណ៍ កម្មនិមិត្តអារម្មណ៍ និង គតិនិមិត្តអារម្មណ៍ គឺថាកាលបើអារម្មណ៍ ៦ ដែលមកប្រាកដដល់អ្នកដែលជិតស្លាប់នោះ ជា :

បញ្ចារម្មណ៍ គឺ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍

រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ណាមួយហើយ អារម្មណ៍នោះ ក៏ហៅថា **កម្មនិមិត្តអារម្មណ៍** ឬ **គតិនិមិត្តអារម្មណ៍** ស្រេចហើយតែសភាពរបស់អារម្មណ៍ដែលមកប្រាកដ ជានិមិត្តនោះ ។

-ចំណែកធម្មារម្មណ៍ ដែលមកប្រាកដក្នុងពេលជិតនឹងស្លាប់នោះ ហៅថា **កម្មអារម្មណ៍** ក៏មាន **កម្មនិមិត្តអារម្មណ៍** ក៏មាន **គតិនិមិត្តអារម្មណ៍** ក៏មាន ស្រេចហើយតែសភាពរបស់អារម្មណ៍ដែលមកប្រាកដនោះ ។

អារម្មណ៍របស់ទ្វារវិមុត្តិចិត្តនោះ ទើបបានដល់ **កម្មអារម្មណ៍ កម្មនិមិត្តអារម្មណ៍** ឬ **គតិនិមិត្តអារម្មណ៍** ជាអារម្មណ៍ ៦ ដែលមកប្រាកដដល់អ្នកដែលជិតនឹងស្លាប់ ។ ក្នុងមរណាសន្នជវនៈ អារម្មណ៍ នេះត្រូវប្រាកដដល់សត្វទូទៅ វៀរតែអសញ្ញសត្តព្រហ្ម និង ព្រះអរហន្ត ប៉ុណ្ណោះ ។

ចំណែកអារម្មណ៍ ៦ ដែលមកប្រាកដតាម ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត ក្នុងវេលាជាប្រក្រតីនោះ មិនហៅថា កម្មអារម្មណ៍ កម្មនិមិត្តអារម្មណ៍ ឬ គតិនិមិត្តអារម្មណ៍ទេ ឬ អារម្មណ៍ ៦ ដែលប្រាកដដល់ព្រះអរហន្ត ក្នុងកាលដែលជិតនឹងបរិនិព្វាននោះ ក៏មិនហៅថា កម្មអារម្មណ៍ កម្មនិមិត្តអារម្មណ៍ ឬ គតិនិមិត្តអារម្មណ៍ដែរ ព្រោះមិនមានការកើតបន្តក្នុងភពថ្មីទៀត ។

ឯចំណែកសត្វទាំងឡាយទាំងពួង ដែលនៅមានការកើត-ការស្លាប់ ត្រាច់រង្គាត់ក្នុងសង្សារវដ្តបន្តទៅទៀត (វៀរអសញ្ញសត្វព្រហ្ម) ចាំបាច់ត្រូវមាន កម្មអារម្មណ៍ កម្មនិមិត្តអារម្មណ៍ ឬ គតិនិមិត្ត-អារម្មណ៍ មកប្រាកដក្នុងកាលជិតស្លាប់ជានិច្ច ។

# កម្មអារម្មណ៍

**កម្មអារម្មណ៍** បានដល់ ធម្មារម្មណ៍ ជាកុសលកម្ម ឬ អកុសលកម្ម ដែលជាគរុកម្ម អាចិណ្ណកម្ម អាសន្នកម្ម ឬ កដត្តាកម្ម សឹងនឹងអាចបញ្ជូនផល ឲ្យបដិសន្ធិក្នុងភពខាងមុខ ដូចជាការសម្ដែងតួឲ្យច្បាស់ចំពោះមុខ ប្រាកដក្នុងមនោទ្វារ ឬ កុសល-កម្ម-អកុសលកម្ម ដែលឲ្យកើតបដិសន្ធិនោះ រមែងប្រាកដក្នុងផ្លូវចិត្ត ដោយអំណាច ធ្វើខ្លួនឲ្យដូចនឹងការកើតឡើងថ្មីៗ ព្រោះហេតុនោះហើយ ទើបការប្រាកដនៃកម្មអារម្មណ៍ មាន ២ យ៉ាង ។

១. **កម្មអារម្មណ៍** ដែលប្រាកដឡើងដោយកុសលកម្ម អកុសលកម្ម សម្ដែងតួឲ្យច្បាស់ “ **អភិមុខីភូតំ** ” ជាការប្រាកដឡើងដោយអំណាចនៃ “ **បុព្វេកតសញ្ញា** ” សញ្ញា គឺ សេចក្ដីចងចាំខាងក្នុងខ្លួន ដែលបានប្រព្រឹត្តហើយក្នុងកាលមុន ដូចខ្លួនធ្លាប់

មានបីតិ សោមនស្ស ក្នុងខណៈធ្វើបុណ្យ ឲ្យទាន រក្សាសីល ចម្រើនភាវនា កាល ១០-១៥ ឆ្នាំកន្លងហើយ លុះមកដល់ ឥឡូវនេះ ក៏នៅរលឹកនឹកចាំកុសល បីតិសោមនស្សនោះៗបាន ឬ ខ្លួនធ្លាប់ក្តៅក្រហាយចិត្តក្នុងខណៈដែលត្រូវភ្លើងឆេះ ត្រូវគេឆបោកកាលពី ១០-១៥ ឆ្នាំ មុនកន្លងហើយ ឬ ធ្លាប់ខឹងក្រោធ ចង្អៀតចង្អល់ចិត្តនឹងអ្នកណាមួយ ក្នុងកាលមុន ដល់ពេលជិតនឹងស្លាប់ ក៏ទាញមកនឹកចាំនូវសេចក្តីក្តៅក្រហាយ ឬ សេចក្តីក្រោធ សេចក្តីចង្អៀតចង្អល់នោះៗឡើងមកបាន ។

សេចក្តីនេះឧបមាដូចជាអ្នកធំ ចំណាស់ម្នាក់ លុះនឹកដល់វ័យកាលខ្លួននៅកំឡោះ ក្រមុំ មានសេចក្តីសប្បាយរីករាយយ៉ាងណា ក៏នៅរលឹក នឹកចាំសេចក្តីសប្បាយរីករាយក្នុងគ្រាអង្កាល់ណោះបាន ការប្រាកដនៃកម្មអារម្មណ៍តាម **បុព្វេកតសញ្ញា** ដែលជា **“អភិមុខីភូតំ”** ក៏យ៉ាងនោះដែរ ។

ចំណែកអ្នកជិតនឹងស្លាប់ នឹកចងចាំរឿងខាងក្រៅខ្លួន មានកិរិយាអាការៈ វត្ថុរបស់របរ គ្រឿងប្រដាប់ផ្សេងៗបាននោះ ទាំងនេះជា **កម្មនិមិត្តអារម្មណ៍** មិនមែនជា កម្មអារម្មណ៍ទេ ។

**២ . កម្មអារម្មណ៍** ដែលប្រាកដឡើងដោយកុសលកម្ម អកុសលកម្ម ធ្វើខ្លួនឲ្យដូចនឹងការកើតឡើងថ្មីៗ **“អភិនវករណេន”**

ជាការប្រាកដឡើងដោយអំណាចនៃ " **សម្បតិកតសញ្ញា** " សញ្ញា គឺ សេចក្តីចងចាំខាងក្នុងខ្លួន ប្រព្រឹត្តទៅប្រហែលគ្នានឹងថា កំពុងធ្វើក្នុងពេលឥឡូវនេះ ដូចខ្លួនធ្លាប់មានបីតិសោមនស្សក្នុងខណៈធ្វើបុណ្យឲ្យទាន រក្សាសីល ចំរើនភាវនា ឬធ្លាប់ក្តៅក្រហាយចិត្ត ក្នុងខណៈដែលត្រូវភ្លើងឆេះ ត្រូវគេឆបោក ឬ ធ្លាប់ខឹងក្រោធចង្អៀតចង្អល់នឹងនរណាមួយ ក្នុងកាលមុនកន្លងច្រើនខែឆ្នាំមកហើយ លុះដល់ពេលជិតនឹងស្លាប់ បីតិសោមនស្សបានកើតឡើងប្រហែលគ្នានឹងថា ខ្លួនកំពុងទៅធ្វើបុណ្យ ឲ្យទាន រក្សាសីល ចម្រើចភាវនា ឬ សេចក្តីក្តៅក្រហាយចិត្ត បានកើតឡើងប្រហែលគ្នានឹងថា ខ្លួនកំពុងត្រូវភ្លើងឆេះ ត្រូវគេឆបោក ឬ សេចក្តីក្រោធ សេចក្តីចង្អៀតចង្អល់បានកើតឡើង ប្រហែលគ្នានឹងថា ខ្លួនកំពុងវាយតប់ ឈ្លោះប្រកែកនឹងអ្នកណាម្នាក់ ។

សេចក្តីនេះ ឧបមាដូចជាសេចក្តី សប្បាយរីករាយមួយ ដែលកើតឡើងក្នុងចិត្តរបស់បុគ្គល ដែលកំពុងដេកលក់ក្នុងកណ្តាលអធ្រាត្រយល់សប្តិ ព្រោះអាស្រ័យសេចក្តីសប្បាយរីករាយ បានមកពីការទៅមើលកុន ល្ខោន ឬ កីឡាកាលពីថ្ងៃរសៀលមុិញអុីចឹង ។

កម្មអារម្មណ៍ដែលបានពោលមកហើយនេះ ប្រាកដបានចំពោះតែតាម **មនោទ្វារ** ប៉ុណ្ណោះ មិនអាចប្រាកដតាម បញ្ចទ្វារទេ ។

កម្មអារម្មណ៍នេះ តែងនឹកគិតនូវអំពើដែលកន្លងទៅហើយ ជា **អតីតអារម្មណ៍** ។

-បើកម្មអារម្មណ៍ ជាកុសល រមែងនាំទៅកាន់សុគតិ ។

-បើកម្មអារម្មណ៍ ជាអកុសល រមែងនាំទៅកាន់ទុគ្គតិ ។

# កម្មនិមិត្តអារម្មណ៍

**កម្មនិមិត្តអារម្មណ៍** សំដៅយកអារម្មណ៍ដែលជាហេតុនៃការប្រព្រឹត្តិធ្វើ ។

**កម្មស្ស និមិត្តំ = កម្មនិមិត្តំ**

ប្រែថា : អារម្មណ៍ដែលជាហេតុនៃការប្រព្រឹត្តិធ្វើ ឈ្មោះថា **កម្មនិមិត្តអារម្មណ៍** ។

**កម្មនិមិត្តអារម្មណ៍** បានដល់ អារម្មណ៍ ៦ គឺ រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ដែលដឹងបានតាមផ្លូវចិត្ត គឺបំណងយកតែអារម្មណ៍ ៦ ដែលទាក់ទងជាមួយនឹងការប្រព្រឹត្តិធ្វើ នៃបុគ្គលម្នាក់ៗ ដែលខ្លួនបានប្រព្រឹត្តដោយ កាយ វាចា ចិត្ត ប៉ុណ្ណោះ ។

អារម្មណ៍ ៦ ដែលទាក់ទិនជាមួយនឹងការប្រព្រឹត្តិធ្វើរបស់ខ្លួន

ដែលជា កម្មនិមិត្តបាននោះ មាន ២ យ៉ាង គឺ :

**១. ឧបលទ្ធកម្មនិមិត្ត** បានដល់ អារម្មណ៍ ៦ ដែលខ្លួនបានប្រសព្វឃើញ ជាប្រធានក្នុងខណៈប្រព្រឹត្តធ្វើ ។

**២. ឧបករណកម្មនិមិត្ត** បានដល់ អារម្មណ៍ ៦ ដែលខ្លួនបានប្រសព្វឃើញ តែមិនមែនជាប្រធានទេ គ្រាន់តែជាគ្រឿងប្រកបជំនួយក្នុង :

**ក. ផ្នែកកុសល**

- **ទានកុសល** ចិញ្ចឹមភិក្ខុ ដាក់បាត្រ ធ្វើកឋិនទាន សាងសាលាសិក្សា ។

អារម្មណ៍ដែលជាប្រធាន គឺភិក្ខុសាមណេរ អាហារភោជន ត្រៃចីវរ វិហារ អាគារសិក្សា ទាំងអស់នេះ ឈ្មោះថា **ឧបលទ្ធ-កម្មនិមិត្ត** ។

ចំពោះអារម្មណ៍ ដែលជាចំណែកប្រកប ឧបត្ថម្ភឲ្យសម្រេចជាទានកុសលផ្សេងៗនោះ គឺព្រះពុទ្ធរូប ផ្កាភ្ញី ធូប ទៀន ចាន កន្ទេល តុកៅអី ផ្ដិល ថាស យានយន្ត និង អ្នកជួយបម្រើ ទាំងអស់នេះ ឈ្មោះថា **ឧបករណកម្មនិមិត្ត** ។

**- សីលកុសល** ភិក្ខុសាមណេរអ្នកឲ្យសីល ពាក្យឲ្យសីល ការពោលវាចាទទួលសីល ជា **ឧបលទ្ធកម្មនិមិត្ត** គ្រឿងទេយ្យធម៌ ដែលយកទៅបូជា និងបុគ្គលដែលរួមជាមួយនោះ ជា **ឧបករណ-កម្មនិមិត្ត** ។

**- ភាវនាកុសល** បើជាការចម្រើនសមថភាវនា អារម្មណ៍កម្មដ្ឋានផ្សេងៗមានកសិណជាដើម រហូតដល់ឧគ្គហនិមិត្ត បដិភាគ-និមិត្ត អប្បនាឈាន និងគ្រូអាចារ្យជា **ឧបលទ្ធកម្មនិមិត្ត** ។

បើជាការចម្រើនវិបស្សនាភាវនា រូបធម៌ នាមធម៌ ខន្ធ ៥ សតិសម្បជញ្ញៈ គ្រូអាចារ្យ ជាឧបលទ្ធកម្មនិមិត្ត ។

ទីកន្លែង គ្រឿងប្រើប្រាស់ ដែលជាប់ទាក់ទិននឹងការចម្រើនវិបស្សនា ឈ្មោះថា **ឧបករណកម្មនិមិត្ត** ។

ម្យ៉ាងទៀត ការសិក្សារៀនសូត្រព្រះធម៌ ច្បាប់តម្រា ព្រះត្រៃ-បិដក គ្រូអាចារ្យ ការសូត្រទន្ទេញ ជា **ឧបលទ្ធកម្មនិមិត្ត** ។

សាលារៀន ទីកន្លែង អ្នកសិក្សា ក្ដារខៀន ប្រដាប់សរសេរ ជា **ឧបករណកម្មនិមិត្ត** ។

## ខ. ផ្នែកអកុសល

- **បាណាតិបាត** សត្វដែលត្រូវស្លាប់ កិរិយាអាការដែលប្រព្រឹត្តធ្វើ ជាប្រធានក្នុងការសម្លាប់ ឈ្មោះថា **ឧបលទ្ធកម្មនិមិត្ត**

ស្ថានទីសម្លាប់ គ្រឿងអាវុធប្រើប្រាស់ក្នុងការសម្លាប់ ដូចជា សាច់ ស្បែក ឆ្អឹង រោម ជាដើម ជាចំណែកប្រកប ឈ្មោះថា **ឧបករណកម្មនិមិត្ត** ។

- **អទិន្នាទាន** ទ្រព្យរបស់របរដែលលួចប្លន់ កិរិយាអាការលួច ប្លន់ ជា **ឧបលទ្ធកម្មនិមិត្ត** ។

ទីកន្លែង គ្រឿងប្រដាប់ប្រដា ប្រើប្រាស់ ក្នុងការលួចប្លន់ ជា **ឧបករណកម្មនិមិត្ត** ។

- **កាមេសុមិច្ឆាចារ** បុគ្គលដែលខ្លួនរំលោភល្មើស និងកិរិយា អាការរបស់ខ្លួន ជា **ឧបលទ្ធកម្មនិមិត្ត** ។

ទីកន្លែង សំដី វាចា ល្បួង លួងលោម គំរាមកំហែង ជា **ឧបករណកម្មនិមិត្ត** ។

- **មុសាវាទ** ពាក្យសំដីមិនពិត ឬ វត្ថុដែលមិនពិត ជា **ឧបលទ្ធកម្មនិមិត្ត** ។

បុគ្គលអ្នកស្តាប់ ជា **ឧបករណកម្មនិមិត្ត** ។

- **សុរាមេរ័យ** ស្រា បៀរ មេរ័យ អាការស្រវឹង ជា **ឧបលទ្ធកម្មនិមិត្ត** ។

ដប កំប៉ុង គ្រឿងក្លែម ពួកម៉ាក ពួកភៀន ភាជន៍ ទីកន្លែង និងប្រដាប់ប្រដាផ្សេងៗ ជា **ឧបករណកម្មនិមិត្ត** ។

រួមសេចក្តីមក **ឧបលទ្ធកម្មនិមិត្ត** និង **ឧបករណកម្ម-និមិត្ត** ទាំង ២ យ៉ាងនេះ បណ្តាវត្ថុមានជីវិតក្តី មិនមានជីវិតក្តី ដែលជាប់ទាក់ទងនឹងការប្រព្រឹត្តធ្វើល្អក្តី អាក្រក់ក្តី ជា **ឧបលទ្ធ-កម្មនិមិត្ត** ឯវត្ថុដទៃៗទៀតដែលជាគ្រឿងប្រកបជំនួយ ក្នុងការធ្វើល្អ ធ្វើអាក្រក់ ទាំងនោះ ជា **ឧបករណកម្មនិមិត្ត** ។

កាលបើជិតនឹងស្លាប់ កម្មនិមិត្ត ណាមួយជាគ្រឿងសំគាល់មកប្រាកដចំពោះមុខ មានអារម្មណ៍ជាផ្នែកកុសលហើយ ក៏នឹងនាំទៅកាន់សុគតិ ប៉ុន្តែបើ កម្មនិមិត្តអារម្មណ៍ ទាំងនោះជាផ្នែកអកុសលហើយ រមែងនាំទៅកាន់ទុគ្គតិ ។

# គតិនិមិត្តអារម្មណ៍

**គតិនិមិត្តអារម្មណ៍** សំដៅយកអារម្មណ៍នៃភពជាតិ ដែលគប្បីនឹងទៅ គឺ អារម្មណ៍ដែលនឹងបានសោយក្នុងភពបន្ទាប់ពីស្លាប់

ទៅ ។

**គតិយា និមិត្តំ = គតិនិមិត្តំ**

ប្រែថា : អារម្មណ៍របស់ភពជាតិ ដែលគប្បីទៅ ឈ្មោះថា **គតិនិមិត្ត** ។

**គតិនិមិត្តនេះ** បានដល់ អារម្មណ៍ ៦ ប៉ុន្តែអារម្មណ៍ ៦ ដែលជា គតិនិមិត្តនេះ មិនមែនជាអារម្មណ៍ទាក់ទងនឹងភពជាតិនេះទេ គឺ ជាអារម្មណ៍ ៦ ដែលគប្បីនឹងបានជួប បានឃើញ បានសោយ ក្នុងភពមុខប៉ុណ្ណោះ ។

គតិនិមិត្តអារម្មណ៍នេះ មាន ២ យ៉ាង គឺ ឧបលភិតព្វ-គតិនិមិត្ត ១ និង ឧបភោគគតិនិមិត្ត ១ ។

**១. ឧបលភិតព្វគតិនិមិត្ត** គឺ ជាអារម្មណ៍ ៦ របស់ភពជាតិ ដែលនឹងគប្បីឃើញ ។

**២. ឧបភោគគតិនិមិត្ត** គឺ ជាអារម្មណ៍ ៦ របស់ភពជាតិ ដែលនឹងគប្បីសោយ ។

- **ចំពោះអ្នកដែលនឹងទៅកើតក្នុងព្រហ្មលោក** គតិនិមិត្តទាំង ២ នេះ រមែងមិនមាន គឺ មានតែ បញ្ញត្តិកម្មនិមិត្ត ឬ

មហគ្គតកម្មនិមិត្ត ប៉ុណ្ណោះ ។

- **ចំពោះអ្នកដែលនឹងទៅកើតទេវលោក** បើឃើញ រាជរថ វិមាន ទេវបុត្ត ទេពធីតា គ្រឿងប្រដាប់ សួនឧទ្យាន ស្រះទឹក ទាំងនេះ ចាត់ជា **ឧបលភិតព្វគតិនិមិត្ត** ។ ប៉ុន្តែបើដឹងខ្លួនថា ខ្លួនបានអង្គុយលើរាជរថក្តី កំពុងដើរទៅក្នុងទីកន្លែងផ្សេងៗ យ៉ាងសប្បាយក្តី បានបរិភោគអាហារភោជន រួមនឹងទេវបុត្ត ទេពធីតាក្តី ទ្រទ្រង់នូវគ្រឿងអាភរណៈក្តី ទាំងនេះ ចាត់ជា **ឧប-ភោគគតិនិមិត្ត** ។

- **ចំពោះអ្នកដែលនឹងទៅកើតជាមនុស្ស** បើបានឃើញ គភ៌មាតា ឃើញភូមិ-ស្រុកពួកមនុស្ស យានជំនិះ និង គ្រឿងប្រើ-ប្រាស់ក្នុងភូមិក្នុងស្រុក ទាំងនេះ ចាត់ជា **ឧបលភិតព្វគតិនិមិត្ត**។ ប៉ុន្តែបើដឹងខ្លួនថា ខ្លួនកំពុងនៅទីនោះកំពុងសន្ទនា ប្រាស្រ័យនឹងនរណាម្នាក់ ប្រកបការងារណាមួយក្តី ឬហាក់ដូចជាខ្លួនបានចាប់ បដិសន្ធិក្នុងគភ៌ក្តី យ៉ាងនេះ ចាត់ជា **ឧបភោគគតិនិមិត្ត** ។

- **ចំពោះអ្នកដែលនឹងទៅកើតជាសត្វតិរច្ឆាន** បើ ឃើញសត្វផ្សេង ៗ ដូចជា ឆ្កែ ឆ្មា មាន់ ទា បក្សី ដំរី សេះ គោ

ក្របីជាដើម ឬទីកន្លែងដែលពួកសត្វទាំងនោះ អាស្រ័យនៅ ដូចជា ជ្រោះ ត្រពាំង បឹង ព្រៃក ក្រោល ទ្រុង គុម្ពោត ព្រៃឈើជាដើម ជា **ឧបលភិតព្វគតិនិមិត្ត** ។ បើដឹងខ្លួនថា ខ្លួនជាសត្វតិរច្ឆាន ពួកណាមួយ ឬកំពុងតែប្រឡែងលេងជាមួយនឹងសត្វ ទាំងនោះ ជា **ឧបភោគគតិនិមិត្ត** ។

- **ចំពោះអ្នកដែលនឹងទៅកើតជាប្រេត និងអសុរកាយ** បើឃើញ ព្រៃ ជ្រោះ ទន្លេ ភ្នំ ដែលស្ងាត់ជ្រងំគួរឲ្យខ្លាចស្រៀវសាច់ ឃើញ ប្រេត អសុរកាយ ទាំងនេះ ជា **ឧបលភិតព្វគតិនិមិត្ត** ។ បើដឹងខ្លួនថា ខ្លួនកំពុងដើរក្នុងទីទាំងនោះក្តី ដឹងខ្លួនថា រាងកាយរបស់ខ្លួនគួរខ្ពើម គួរខ្លាច ឬ កំពុងស្រេកឃ្លាន កំពុងរកទឹក រកអាហារក្តី ទាំងនេះ ជា **ឧបភោគគតិនិមិត្ត** ។

- **ចំពោះអ្នកដែលនឹងទៅកើតក្នុងនរក** បើឃើញគ្រឿងប្រហារ ឆ្កែ ត្មាត ក្អែក យមរាជ យមបាល សត្វនរក និង ស្ថានទីនៅរបស់សត្វ ទាំងនោះ ជា **ឧបលភិតព្វគតិនិមិត្ត** ។ បើដឹងខ្លួនថា ខ្លួនកំពុងត្រូវគេអូសកញ្ឆក់ ត្រូវគេវាយតប់ ត្រូវឆ្កែខាំ ត្រូវត្មាតចឹក ត្រូវគេចងក្រៀកក្តី ដឹងខ្លួនថា រាងកាយរបស់ខ្លួនឈឺចុកចាប់ ក្រំស្គមស្គាំងក្តី ទាំងនេះ ជា **ឧបភោគគតិនិមិត្ត** ។

បណ្ដាទ្វារណាមួយក្នុងទ្វារទាំង ៦ ការប្រាកដនៃនិមិត្តទាំង ៣ នេះ រមែងប្រាកដតាមទ្វារ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ណាមួយ ពោលគឺ :

-និមិត្តដែលជា **កម្មអារម្មណ៍** នឹងប្រាកដតាម **មនោទ្វារ** ។

-និមិត្តដែលជា **កម្មនិមិត្តអារម្មណ៍** និង **គតិនិមិត្ត-អារម្មណ៍** ទាំង ២ យ៉ាងនេះ ត្រូវសម្រេចតាមសភាពនៃនិមិត្តនោះៗ បើជា **បច្ចុប្បន្នរូបារម្មណ៍** ក៏ប្រាកដតាម **ចក្ខុទ្វារ** និង **មនោទ្វារ** , បើជា **អតីតរូបារម្មណ៍** ក៏ប្រាកដបានតាម **មនោទ្វារ** តែម្យ៉ាង ។

សទ្ទាអារម្មណ៍ គន្ធាអារម្មណ៍ រសាអារម្មណ៍ និង ផោដ្ឋព្វា-អារម្មណ៍ ក៏ប្រាកដមានទំនងដូចគ្នាអ៊ីចឹងដែរ ។ ប៉ុន្តែចំពោះ **និមិត្តធម្មារម្មណ៍** រមែងប្រាកដតែតាម **មនោទ្វារ** ប៉ុណ្ណោះ ។

ម្យ៉ាងទៀត **គតិនិមិត្តអារម្មណ៍** នោះ សូម្បីជាអារម្មណ៍ទាំង ៦ ក៏ពិតមែន ប៉ុន្តែចំណែកច្រើនដែលប្រាកដ រមែងជា **រូបារម្មណ៍** និង **បញ្ញត្តិអារម្មណ៍** ដែលទាក់ទិនជាមួយនឹងរូបារម្មណ៍នោះៗ ។ ដូច្នេះ ក្នុងបណ្ដាទ្វារទាំង ៦ នេះ **គតិនិមិត្ត-**

**អារម្មណ៍** រមែងប្រាកដតាម **ចក្ខុទ្វារ** និង **មនោទ្វារ** ដោយច្រើន ។

បន្តពីអារម្មណ៍ដែលមាន កម្ម កម្មនិមិត្ត គតិនិមិត្ត ទាំងនោះមកប្រាកដហើយ អាស្រ័យដោយអារម្មណ៍ ដែលមកប្រាកដតាមអាការនោះៗឯង ក្រសែចិត្តបរិសុទ្ធក្តី ឬសៅហ្មងក្តី គឺស្រេចតែកម្មដែលនឹងបញ្ជូនផល ។

កាលបើកម្ម ដែលនឹងបញ្ជូនផលបដិសន្ធិក្នុងភពជាតិ ខាងមុខជាកុសលហើយ និមិត្តទាំង ៣ ក៏ជានិមិត្តល្អ , កាលបើនិមិត្តល្អហើយ ក្រសែចិត្តដែលជាប់នៅក្នុងនិមិត្ត នោះក៏ផ្លូវផង់ថ្លាបរិសុទ្ធ សូម្បីរាងកាយត្រូវបៀតបៀនដោយ រោគភ័យចុកចាប់ យ៉ាងណា ឬមានគេនិយាយរឿងរ៉ាវអាក្រក់ មានការដណ្តើមទ្រព្យសម្បត្តិ ប្រកាប់ប្រចាក់គ្នានិងគ្នា យ៉ាងណាក៏ដោយ ចិត្តសន្តានរបស់អ្នកជិតស្លាប់នោះ គ្រាន់តែសៅហ្មងមួយជួរខណៈៗប៉ុណ្ណោះ រួចហើយក៏ត្រឡប់ថ្លាផ្លូវផង់ដូចដើមវិញ ។ ដូច្នេះវេលាជិតនឹងស្លាប់ ក្រសែចិត្តថ្លាផ្លូវផង់ បរិសុទ្ធកើតឡើងជារឿយៗ ។

កាលបើកម្ម ដែលនឹងបញ្ជូនផលបដិសន្ធិក្នុងភពជាតិ ខាងមុខជាអកុសលហើយ និមិត្តទាំង ៣ ក៏ជានិមិត្តមិនល្អ កាលបើនិមិត្តមិនល្អហើយ ក្រសែចិត្តដែលជាប់នៅក្នុង និមិត្តនោះ ក៏សៅហ្មងមិន

ផ្លូវផង់ សូម្បីរាងកាយមិនមានរោគភ័យ ចុកចាប់យ៉ាងណា ក៏ដោយ ទាំងកូនចៅ ញាតិ អ្នកផងមកប្រតិបត្តិផ្គាប់ផ្គុនល្អ មិនបាននិយាយរឿងអាក្រក់ឲ្យរំខាន មានតែនិយាយគ្នានូវរឿងល្អៗយ៉ាងណាក៏ដោយ គ្រាន់តែធ្វើឲ្យចិត្ត បន្ថយពីសេចក្តីសៅហ្មងបានមួយជួរខណៈ ។ ប៉ុណ្ណោះ ក្រសែចិត្តដទៃៗក្រៅពីនោះ ក៏ត្រឡប់ជាកង្វល់សៅហ្មងដូចដើមវិញ ។

ដូច្នេះក្រសែចិត្តដែលកើតឡើងជារឿយៗ ដោយសេចក្តីសៅហ្មង ឬដោយបរិសុទ្ធនោះ បានចំពោះតែអ្នកដែលស្លាប់ដោយជម្ងឺឈឺចុកចាប់ច្រើនអស់វេលាយូរៗ ច្រើននាទី ច្រើនម៉ោង ច្រើនថ្ងៃ ក៏ប៉ុន្តែ វៀរចំពោះអ្នកស្លាប់ដោយ ទាន់ហាន់មិនដឹងខ្លួន ដូចជាស្លាប់ដោយផ្ទុះគ្រាប់បែកជាដើម ។

ចំណែក ព្រះអរហន្ត កាលជិតនឹងបរិនិព្វាននោះ សូម្បីថាចិត្តនឹងមានអារម្មណ៍ជាលោកិយ លោកុត្តរ ឬ បញ្ញត្តិក៏ដោយ ក្រសែចិត្តកាលជិតនឹងបរិនិព្វាននោះ រមែងបង្អោនទៅក្នុងព្រះនិព្វានតែម្យ៉ាង ដូចគ្នាគ្រប់ៗអង្គ សេចក្តីដែលពោលយ៉ាងនេះ ក៏ព្រោះ លោកមិនមានភពជាតិដែលនឹងត្រូវកើតតទៅទៀត ។

ចំពោះ កម្ម កម្មនិមិត្ត គតិនិមិត្តអារម្មណ៍ ដែលជា បច្ចុប្បន្ន

អតីត និង បញ្ញត្តិ នោះ អធិប្បាយថា បើអារម្មណ៍របស់មរណា-សន្នជវនៈ ជានិប្ផន្នរូប មានរូបារម្មណ៍ជាដើមនោះ វេលាដែលចុតិចិត្តរលត់ហើយ អារម្មណ៍នោះនៅមិនទាន់រលត់ទេ កាលបើយ៉ាងនេះ បដិសន្ធិចិត្ត និង ភវង្គចិត្ត ច្រើនបំផុត ៦ ដួង ដែលកើតក្នុងភពថ្មីនោះ ក៏មានអារម្មណ៍ជាបច្ចុប្បន្ន ។ ចំណែកភវង្គចិត្តដែលកើតបន្តពីនោះមក រហូតដល់ចុតិចិត្តនោះ មានអារម្មណ៍បច្ចុប្បន្នមិនបាន ។

បើ និប្ផន្នរូបារម្មណ៍ ដែលបានពោលហើយនោះ រលត់ព្រមនឹងចុតិចិត្តក្តី ឬ អារម្មណ៍របស់មរណាសន្នជវននោះ ជាធម្មារម្មណ៍ជា ចិត្ត-ចេតសិកក្តី យ៉ាងនេះ បដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្តក្នុងភពថ្មី រមែងមានអារម្មណ៍ជាអតីត ។

ចំណែក បដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្ត របស់កាមបុគ្គលដែលកើតក្នុងកាមភូមិនោះ មានកាលវិមុត្តិអារម្មណ៍ គឺបញ្ញត្តិមិនបាន ព្រោះឧបេក្ខាមនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ២ មហាវិបាកចិត្ត ៨ ទាំងនេះមានអារម្មណ៍ ៦ ដែលជាកាមារម្មណ៍តែម្យ៉ាង ។ ដូច្នេះ អារម្មណ៍របស់ បដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្តរបស់កាមបុគ្គល ទើបជាអារម្មណ៍ដែលជាបច្ចុប្បន្ន ឬអតីតយ៉ាងណាមួយប៉ុណ្ណោះ ។

បើអារម្មណ៍របស់មរណាសន្នជវន ជាបញ្ញត្តិធម្មារម្មណ៍ គឺបញ្ញត្តិដែលទាក់ទងនឹងកម្មដ្ឋាន មានកសិណបញ្ញត្តិ ជាដើមយ៉ាងនេះ ហើយ បដិសន្ធិចិត្ត ភវង្គចិត្ត ចុតិចិត្តក្នុងភពថ្មី រមែងមានអារម្មណ៍

ជាកាលវិមុត្តិអារម្មណ៍ គឺ បញ្ញត្តិនោះឯង ។

អារម្មណ៍របស់ទ្វារវិមុត្តិចិត្តទាំងនេះ ជាអនាគតអារម្មណ៍នោះ តែងមានមិនបាន ព្រោះការទទួលអារម្មណ៍របស់ទ្វារវិមុត្តិចិត្តនេះ ទទួលអារម្មណ៍ ដែលមរណាសន្នជវនទទួលយកមកពីភពមុន កាល ជិតនឹងស្លាប់នោះឯង ៕

# អារម្មណ៍ពិស្តារ ២១

តាមដែលបានសម្តែងប្រភេទអារម្មណ៍ផ្សេងៗ រួចមកហើយ មានអារម្មណ៍ ៦ បានដល់ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ ហើយនិងប្រភេទ អារម្មណ៍ ៤ ដែលមានកាមអារម្មណ៍ មហគ្គតអារម្មណ៍ បញ្ញត្តិ-អារម្មណ៍ និងលោកុត្តរអារម្មណ៍ ។ ដោយហេតុសភាវៈរបស់ អារម្មណ៍នោះ ប្រព្រឹត្តទៅយ៉ាងទូលំទូលាយ និងមានឈ្មោះហៅបាន ច្រើនយ៉ាង ផ្សេងៗគ្នា ដោយន័យទេសនា ដូច្នេះបើរួបរួមនូវប្រភេទ នៃអារម្មណ៍ផ្សេងៗទាំងនោះ ដោយពិស្តារហើយ ក៏មានអារម្មណ៍ ២១ យ៉ាង គឺ :

# សម្តែងអារម្មណ៍ពិស្តារ ២១ ប្រភេទ

**១. កាមអារម្មណ៍** បានដល់ កាមាវចរចិត្ត ៥៤ ចេតសិក ៥២ រូប ២៨ បានជា អារម្មណ៍ ៦ ។

**២. មហគ្គតអារម្មណ៍** បានដល់ មហគ្គតចិត្ត ២៧ ចេតសិក ៣៥ បានជា អារម្មណ៍ ១ គឺ ធម្មារម្មណ៍ ។

**៣. និព្វានអារម្មណ៍** បានដល់ និព្វាន បានជា អារម្មណ៍ ១ គឺ ធម្មារម្មណ៍ ។

**៤. នាមអារម្មណ៍** បានដល់ ចិត្ត ៨៩ ចេតសិក ៥២ និព្វាន ១ បានជា អារម្មណ៍ ១ គឺ ធម្មារម្មណ៍ ។

**៥. រូបអារម្មណ៍** បានដល់ រូប ២៨ បានជា អារម្មណ៍ ៦ ។

**៦. អតីតអារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលរលត់ហើយ បានជា អារម្មណ៍ ៦ ។

**៧. អនាគតអារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលនឹងកើត បានជា អារម្មណ៍ ៦ ។

**៨. បច្ចុប្បន្នអារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលកំពុងកើតឡើង បានជា អារម្មណ៍ ៦ ។

**៩. កាលវិមុត្តិអារម្មណ៍** បានដល់ និព្វាន បញ្ញត្តិ បានជា អារម្មណ៍ ១ គឺ ធម្មារម្មណ៍ ។

**១០. បញ្ញត្តិអារម្មណ៍** បានដល់ អត្ថប្បញ្ញត្តិ សទ្ទប្បញ្ញត្តិ បានជា អារម្មណ៍ ១ គឺ ធម្មារម្មណ៍ ។

**១១. បរមត្ថអារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប និព្វាន បានជា អារម្មណ៍ ៦ ។

**១២. អជ្ឈត្តអារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលកើតឡើងខាងក្នុងខ្លួនឯង បានជា អារម្មណ៍ ៦ ។

**១៣. ពហិទ្ធអារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលកើតឡើងក្នុងអ្នកដទៃ និងរូបដែលមិនមានជីវិត រួមទាំងនិព្វាន បញ្ញត្តិ បានជា អារម្មណ៍ ៦ ។

**១៤.អជ្ឈត្តពហិទ្ធារម្មណ៍** បានដល់ ចិត្ត ចេតសិក រូប ដែលកើតឡើងខាងក្នុងខ្លួន និងខាងក្រៅខ្លួន បានជា អារម្មណ៍ ៦ ។

**១៥. បញ្ញារម្មណ៍** បានដល់ វិសយរូប ៧ បានជា អារម្មណ៍ ៥ ។

**១៦. រូបារម្មណ៍** បានដល់ វណ្ណរូប គឺ ពណ៌ផ្សេងៗ ។

**១៧. សទ្ទារម្មណ៍** បានដល់ សទ្ទរូប គឺ សម្លេងផ្សេងៗ ។

**១៨. គន្ធារម្មណ៍** បានដល់ គន្ធរូប គឺ ក្លិនផ្សេងៗ ។

**១៩. រសារម្មណ៍** បានដល់ រសរូប គឺ រសផ្សេងៗ ។

**២០. ផោដ្ឋព្វារម្មណ៍** បានដល់ រឹង-ទន់ ក្តៅ-ត្រជាក់ តឹង-ញ័រ ។

**២១. ធម្មារម្មណ៍** បានដល់ ចិត្ត ចេតសិក បសាទរូប ៥ សុខុមរូប ១៦ និព្វាន បញ្ញត្តិ ៕

# ការចែកចិត្តដែលទទួលអារម្មណ៍ ដោយឯកន្តៈ និង អនេកន្តៈ

## ១. កាមអារម្មណ៍

**ក.** ចិត្តដែលទទួលកាមអារម្មណ៍បាន មាន ៥៦ ដួង គឺ :

+ **ឯកន្តៈ** មាន **២៥** ដួង បានដល់ :

- ទ្វិបញ្ចវិញ្ញាណចិត្ត **១០** ដួង
- មនោធាតុ **៣** ដួង
- មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត **៣** ដួង
- ហសិតុប្បាទចិត្ត **១** ដួង
- មហាវិបាកចិត្ត **៨** ដួង

+ **អនេកន្តៈ** មាន **៣១** ដួង បានដល់ :

- អកុសលចិត្ត **១២** ដួង
- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត **១** ដួង
- មហាកុសលចិត្ត **៨** ដួង

- មហាកិរិយាចិត្ត ៨ ដួង
- អភិញ្ញាចិត្ត ២ ដួង

**ខ.** ចិត្តដែលទទួលកាមារម្មណ៍មិនបានមាន **៣៥** ដួង គឺ :

- មហគ្គតចិត្ត **២៧** ដួង
- លោកុត្តរចិត្ត ៨ ដួង

## ២. មហគ្គតអារម្មណ៍

**ក.** ចិត្តដែលទទួលមហគ្គតអារម្មណ៍បាន មាន **៣៧** ដួង គឺ :

\+ **ឯកន្តៈ** មាន **៦** ដួង បានដល់ :

- វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣ ដួង
- នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣ ដួង

\+ **អនេកន្តៈ** មាន **៣១** ដួង បានដល់ :

- អកុសលចិត្ត **១២** ដួង
- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១ ដួង
- មហាកុសលចិត្ត ៨ ដួង

- មហាកិរិយាចិត្ត ៨ ដួង
- អភិញ្ញាចិត្ត ២ ដួង

**ខ.** ចិត្តដែលទទួលមហគ្គតអារម្មណ៍មិនបាន មាន **៥៤** ដួង គឺ :

- អហេតុកចិត្ត **១៧** ដួង

(វៀរឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១)

- មហាវិបាកចិត្ត ៨ ដួង
- រូបាវចរចិត្ត **១៥** ដួង
- អាកាសានញ្ចាយតនជ្ឈានចិត្ត ៣ ដួង
- អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣ ដួង
- លោកុត្តរចិត្ត ៨ ដួង

## ៣. និព្វានអារម្មណ៍

**ក.** ចិត្តដែលទទួលនិព្វានអារម្មណ៍បាន មាន **១៩** ដួង គឺ :

**+ ឯកន្តៈ** មាន **៨** ដួង បានដល់ :

- លោកុត្តរចិត្ត ៨ ដួង

+ **អនេកន្តៈ** មាន **១១** ដួង បានដល់ :

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត **១** ដួង
- មហាកុសលញាណសម្បយុត្តចិត្ត **៤** ដួង
- មហាកិរិយាញាណសម្បយុត្តចិត្ត **៤** ដួង
- អភិញ្ញាចិត្ត **២** ដួង

**ខ.** ចិត្តដែលទទួលនិព្វានអារម្មណ៍មិនបាន មាន **៧២** ដួង គឺ :

- កុសលចិត្ត **១២** ដួង
- ហេតុកចិត្ត **១៧** ដួង

( វៀរឧបេក្ខាមនោវិញ្ញាធាតុអហេតុកកិរិយាចិត្ត ១ )

- មហាកុសលញាណវិប្បយុត្តចិត្ត **៤** ដួង
- មហាកិរិយាញាណវិប្បយុត្តចិត្ត **៤** ដួង
- មហាវិបាកចិត្ត **៨** ដួង
- មហគ្គតចិត្ត **២៧** ដួង

# ៤. នាមអារម្មណ៍

**ក.** ចិត្តដែលទទួលនាមអារម្មណ៍បាន មាន **៥៧** ដួង គឺ :

**+ ឯកន្តៈ** មាន **១៤** ដួង បានដល់ :

- វិញ្ញាណញ្ចាយតនជ្ឈានចិត្ត **៣** ដួង
- នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត **៣** ដួង
- លោកុត្តរចិត្ត **៨** ដួង

**+ អនេកន្តៈ** មាន **៤៣** ដួង បានដល់ :

- កាមាវចរចិត្ត **៤១** ដួង

( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ )

- អភិញ្ញាចិត្ត **២** ដួង

**ខ.** ចិត្តដែលទទួលនាមអារម្មណ៍មិនបាន មាន **៣៤** ដួង គឺ :

- ទ្វិបញ្ចវិញ្ញាណចិត្ត **១០** ដួង
- មនោធាតុ **៣** ដួង
- រូបាវចរចិត្ត **១៥** ដួង
- អាកាសានញ្ចាយតនជ្ឈានចិត្ត **៣** ដួង

- អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣ ដួង

# ៥. រូបអារម្មណ៍

**ក.** ចិត្តដែលទទួល រូបអារម្មណ៍បាន មាន **៥៦** ដួង គឺ :

**+ ឯកន្តៈ** មាន **១៣** ដួង បានដល់ :

- ទ្វិបញ្ចវិញ្ញាណចិត្ត **១០** ដួង
- មនោធាតុ **៣** ដួង

**+ អនេកន្តៈ** មាន **៤៣** ដួង បានដល់ :

- កាមាវចរចិត្ត **៤១** ដួង

(វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣)

- អភិញ្ញាចិត្ត **២** ដួង

**ខ.** ចិត្តដែលទទួលរូបអារម្មណ៍មិនបាន មាន **៣៥** ដួង គឺៈ

- មហគ្គតចិត្ត **២៧** ដួង
- លោកុត្តរចិត្ត **៨** ដួង

# ៦. អតីតអារម្មណ៍

**ក.** ចិត្តដែលទទួលអតីតអារម្មណ៍បាន មាន **៤៩** ដួង គឺ :

**+ ឯកន្តៈ** មាន **៦** ដួង បានដល់ :

- វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣ ដួង
- នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣ ដួង

**+ អនេកន្តៈ** មាន **៤៣** ដួង បានដល់ :

- កាមាវចរចិត្ត **៤១** ដួង

( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ )

- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួលអតីតអារម្មណ៍មិនបាន មាន **៤២** ដួង គឺ :

- ទ្វិបញ្ចវិញ្ញាណចិត្ត **១០** ដួង
- មនោធាតុ ៣ ដួង
- រូបាវចរចិត្ត **១៥** ដួង
- អាកាសានញ្ចាយតនជ្ឈានចិត្ត ៣ ដួង
- អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣ ដួង

- លោកុត្តរចិត្ត **៨** ដួង

## ៧. អនាគតអារម្មណ៍

**ក.**ចិត្តដែលទទួល អនាគតអារម្មណ៍បាន មាន **៤៣** ដួង គឺ :

+ **ឯកន្តៈ** មិនមាន

+ **អនេកន្តៈ** មាន **៤៣** ដួង បានដល់ :

- កាមាវចរចិត្ត **៤១** ដួង

( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ )

- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួលអនាគតអារម្មណ៍មិនបាន មាន **៤៨** ដួង គឺ :

- ទ្វិបញ្ចវិញ្ញាណចិត្ត **១០** ដួង

- មនោធាតុ **៣** ដួង

- មហគ្គតចិត្ត **២៧** ដួង

- លោកុត្តរចិត្ត **៨** ដួង

# ៨. បច្ចុប្បន្នអារម្មណ៍

**ក.**ចិត្តដែលទទួលបច្ចុប្បន្នអារម្មណ៍បាន មាន **៥៦** ដួង គឺ :

**+ ឯកន្តៈ** មាន **១៣** ដួង បានដល់ :

- ទ្វិបញ្ចវិញ្ញាណចិត្ត **១០** ដួង
- មនោធាតុ **៣** ដួង

**+ អនេកន្តៈ** មាន **៤៣** ដួង បានដល់ :

- កាមាវចរចិត្ត **៤១** ដួង

( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ )

- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួល បច្ចុប្បន្នអារម្មណ៍មិនបាន មាន **៣៥** ដួង គឺ :

- មហគ្គតចិត្ត **២៧** ដួង
- លោកុត្តរចិត្ត **៨** ដួង

# ៩. កាលវិមុត្តិអារម្មណ៍

**ក.**ចិត្តដែលទទួល កាលវិមុត្តិអារម្មណ៍បាន មាន **៦០** ដួង គឺ :

**+ ឯកន្តៈ** មាន **២៩** ដួង បានដល់ :

- រូបាវចរចិត្ត **១៥** ដួង
- អាកាសានញ្ចាយតនជ្ឈានចិត្ត **៣** ដួង
- អាកិញ្ចញ្ញាយតនជ្ឈានចិត្ត **៣** ដួង
- លោកុត្តរចិត្ត **៨** ដួង

**+ អនេកន្តៈ** មាន **៣១** ដួង បានដល់ :

- អកុសលចិត្ត **១២** ដួង
- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត **១** ដួង
- មហាកុសលចិត្ត **៨** ដួង
- មហាកិរិយាចិត្ត **៨** ដួង
- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួល កាលវិមុត្តិអារម្មណ៍មិនបាន មាន **៣១** ដួង បានដល់ :

- អហេតុកចិត្ត **១៧** ដួង

( វៀរឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១ )

- មហាវិបាកចិត្ត **៨** ដួង

- វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣ ដួង
- នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣ ដួង

## ១០. បញ្ញត្តិអារម្មណ៍

**ក.**ចិត្តដែលទទួល បញ្ញត្តិអារម្មណ៍បាន មាន **៥២** ដួង គឺ :

+ **ឯកន្តៈ** មាន **២១** ដួង បានដល់ :

- រូបាវចរចិត្ត **១៥** ដួង
- អាកាសានញ្ចាយតនជ្ឈានចិត្ត ៣ ដួង
- អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣ ដួង

+ **អនេកន្តៈ** មាន **៣១** ដួង បានដល់ :

- អកុសលចិត្ត **១២** ដួង
- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១ ដួង
- មហាកុសលចិត្ត ៨ ដួង
- មហាកិរិយាចិត្ត ៨ ដួង
- អភិញ្ញាចិត្ត ២ ដួង

**ខ.**ចិត្តដែលទទួលបញ្ញត្តិអារម្មណ៍មិនបាន មាន **៣៩** ដួង គឺ :

- អហេតុកចិត្ត **១៧** ដួង

( វៀរឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១ )

- មហាវិបាកចិត្ត **៨** ដួង
- វិញ្ញាណញ្ចាយតនជ្ឈានចិត្ត **៣** ដួង
- នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត **៣** ដួង
- លោកុត្តរចិត្ត **៨** ដួង

# ១១. បរមត្ថអារម្មណ៍

**ក.**ចិត្តដែលទទួល បរមត្ថអារម្មណ៍បាន មាន **៧០** ដួង គឺ :

**+ ឯកន្តៈ** មាន **៣៩** ដួង បានដល់ :

- អហេតុកចិត្ត **១៧** ដួង

( វៀរឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១ )

- មហាវិបាកចិត្ត **៨** ដួង
- វិញ្ញាណញ្ចាយតនជ្ឈានចិត្ត **៣** ដួង
- នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត **៣** ដួង

- លោកុត្តរចិត្ត ៨ ដួង

**+ អនេកន្តៈ** មាន **៣១** ដួង បានដល់ :

- អកុសលចិត្ត **១២** ដួង
- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត **១** ដួង
- មហាកុសលចិត្ត **៨** ដួង
- មហាកិរិយាចិត្ត **៨** ដួង
- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួល បរមត្ថអារម្មណ៍មិនបាន មាន **២១** ដួង គឺ :

- រូបាវចរចិត្ត **១៥** ដួង
- អាកាសានញ្ចាយតនជ្ឈានចិត្ត **៣** ដួង
- អាកិញ្ចញ្ញាយតនជ្ឈានចិត្ត **៣** ដួង

# ១២. អជ្ឈត្តអារម្មណ៍

**ក.**ចិត្តដែលទទួល អជ្ឈត្តអារម្មណ៍បាន មាន **៦២** ដួង គឺ :

**+ ឯកន្តៈ** មាន **៦** ដួង បានដល់ :

- វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣ ដួង
- នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣ ដួង

**+ អនេកន្តៈ** មាន **៥៦** ដួង បានដល់ :

- កាមាវចរចិត្ត **៥៤** ដួង
- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួល អជ្ឈត្តអារម្មណ៍មិនបាន មាន **២៩** ដួង គឺ :

- រូបាវចរចិត្ត **១៥** ដួង
- អាកាសានញ្ចាយតនជ្ឈានចិត្ត **៣** ដួង
- អាកិញ្ចញ្ញាយតនជ្ឈានចិត្ត **៣** ដួង
- លោកុត្តរចិត្ត **៨** ដួង

## ១៣. ពហិទ្ធអារម្មណ៍

**ក.** ចិត្តដែលទទួល ពហិទ្ធអារម្មណ៍បាន មាន **៨២** ដួង គឺ :

**+ ឯកន្តៈ** មាន **២៦** ដួង បានដល់ :

- រូបាវចរចិត្ត **១៥** ដួង

- អាកាសានញ្ចាយតនជ្ឈានចិត្ត ៣ ដួង
- លោកុត្តរចិត្ត ៨ ដួង

**+ អនេកន្តៈ** មាន **៥៦** ដួង បានដល់ :

- កាមាវចរចិត្ត **៥៤** ដួង
- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួល ពហិទ្ធអារម្មណ៍មិនបាន មាន **៩** ដួង គឺ :

- វិញ្ញាណញ្ចាយតនជ្ឈានចិត្ត ៣ ដួង
- អាកិញ្ចញ្ញាយតនជ្ឈានចិត្ត ៣ ដួង
- នេវសញ្ញានាសញ្ញាយតនជ្ឈានចិត្ត ៣ ដួង

## ១៤. អជ្ឈត្តពហិទ្ធអារម្មណ៍

**ក.**ចិត្តដែលទទួលអជ្ឈត្តពហិទ្ធអារម្មណ៍បាន មាន **៥៦** ដួង គឺ:

**+ ឯកន្តៈ** មិនមាន

**+ អនេកន្តៈ** មាន **៥៦** ដួង បានដល់ :

- កាមាវចរចិត្ត **៥៤** ដួង

- អភិញ្ញាចិត្ត **២** ដួង

**ខ.** ចិត្តដែលទទួល អជ្ឈត្តពហិទ្ធអារម្មណ៍មិនបាន មាន **៣៥** ដួង គឺ :

- មហគ្គតចិត្ត **២៧** ដួង
- លោកុត្តរចិត្ត **៨** ដួង

## ១៥. បញ្ញារម្មណ៍

**ក.** ចិត្តដែលទទួល បញ្ញារម្មណ៍បាន មាន **៤៦** ដួង គឺ :

**+ ឯកន្តៈ** មាន **៣** ដួង បានដល់ :

- មនោធាតុ **៣** ដួង

**+ អនេកន្តៈ** មាន **៤៣** ដួង បានដល់ :

- កាមាវចរចិត្ត **៤១** ដួង

( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ )

- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួល បញ្ញារម្មណ៍មិនបាន មាន **៤៥** ដួង គឺ:

- ទ្វិបញ្ចវិញ្ញាណចិត្ត **១០** ដួង
- មហគ្គតចិត្ត **២៧** ដួង
- លោកុត្តរចិត្ត **៨** ដួង

## ១៦. រូបារម្មណ៍

**ក.** ចិត្តដែលទទួល រូបារម្មណ៍បាន មាន **៤៨** ដួង គឺ :

**+ ឯកន្តៈ** មាន **២** ដួង បានដល់ :

- ចក្ខុវិញ្ញាណចិត្ត **២** ដួង

**+ អនេកន្តៈ** មាន **៤៦** ដួង បានដល់ :

- កាមាវចរចិត្ត **៤៤** ដួង

( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ )

- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួល រូបារម្មណ៍មិនបាន មាន **៤៣** ដួង គឺ :

- សោតវិញ្ញាណចិត្ត **២** ដួង
- ឃានវិញ្ញាណចិត្ត **២** ដួង
- ជីវ្ហាវិញ្ញាណចិត្ត **២** ដួង

- កាយវិញ្ញាណចិត្ត **២** ដួង
- មហគ្គតចិត្ត **២៧** ដួង
- លោកុត្តរចិត្ត **៨** ដួង

# ១៧. សទ្ទារម្មណ៍

**ក.** ចិត្តដែលទទួល សទ្ទារម្មណ៍បាន មាន **៤៨** ដួង គឺ :

+ **ឯកន្តៈ** មាន **២** ដួង បានដល់ :

- សោតវិញ្ញាណចិត្ត **២** ដួង

+ **អនេកន្តៈ** មាន **៤៦** ដួង បានដល់ :

- កាមាវចរចិត្ត **៤៤** ដួង

( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ )

- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួល សទ្ទារម្មណ៍មិនបាន មាន **៤៣** ដួង គឺ :

- ចក្ខុវិញ្ញាណចិត្ត **២** ដួង
- ឃានវិញ្ញាណចិត្ត **២** ដួង

- ជីវ្ហាវិញ្ញាណចិត្ត **២** ដួង
- កាយវិញ្ញាណចិត្ត **២** ដួង
- មហគ្គតចិត្ត **២៧** ដួង
- លោកុត្តរចិត្ត **៨** ដួង

## ១៨. គន្ធារម្មណ៍

**ក.** ចិត្តដែលទទួល គន្ធារម្មណ៍បាន មាន **៤៨** ដួង គឺ :

**+ ឯកន្តៈ** មាន **២** ដួង បានដល់ :

- ឃានវិញ្ញាណចិត្ត **២** ដួង

**+ អនេកន្តៈ** មាន **៤៦** ដួង បានដល់ :

- កាមាវចរចិត្ត **៤៤** ដួង

( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ )

- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួល គន្ធារម្មណ៍មិនបាន មាន **៤៣** ដួង គឺ :

- ចក្ខុវិញ្ញាណចិត្ត **២** ដួង
- សោតវិញ្ញាណចិត្ត **២** ដួង

- ជីវ្ហាវិញ្ញាណចិត្ត **២** ដួង
- កាយវិញ្ញាណចិត្ត **២** ដួង
- មហគ្គតចិត្ត **២៧** ដួង
- លោកុត្តរចិត្ត **៨** ដួង

## ១៩. រសារម្មណ៍

**ក.** ចិត្តដែលទទួល រសារម្មណ៍បាន មាន **៤៨** ដួង គឺ :

**+ ឯកន្តៈ** មាន **២** ដួង បានដល់ :

- ជីវ្ហាវិញ្ញាណចិត្ត **២** ដួង

**+ អនេកន្តៈ** មាន **៤៦** ដួង បានដល់ :

- កាមាវចរចិត្ត **៤៤** ដួង

( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ )

- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួល រសារម្មណ៍មិនបាន មាន **៤៣** ដួង គឺ :

- ចក្ខុវិញ្ញាណចិត្ត **២** ដួង
- សោតវិញ្ញាណចិត្ត **២** ដួង

- ឃានវិញ្ញាណចិត្ត **២** ដួង
- កាយវិញ្ញាណចិត្ត **២** ដួង
- មហគ្គតចិត្ត **២៧** ដួង
- លោកុត្តរចិត្ត **៨** ដួង

## ២០. ផោដ្ឋព្វារម្មណ៍

**ក.**ចិត្តដែលទទួល ផោដ្ឋព្វារម្មណ៍បាន មាន **៤៨** ដួង គឺ :

**+ ឯកន្តៈ** មាន **២** ដួង បានដល់ :

- កាយវិញ្ញាណចិត្ត **២** ដួង

**+ អនេកន្តៈ** មាន ៤៦ ដួង បានដល់ :

- កាមាវចរចិត្ត **៤៤** ដួង

( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ )

- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួល ផោដ្ឋព្វារម្មណ៍មិនបាន មាន **៤៣** ដួង គឺ :

- ចក្ខុវិញ្ញាណចិត្ត **២** ដួង
- សោតវិញ្ញាណចិត្ត **២** ដួង

- ឃានវិញ្ញាណចិត្ត **២** ដួង
- ជីវ្ហាវិញ្ញាណចិត្ត **២** ដួង
- មហគ្គតចិត្ត **២៧** ដួង
- លោកុត្តរចិត្ត **៨** ដួង

# ២១. ធម្មារម្មណ៍

**ក.**ចិត្តដែលទទួល ធម្មារម្មណ៍បាន មាន **៧៨** ដួង គឺ :

+ **ឯកន្តៈ** មាន **៣៥** ដួង បានដល់ :

- មហគ្គតចិត្ត **២៧** ដួង
- លោកុត្តរចិត្ត **៨** ដួង

+ **អនេកន្តៈ** មាន **៤៣** ដួង បានដល់ :

- កាមាវចរចិត្ត **៤១** ដួង

( វៀរទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ )

- អភិញ្ញាចិត្ត **២** ដួង

**ខ.**ចិត្តដែលទទួលធម្មារម្មណ៍មិនបាន មាន **១៣** ដួង គឺ :

- ទ្វិបញ្ចវិញ្ញាណចិត្ត **១០** ដួង

- មនោធាតុ ៣ ដួង

# ការសម្តែងអារម្មណ៍របស់ចិត្ត

យើងបានដឹងហើយថា ចិត្តនោះជាធម្មជាតិមួយ ដែលដឹងនូវអារម្មណ៍ ។ ចិត្តដែលកើតឡើងគ្រប់ៗខណៈ រមែងត្រូវមានអារម្មណ៍ជានិច្ច ហើយចិត្តដែលកើតឡើង មួយខណៈៗ តែងមានអារម្មណ៍បានតែមួយប៉ុណ្ណោះ មិនមានអារម្មណ៍ ២ ឬ ៣ យ៉ាង ក្នុងខណៈចិត្តតែមួយនោះបានឡើយ ។

ប៉ុន្តែការទទួលអារម្មណ៍របស់ចិត្តនោះ ចិត្តដួងខ្លះ មិនថានឹងកើតក្នុងខណៈណាក៏ដោយ ក៏តែងទទួលអារម្មណ៍ បានចំពោះតែម្យ៉ាងប៉ុណ្ណោះ ទទួលអារម្មណ៍យ៉ាងដទៃមិនបានឡើយ **ឯចិត្តដួងខ្លះ** ក៏ទទួលអារម្មណ៍ច្រើនយ៉ាងបាន ។

ដូច្នេះតទៅនេះ នឹងសម្តែងអំពីការទទួលអារម្មណ៍ របស់ចិត្តទាំងបាន ១ យ៉ាង ទាំងបានច្រើនយ៉ាង គឺ :

**១.**ចិត្តដែលទទួលអារម្មណ៍បានតែ **១** យ៉ាង មាន **២៨** ដួង

**២.**ចិត្ត ” ” **២** យ៉ាង មាន **២** ដួង

**៣.**ចិត្ត ” ” **៥** យ៉ាង មាន **៣** ដួង

| | | | | | |
|---|---|---|---|---|---|
| ៤.ចិត្តដែលទទួលអារម្មណ៍បានតែ | ៦ | យ៉ាង | មាន | ៤១ | ដួង |
| ៥.ចិត្ត ” ” ” | ១២ | យ៉ាង | មាន | ៣ | ដួង |
| ៦.ចិត្ត ” ” ” | ១៤ | យ៉ាង | មាន | ៩ | ដួង |
| ៧.ចិត្ត ” ” ” | ២៥ | យ៉ាង | មាន | ៣ | ដួង |

# អធិប្បាយ

១.ចិត្តដែលទទួលអារម្មណ៍**បានតែម៉្យាង មាន ២៨ ដួង** គឺ

-ចក្ខុវិញ្ញាណចិត្ត ២ មានអារម្មណ៍តែម៉្យាង គឺ រូបារម្មណ៍ដែលជាបច្ចុប្បន្ន ។

-សោតវិញ្ញាណចិត្ត ២ មានអារម្មណ៍តែម៉្យាង គឺ សទ្ទារម្មណ៍ដែលជាបច្ចុប្បន្ន ។

-ឃានវិញ្ញាណចិត្ត ២ មានអារម្មណ៍តែម៉្យាង គឺ គន្ធារម្មណ៍ដែលជាបច្ចុប្បន្ន ។

-ជីវ្ហាវិញ្ញាណចិត្ត ២ មានអារម្មណ៍តែម៉្យាង គឺ រសារម្មណ៍ដែលជាបច្ចុប្បន្ន ។

-កាយវិញ្ញាណចិត្ត ២ មានអារម្មណ៍តែម៉្យាង គឺផោដ្ឋព្វារម្មណ៍ដែលជាបច្ចុប្បន្ន ។

| | | |
|---|---|---|
| -អាកាសានញ្ចាយតនជ្ឈានចិត្ត | ៣ | មានអារម្មណ៍តែម៉្យាង គឺ កសិណុគ្ឃាដិមាកាសប្បញ្ញត្តិ ។ |
| -អាកិញ្ចញ្ញាយតនជ្ឈានចិត្ត | ៣ | មានអារម្មណ៍តែម៉្យាង គឺ នត្ថិភាវប្បញ្ញត្តិ ។ |
| -វិញ្ញាណញ្ចាយតនជ្ឈានកុសលចិត្ត ១ វិបាកចិត្ត ១ | | មានអារម្មណ៍តែម៉្យាង គឺ អាកាសានញ្ចាយតនជ្ឈានកុសលចិត្ត ដែលធ្លាប់កើតឡើងដល់ ខ្លួនក្នុងភពនេះ ឬ ភពមុន ។ |
| -នេវសញ្ញានាសញ្ញាយតនជ្ឈានកុសលចិត្ត ១ វិបាកចិត្ត ១ | | មានអារម្មណ៍តែម៉្យាង គឺ អាកិញ្ចញ្ញាយតនជ្ឈានកុសល ដែលធ្លាប់កើតដល់ខ្លួន ក្នុងភពនេះ ឬ ភពមុន ។ |
| -លោកុត្តរចិត្ត | ៨ | មានអារម្មណ៍តែម៉្យាង គឺ និព្វាន ។ |

២.ចិត្តដែលទទួលអារម្មណ៍បាន ២ យ៉ាង មាន ២ ដួង គឺ

-វិញ្ញាណញ្ចាយតនជ្ឈានកិរិយាចិត្ត **១** មានអារម្មណ៍ **២** យ៉ាង គឺ អាកាសានញ្ចាយតនជ្ឈាន-កុសលចិត្ត ដែលធ្លាប់កើតដល់ខ្លួនហើយ ក្នុងភពនេះ ឬ ភពមុន និងអាកាសា-នញ្ចាយតនជ្ឈានកិរិយាចិត្ត ដែលធ្លាប់កើតដល់ខ្លួនហើយ ក្នុងភពនេះ ។

-នេវសញ្ញានាសញ្ញាយតនជ្ឈាន-កិរិយាចិត្ត **១** មានអារម្មណ៍ ២ យ៉ាង គឺ អាកិញ្ចញ្ញាយតនជ្ឈាន-កុសលចិត្ត ដែលធ្លាប់កើតដល់ខ្លួនហើយ ក្នុងភពនេះ ឬ ភពមុន និង អាកិញ្ច-ញ្ញាយតនជ្ឈានកិរិយាចិត្ត ដែលធ្លាប់កើតដល់ខ្លួនហើយ ក្នុងភពនេះ ។

**៣**.ចិត្តដែលទទួលអារម្មណ៍បាន **៥ យ៉ាង មាន ៣ ដួង** គឺ :

-មនោធាតុ ៣ មានអារម្មណ៍ ៥ យ៉ាង គឺ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ។

**៤.**ចិត្តដែលទទួលអារម្មណ៍បាន **៦ យ៉ាង មាន ៤១ ដួង** គឺ :

| | | |
|---|---|---|
| -ឧបេក្ខាមនោវិញ្ញាណធាតុ-អហេតុកកិរិយាចិត្ត | **១** | មាន អារម្មណ៍ ៦ យ៉ាង គឺ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ធម្មារម្មណ៍ |
| -តទាលម្ពណចិត្ត | **១១** | |
| -កាមជវនចិត្ត | **២៩** | |

**៥.**ចិត្តដែលទទួលអារម្មណ៍បាន **១២ យ៉ាង មាន ៣ ដួង** គឺ :

-រូបាវចរបញ្ចមជ្ឈានចិត្ត **៣** មានអារម្មណ៍ **១២** យ៉ាង គឺ កសិណបញ្ញត្តិ **១០** អានាបានបញ្ញត្តិ **១** មជ្ឈត្តសត្វបញ្ញត្តិ (ឧបេក្ខាព្រហ្មវិហារ) **១** ។

**៦.**ចិត្តដែលទទួលអារម្មណ៍បាន **១៤ យ៉ាង មាន ៩ ដួង** គឺ :

-រូបាវចរទុតិយជ្ឈានចិត្ត ៣
-រូបាវចរតតិយជ្ឈានចិត្ត ៣
-រូបាវចរចតុត្ថជ្ឈានចិត្ត ៣

មានអារម្មណ៍ ១៤ យ៉ាង គឺ កសិណបញ្ញត្តិ ១០ អានាបានបញ្ញត្តិ ១ បិយមនាបសត្វបញ្ញត្តិ(មេត្តា) ១ ទុក្ខិតសត្វប្បញ្ញត្តិ (ករុណា) ១ សុខិតសត្វប្បញ្ញត្តិ (មុទិតា) ១ ។

**៧.**ចិត្តដែលទទួលអារម្មណ៍បាន **២៥ យ៉ាង មាន ៣ ដួង** គឺ :

-រូបាវចរបឋមជ្ឈានចិត្ត ៣ មានអារម្មណ៍ **២៥** យ៉ាង គឺ កសិណបញ្ញត្តិ ១០ អសុភបញ្ញត្តិ ១០ កោដ្ឋាសប្បញ្ញត្តិ (កាយគតាសតិ) ១ អានាបានបញ្ញត្តិ ១ បិយមនាបសត្វប្បញ្ញត្តិ ១ ទុក្ខិតសត្វបញ្ញត្តិ ១ សុខិតសត្វបញ្ញត្តិ ១ ។

# ចេតសិក និង អារម្មណ៍

**ចិត្ត** ជាធម្មជាតិដែលដឹងនូវអារម្មណ៍ ហើយការប្រាកដឡើងរបស់ចិត្តនោះ តែងប្រកបព្រមជាមួយនឹងចេតសិក ដោយ **ចេតោយុត្តលក្ខណៈ** គឺ ចេតសិកនោះ តែងកើតព្រមជាមួយនឹងចិត្ត **ឯកុប្បាទៈ** , តែងរលត់ព្រមជាមួយនឹងចិត្ត **ឯកនិរោធៈ** , តែងមានអារម្មណ៍ដូចគ្នានឹងចិត្ត **ឯកាលម្ពណៈ** , តែងមាននាទីអាស្រ័យជាមួយគ្នានឹងចិត្ត **ឯកវត្ថុកៈ** ។

ដូច្នេះ ចេតសិកធម៌ទាំងឡាយនោះ តែងមានការទទួលអារម្មណ៍បាន ដូចគ្នាជាមួយនឹងចិត្ត ។ កាលណាចិត្តដឹងនូវអារម្មណ៍ណា ចេតសិកដែលប្រកបជាមួយនឹងចិត្តនោះ ក៏រមែងដឹងនូវអារម្មណ៍នោះដែរ ។ កាលបើចែក ការទទួលអារម្មណ៍ដោយទូទៅរបស់ចេតសិកហើយ ក៏អាចចែកបានយ៉ាងនេះ គឺ :

-ចេតសិក **៥០** (វៀរអប្បមញ្ញា)ទទួលបញ្ញារម្មណ៍ ។

-ចេតសិក **៥២** ទទួលធម្មារម្មណ៍ ។

-អកុសលចេតសិក **១៤** ទទួលអារម្មណ៍ **៦** ដែលជាលោកិយ និង បញ្ញត្តិ ។

| | | |
|---|---|---|
| -ឥស្សាចេតសិក | ១ | ទទួលអារម្មណ៍ ៦ ដែលជា ពហិទ្ធារម្មណ៍ ។ |
| -វិរតិចេតសិក(លោកិយៈ) | ៣ | ទទួលអារម្មណ៍ ៦ ដែលជា កាមារម្មណ៍ ។ |
| -វិរតិចេតសិក(លោកុត្តរៈ) | ៣ | ទទួលអារម្មណ៍ ១ គឺ និព្វាន-អារម្មណ៍ ។ |
| -អប្បមញ្ញាចេតសិក | ២ | ទទួលធម្មារម្មណ៍ ដែលជា បញ្ញត្តិអារម្មណ៍( សត្វ ) និង ពហិទ្ធារម្មណ៍ ។ |

| | | |
|---|---|---|
| -អញ្ញសមានាចេតសិក | ១៣ | ទទួលអារម្មណ៍ ៦ ដែលជា លោកិយៈ លោកុត្តរៈ អតីត អនាគត បច្ចុប្បន្ន កាលវិមុត្តិ អជ្ឈត្តៈ និង ពហិទ្ធៈ ៕ |
| -សោភណសាធារណចេតសិក | ១៩ | |
| -បញ្ញាចេតសិក | ១ | |

# ការចែកចេតសិកទទួលអារម្មណ៍ ២១ ដោយឯកន្តៈ និង អនេកន្តៈ

១. ចេតសិក ដែលទទួល**កាមារម្មណ៍**

+ **ឯកន្តៈ** មិនមាន ។
+ **អនេកន្តៈ** មាន **៥០** ដួង ( វៀរអប្បមញ្ញាចេតសិក**២** ) ។

២. ចេតសិក ដែលទទួល**មហគ្គតារម្មណ៍**

+ **ឯកន្តៈ** មិនមាន ។
+ **អនេកន្តៈ** មាន **៤៧** ដួង ( វៀរវិរតិចេតសិក **៣** អប្ប-មញ្ញាចេតសិក **២** ) ។

៣. ចេតសិក ដែលទទួល**និព្វានអារម្មណ៍**

+ **ឯកន្តៈ** មិនមាន ។
+ **អនេកន្តៈ** មាន **៣៦** ដួង គឺ អញ្ញសមានាចេតសិក **១៣** សោភណចេតសិក **២៣** (វៀរអប្បមញ្ញាចេតសិក **២** ) ។

៤. ចេតសិក ដែលទទួល**នាមអារម្មណ៍**

+ **ឯកន្តៈ** មិនមាន ។

+ **អនេកន្តៈ** មាន **៥០** ដួង (វៀរអប្បមញ្ញាចេតសិក **២**) ។

៥. ចេតសិក ដែលទទួល**រូបអារម្មណ៍**

+ **ឯកន្តៈ** មិនមាន ។

+ **អនេកន្តៈ** មាន **៥០** ដួង (វៀរអប្បមញ្ញាចេតសិក **២**) ។

៦. ចេតសិក ដែលទទួល**អតីតារម្មណ៍**

+ **ឯកន្តៈ** មិនមាន ។

+ **អនេកន្តៈ** មាន **៤៧** ដួង ( វៀរវិរតិចេតសិក **៣** អប្បមញ្ញាចេតសិក **២** ) ។

៧. ចេតសិក ដែលទទួល**អនាគតារម្មណ៍**

+ **ឯកន្តៈ** មិនមាន ។

+ **អនេកន្តៈ** មាន **៥០** ដួង ( វៀរអប្បមញ្ញាចេតសិក **២** ) ។

៨. ចេតសិក ដែលទទួល**បច្ចុប្បន្នារម្មណ៍**

+ **ឯកន្តៈ** មិនមាន ។

+ **អនេកន្តៈ** មាន **៥០** ដួង( វៀរអប្បមញ្ញាចេតសិក **២** ) ។

**៩.** ចេតសិក ដែលទទួល**កាលវិមុត្តិអារម្មណ៍**

+ **ឯកន្តៈ** មាន **២** ដួង គឺ អប្បមញ្ញាចេតសិក **២** ដួង ។
+ **អនេកន្តៈ** មាន **៥០** ដួង( វៀរអប្បមញ្ញាចេតសិក **២** ) ។

**១០.** ចេតសិក ដែលទទួល**បញ្ញត្តិអារម្មណ៍**

+ **ឯកន្តៈ** មាន **២** ដួង គឺ អប្បមញ្ញាចេតសិក **២** ដួង ។
+ **អនេកន្តៈ** មាន **៤៧** ដួង( វៀរវិរតិ **៣** អប្បមញ្ញា-ចេតសិក **២** ) ។

**១១.** ចេតសិក ដែលទទួល**បរមត្ថអារម្មណ៍**

+ **ឯកន្តៈ** មាន **៣** ដួង គឺ វិរតិចេតសិក **៣** ដួង ។
+ **អនេកន្តៈ** មាន **៤៧** ដួង ( វៀរវិរតិចេតសិក **៣** អប្បមញ្ញាចេតសិក **២** ) ។

**១២.** ចេតសិក ដែលទទួល**អជ្ឈត្តារម្មណ៍**

+ **ឯកន្តៈ** មិនមាន ។
+ **អនេកន្តៈ** មាន **៤៩** ដួង (វៀរឥស្សាចេតសិក **១** អប្បមញ្ញា-

ចេតសិក ២ ) ។

**១៣.** ចេតសិក ដែលទទួល**ពហិទ្ធអារម្មណ៍**

+ **ឯកន្តៈ** មាន **៣** ដួង គឺ ឥស្សាចេតសិក ១ អប្បមញ្ញា-ចេតសិក ២ ដួង ។

+ **អនេកន្តៈ** មាន **៤៩** ដួង (វៀរឥស្សាចេតសិក ១ អប្បមញ្ញា-ចេតសិក ២ ) ។

**១៤.** ចេតសិក ដែលទទួល**អជ្ឈត្តពហិទ្ធអារម្មណ៍**

+ **ឯកន្តៈ** មិនមាន ។

+ **អនេកន្តៈ** មាន **៤៩** ដួង ( វៀរ ឥស្សាចេតសិក ១ អប្បមញ្ញាចេតសិក ២ ) ។

**១៥.** ចេតសិក ដែលទទួល**បញ្ញារម្មណ៍**

+ **ឯកន្តៈ** មិនមាន ។

+ **អនេកន្តៈ** មាន **៥០** ដួង (វៀរអប្បមញ្ញាចេតសិក ២) ។

**១៦.** ចេតសិក ដែលទទួល**រូបារម្មណ៍ ១៧-សទ្ទារម្មណ៍ ១៨-គន្ធារម្មណ៍ ១៩-រសារម្មណ៍ ២០-ផោដ្ឋព្វារម្មណ៍** ។

+ **ឯកន្តៈ** មិនមាន ។

+ **អនេកន្តៈ** មាន **៥០** ដួង (វៀរអប្បមញ្ញាចេតសិក **២**) ។

**២១.** ចេតសិក ដែលទទួល**ធម្មារម្មណ៍**

+ **ឯកន្តៈ** មាន **២** ដួង គឺ អប្បមញ្ញាចេតសិក **២** ។

+ **អនេកន្តៈ** មាន **៥០** ដួង (វៀរអប្បមញ្ញាចេតសិក**២**) ។

( ចប់ អារម្មណសង្គហៈ )

---------- • ----------

# វត្ថុសង្គហៈ

ការរួបរួមចិត្តនិងចេតសិក ដោយប្រភេទនៃវត្ថុរូប គឺ ដែលអាស្រ័យកើតជាមួយនឹងវត្ថុរូប ឈ្មោះថា “ **វត្ថុសង្គហៈ** ” ។

វត្ថុរូប ដែលត្រូវជាទីអាស្រ័យកើតរបស់ចិត្ត និង ចេតសិក មាន **៦** កន្លែង ហៅថា **វត្ថុ ៦** ។

## វត្ថុ ៦

| | | | |
|---|---|---|---|
| **១.** | **ចក្ខុវត្ថុ** | បានដល់ | ចក្ខុបសាទរូប |
| **២.** | **សោតវត្ថុ** | បានដល់ | សោតបសាទរូប |
| **៣.** | **ឃានវត្ថុ** | បានដល់ | ឃានបសាទរូប |
| **៤.** | **ជីវ្ហាវត្ថុ** | បានដល់ | ជីវ្ហាបសាទរូប |
| **៥.** | **កាយវត្ថុ** | បានដល់ | កាយបសាទរូប |
| **៦.** | **ហទយវត្ថុ** | បានដល់ | ហទយវត្ថុរូប |

# អធិប្បាយ

## វសន្តិ បតិដ្ឋហន្តិ ចិត្តចេតសិកា ឯត្ថាតិ = វត្ថុ

ចិត្ត និង ចេតសិកទាំងឡាយ រមែងអាស្រ័យតាំងនៅក្នុងធម៌ណា ដូច្នេះធម៌ជាទីអាស្រ័យតាំងនៅរបស់ចិត្ត និងចេតសិកទាំងនោះ ឈ្មោះថា **វត្ថុ** ។

ធម្មតាផែនដី រមែងជាទីអាស្រ័យនៅ របស់អវិញ្ញាណកវត្ថុ គឺ បណ្តាវត្ថុដែលមិនមានជីវិត មានភ្នំ ដើមឈើ ទន្លេជាដើម និង សវិញ្ញាណកវត្ថុ គឺ បណ្តាវត្ថុដែលមានជីវិត មានមនុស្ស សត្វតិរច្ឆានជាដើម ទាំងអស់នោះ យ៉ាងណា **វត្ថុរូបទាំង ៦** មានចក្ខុវត្ថុជាដើម ក៏រមែងជាទីអាស្រ័យនៅ របស់ចិត្តនិងចេតសិកទាំងអស់នោះ តាមសភាពរបស់ខ្លួនក៏ យ៉ាងនោះដូចគ្នាដែរ ។

បណ្តាដើមឈើទាំងឡាយ រមែងចម្រើនលូតលាស់បាន ដោយអាស្រ័យផែនដី យ៉ាងណា ចិត្តនិងចេតសិកទាំងឡាយដែលប្រាកដឡើងបាន និងកើតបន្តគ្នាជារឿយៗទៅបាននោះ ក៏ដោយអាស្រ័យ **វត្ថុរូបទាំង ៦** ក៏យ៉ាងនោះដែរ ។ **វត្ថុរូបទាំង ៦** នេះ ប្រៀបដូចជាផែនដី ឯចិត្ត និង ចេតសិក ប្រៀបដូចជា អវិញ្ញាណកវត្ថុ

និង សវិញ្ញាណកវត្ថុ ។ ព្រោះហេតុនោះ ទើបអនុលោមពោលបានថា ចិត្ត និង ចេតសិកទាំងឡាយ នៅក្នុងវត្ថុរូបទាំង **៦** ជាការពោលដោយវោហារប៉ុណ្ណោះ ។ ដូចជាពោលថា ដើមឈើនៅក្នុងគ្រាប់ពូជ ឬ សម្លេងរគាំងនៅក្នុងរគាំង ប៉ុន្តែសេចក្តីពិតនោះ ដើមឈើមិនបាននៅក្នុងគ្រាប់ពូជ សម្លេងរគាំងមិនបាននៅក្នុងរគាំងទេ ដើមឈើក្តី សម្លេងរគាំងក្តី ដែលប្រាកដឡើងបាននោះ រមែងអាស្រ័យបច្ច័យ បើហេតុបច្ច័យកើតឡើងព្រមគ្រប់គ្រាន់ហើយ ដើមឈើ ក៏កើតឡើងអំពីពូជបាន សម្លេងរគាំង ក៏កើតពីរគាំងបាន យ៉ាងណា ចិត្តនិងចេតសិក ក៏កើតឡើងដោយអាស្រ័យ **វត្ថុរូប ៦** ក៏យ៉ាងនោះដូចគ្នាដែរ ។ បើមានហេតុបច្ច័យ គ្រប់គ្រាន់ហើយ ចិត្ត និង ចេតសិកក៏កើតឡើងអំពីវត្ថុរូបបាន ប៉ុន្តែបើហេតុបច្ច័យមិនគ្រប់គ្រាន់ទេ ចិត្តនិងចេតសិកក៏កើតឡើងអំពី**វត្ថុរូប ៦** មិនបាន ។

ធម៌ដែលជាហេតុ ជាបច្ច័យឲ្យចិត្ត និង ចេតសិកកើតឡើងអំពី **វត្ថុរូប ៦** បាននោះ មានហេតុ និង បច្ច័យដែលជាគោលសំខាន់ ៣ យ៉ាង គឺ :

**១. អតីតកម្ម**

**២. វត្ថុ**

## ៣. **អារម្មណ៍**

បើគ្រប់ហេតុទាំង ៣ យ៉ាងនេះហើយ ចិត្តចេតសិកក៏កើតឡើងអំពី**វត្ថុរូប ៦** បាន ។

ការសម្តែងហេតុបច្ច័យនៃការកើតឡើងរបស់ចិត្ត និង ចេតសិកដែលអាស្រ័យដោយ **វត្ថុរូប ៦** នេះនុ៎ះ សំដៅយកចំពោះតែក្នុងបញ្ចវោការភូមិប៉ុណ្ណោះ ។ ចំពោះក្នុងចតុវោការភូមិនោះ ហេតុ-បច្ច័យដែលធ្វើឲ្យចិត្តនិងចេតសិកកើតឡើងបាន រមែងមានត្រឹមតែ **២ ប្រការ** គឺ **អតីតកម្ម** និង **អារម្មណ៍** ប៉ុណ្ណោះ ៕

---------- • ----------

# ភូមិ ៣០
# វត្ថុរូប ៦ និង វិញ្ញាណធាតុ ៧

## គាថាសង្គហៈ

១៣. ឆវត្ថុំ និស្សិតា កាមេ សត្តរូបេ ចតុព្វិធា
តិវត្ថុំ និស្សិតា រូបេ ធាត្វេកា និស្សិតា មតា

ប្រែថា ៖

| | |
|---|---|
| វិញ្ញាណធាតុ **៧** យ៉ាង | អាស្រ័យវត្ថុរូប **៦** កើតនៅក្នុងកាមភូមិ **១១** ។ |
| វិញ្ញាណធាតុ **៤** យ៉ាង | អាស្រ័យវត្ថុរូប **៣** កើតនៅក្នុងរូបភូមិ **១៥** ( វៀរអសញ្ញសត្តភូមិ ) ។ |
| មនោវិញ្ញាណធាតុ **១** យ៉ាង | មិនបានអាស្រ័យវត្ថុរូបណាមួយឡើយ កើតនៅក្នុងអរូបភូមិ ៤។ |

# អធិប្បាយ

វិញ្ញាណធាតុ គឺ ធម្មជាតិដែលទ្រទ្រង់នូវសភាពដឹងអារម្មណ៍ផ្សេងៗ ដែលបានដល់ ចិត្ត **៨៩** ឬ **១២១** ដួង ។

កាលបើពោលដោយធាតុដឹង ក៏រមែងបានវិញ្ញាណធាតុ **៧** គឺ :

## វិញ្ញាណធាតុ ៧

**១.** ចក្ខុវិញ្ញាណចិត្ត **២** ដួង ជាចក្ខុវិញ្ញាណធាតុ

**២.** សោតវិញ្ញាណចិត្ត **២** ដួង ជាសោតវិញ្ញាណធាតុ

**៣.** ឃានវិញ្ញាណចិត្ត **២** ដួង ជាឃានវិញ្ញាណធាតុ

**៤.** ជីវ្ហាវិញ្ញាណចិត្ត **២** ដួង ជាជីវ្ហាវិញ្ញាណធាតុ

**៥.** កាយវិញ្ញាណចិត្ត **២** ដួង ជាកាយវិញ្ញាណធាតុ

ទាំង **៥** នេះ ហៅថា វិញ្ញាណធាតុ **៥** ឬ ហៅថា បញ្ចវិញ្ញាណធាតុ ។

**៦.** ឧបេក្ខាមនោធាតុអហេតុកកិរិយាចិត្ត **១** ដួង
ឧបេក្ខាមនោធាតុអហេតុកវិបាកចិត្ត **២** ដួង
} ទាំង ៣ ដួងនេះ ជាមនោធាតុ ។

**៧.** ចិត្តដែលនៅសល់ **៧៦** ដួងទៀត ជាមនោវិញ្ញាណធាតុ ។

# ភូមិជាមួយនិងវត្ថុ

វត្ថុ ជាទីអាស្រ័យកើត របស់វិញ្ញាណធាតុនោះ ដែលប្រាកដនៅក្នុងភូមិផ្សេងៗ មានចំនួនមិនស្មើគ្នាទេ ។ ដូច គាថាសង្គហៈ ទី **១៣** បានសម្តែងប្រភេទរបស់ភូមិ ទុកថា :

ក្នុងកាមភូមិ **១១** វិញ្ញាណធាតុ **៧** យ៉ាង កើតឡើង ដោយអាស្រ័យវត្ថុ **៦** ។

ក្នុងរូបភូមិ **១៥** វិញ្ញាណធាតុ **៤** យ៉ាង កើតឡើង ដោយអាស្រ័យវត្ថុ **៣** ។

ក្នុងអរូបភូមិ **៤** វិញ្ញាណធាតុ **១** យ៉ាង កើតឡើង ដោយមិនអាស្រ័យវត្ថុរូបឡើយ ។

# ការចែកវិញ្ញាណធាតុ ៧ យ៉ាង ដែលកើតក្នុងកាមភូមិ ១១ ដោយវត្ថុរូប ៦ " ឆវត្ថុំ និស្សិតា កាមេ សត្ត "

| | | | | |
|---|---|---|---|---|
| **១.** | ចក្ខុវិញ្ញាណធាតុ | **២** | អាស្រ័យចក្ខុវត្ថុ | កើត |
| **២.** | សោតវិញ្ញាណធាតុ | **២** | អាស្រ័យសោតវត្ថុ | កើត |
| **៣.** | ឃានវិញ្ញាណធាតុ | **២** | អាស្រ័យឃានវត្ថុ | កើត |
| **៤.** | ជីវ្ហាវិញ្ញាណធាតុ | **២** | អាស្រ័យជីវ្ហាវត្ថុ | កើត |
| **៥.** | កាយវិញ្ញាណធាតុ | **២** | អាស្រ័យកាយវត្ថុ | កើត |
| **៦.** | មនោធាតុ | **៣** | អាស្រ័យហទយវត្ថុ | កើត |
| **៧.** | មនោវិញ្ញាណធាតុ | **៦៧** | បានដល់ : | |
| | - កាមាវចរចិត្ត | **៤១** | ( វៀរ ទ្វិបញ្ចវិញ្ញាណចិត្ត ១០ មនោធាតុ ៣ ) | |
| | - មហគ្គតកុសលចិត្ត | **៩** | មហគ្គតកិរិយាចិត្ត ៩ ( វៀរ មហគ្គតវិបាកចិត្ត ៩ ) | |
| | - លោកុត្តរចិត្ត | **៨** | | |

ចិត្តទាំង **៦៧** ដួងនេះ អាស្រ័យហទយវត្ថុ កើត ៕

# ការចែកវិញ្ញាណធាតុ ៤
# ដែលកើតក្នុងរូបភូមិ ១៥ ដោយវត្ថុរូប ៣
# “ រូបេ ចតុព្វិធា តិវត្ថុំ និស្សិតា ”

| | | | | |
|---|---|---|---|---|
| ១. | ចក្ខុវិញ្ញាណធាតុ | ២ | អាស្រ័យចក្ខុវត្ថុ | កើត |
| ២. | សោតវិញ្ញាណធាតុ | ២ | អាស្រ័យសោតវត្ថុ | កើត |
| ៣. | មនោធាតុ | ៣ | អាស្រ័យហទយវត្ថុ | កើត |
| ៤. | មនោវិញ្ញាណធាតុ | ៦២ | បានដល់ : | |

| | |
|---|---|
| - អកុសលចិត្ត<br>( វៀរទោសមូលចិត្ត ២ ) | ១០ |
| - មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត | ៣ |
| - ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត | ១ |
| - ហសិតុប្បាទចិត្ត | ១ |
| - មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត | ៨ |
| - រូបាវចរចិត្ត | ១៥ |
| - អរូបាវចរកុសលចិត្ត ៤ អរូបាវចរកិរិយាចិត្ត | ៤ |

- លោកុត្តរចិត្ត ៨

វត្ថុទាំង ៦២ ដួងនេះ អាស្រ័យហទយវត្ថុ កើត ៕

## វិញ្ញាណធាតុ ១ យ៉ាង ដែលកើត ក្នុងអរូបភូមិ ៤ ដោយមិនបានអាស្រ័យវត្ថុរូប

មនោវិញ្ញាណធាតុ ៤៦ បានដល់ :

- អកុសលចិត្ត ១០

( វៀរទោសមូលចិត្ត ២ )

- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
- មហាកុសលចិត្ត ៨ មហាកិរិយាចិត្ត ៨
- អរូបាវចរចិត្ត ១២
- លោកុត្តរចិត្ត ៧

( វៀរសោតាបត្តិមគ្គចិត្ត ១ )

ចិត្តទាំង ៤៦ ដួងនេះ កើតឡើងដោយមិនបានអាស្រ័យវត្ថុរូបណាមួយឡើយ ។

**ចំណាំ :**

វត្ថុរូបទាំង **៦** និងវិញ្ញាណធាតុទាំង **៧** យ៉ាង មិនមានក្នុង **អសញ្ញសត្តភូមិ** ។

## ចិត្ត ជាមួយនឹង វត្ថុ

តាមដែលបានពោលមកហើយ ថា វិញ្ញាណធាតុទាំង **៧** ដែលប្រាកដឡើងនោះ ចំណែកច្រើនរមែងអាស្រ័យវត្ថុកើត ចំពោះមនោវិញ្ញាណធាតុប្រភេទខ្លះ មិនបាច់អាស្រ័យវត្ថុ ក៏កើតឡើងបាន ។ ដូច្នេះក្នុងគាថាសង្គហៈទី **១៤** បានសម្តែងដល់ចិត្ត ដួងខ្លះ ត្រូវអាស្រ័យវត្ថុកើតក៏មាន ដួងខ្លះ ជួនកាលអាស្រ័យវត្ថុកើតក៏បាន ជួនកាលមិនបាច់អាស្រ័យវត្ថុកើតក៏បានក៏មាន និងដួងខ្លះ មិនបានអាស្រ័យវត្ថុ ណាមួយសោះ អាចកើតបាន ក៏មាន ។

# គាថាសង្គហៈ

១៤. តេចត្តាឡីស និស្សាយ ទ្វេចត្តាឡីស ជាយរេ
អនិស្សាយច និស្សាយ បាការុប្បា អនិស្សិតា

ប្រែថា ចិត្ត **៤៣** ដួង ត្រូវអាស្រ័យវត្ថុរូប ដោយពិតប្រាកដ ( ឯកន្តៈ ) ចិត្ត **៤២** ដួង ជួនកាលក៏អាស្រ័យវត្ថុរូប ជួនកាលក៏មិនបាច់អាស្រ័យ ។ អរូបាវចរវិបាកចិត្ត **៤** ដួង មិនអាស្រ័យវត្ថុរូបណាមួយឡើយ ។

# អធិប្បាយ

## ការចែកចិត្ត ៤៣ ដួងដែលអាស្រ័យវត្ថុរូបកើតប្រាកដដោយវត្ថុរូប ៦
## “ តេចត្តាឡីស និស្សាយ ជាយរេ ”

ចិត្ត **៤៣** ដួង ដែលអាស្រ័យវត្ថុរូប កើតដោយប្រាកដ គឺ :

| | | | |
|---|---|---|---|
| -ចក្ខុវិញ្ញាណចិត្ត | **២** | អាស្រ័យចក្ខុវត្ថុ | កើតប្រាកដ ។ |
| -សោតវិញ្ញាណចិត្ត | **២** | អាស្រ័យសោតវត្ថុ | កើតប្រាកដ ។ |
| -ឃានវិញ្ញាណចិត្ត | **២** | អាស្រ័យឃានវត្ថុ | កើតប្រាកដ ។ |
| -ជិវ្ហាវិញ្ញាណចិត្ត | **២** | អាស្រ័យជិវ្ហាវត្ថុ | កើតប្រាកដ ។ |
| -កាយវិញ្ញាណចិត្ត | **២** | អាស្រ័យកាយវត្ថុ | កើតប្រាកដ ។ |

-ឧបេក្ខាមនោធាតុអហេតុកវិបាកចិត្ត ២ អាស្រ័យហទយវត្ថុ កើតប្រាកដ ។

-មនោវិញ្ញាណធាតុអហេតុកវិបាកចិត្ត ៣ អាស្រ័យហទយវត្ថុ កើតប្រាកដ ។

-ឧបេក្ខាមនោធាតុអហេតុកកិរិយាចិត្ត ១ អាស្រ័យហទយវត្ថុ កើតប្រាកដ ។

-ហសិតុប្បាទចិត្ត ១ អាស្រ័យហទយវត្ថុ កើតប្រាកដ ។

-ទោសមូលចិត្ត ២ អាស្រ័យហទយវត្ថុ កើតប្រាកដ ។

-មហាវិបាកចិត្ត ៨ អាស្រ័យហទយវត្ថុ កើតប្រាកដ ។

-រូបាវចរចិត្ត ១៥ អាស្រ័យហទយវត្ថុ កើតប្រាកដ ។

-សោតាបត្តិមគ្គចិត្ត ១ អាស្រ័យហទយវត្ថុ កើតប្រាកដ ។

រួមចិត្ត **៤៣** ដួងនេះ អាស្រ័យវត្ថុរូបកើត **ដោយប្រាកដ (ឯកន្តៈ)** ព្រោះចិត្តទាំងនោះ រមែងកើតបានចំពោះតែក្នុងបញ្ចវោការភូមិប៉ុណ្ណោះ ពោលគឺ ចិត្ត **៤៣** ដួងនេះ រមែងកើតបានកំណត់ដោយភូមិ គឺចំពោះតែក្នុងកាមបុគ្គល និងរូបបុគ្គលប៉ុណ្ណោះ នឹងអាចកើតក្នុងអរូបបុគ្គល មិនបាន ។

# ការចែកចិត្ត ៤២ ដួង
# អាស្រ័យវត្ថុរូបកើតមិនប្រាកដដោយវត្ថុរូប ៦
# “ ទ្វេចត្តាឡីស និស្សាយ ច អនិស្សាយ ជាយរេ ”

ចិត្ត **៤២** ដួង ដែលអាស្រ័យវត្ថុរូបកើតដោយមិនពិតប្រាកដនោះ បានសេចក្ដីថា ជួនកាលអាស្រ័យវត្ថុរូបកើត ជួនកាលក៏មិនអាស្រ័យវត្ថុរូបកើត គឺ :

- អកុសលចិត្ត **១០** ( វៀរទោសមូលចិត្ត **២** )
- មហាកុសលចិត្ត **៨**
- មហាកិរិយាចិត្ត **៨**
- អរូបាវចរកុសលចិត្ត **៤**
- អរូបាវចរកិរិយាចិត្ត **៤**
- លោកុត្តរចិត្ត **៧** ( វៀរសោតាបត្តិមគ្គចិត្ត **១** )
- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត **១**

រួមចិត្ត **៤២** ដួងនេះអាស្រ័យហទយវត្ថុកើតដោយមិន ប្រាកដ ព្រោះថា បើចិត្តទាំងនេះកើតក្នុងបញ្ចវោការភូមិ គឺ ភូមិដែលមាន

ខន្ធ ៥ ក៏ត្រូវអាស្រ័យវត្ថុរូបកើតដោយប្រាកដ ប៉ុន្តែបើកើតក្នុង ចតុវោការភូមិ គឺភូមិដែលមានខន្ធ ៤ ក៏មិនបាច់អាស្រ័យវត្ថុរូប កើតឡើយ បានសេចក្តីថា បើចិត្តទាំង ៤២ ដួងនេះ កើតនឹង កាមបុគ្គល និង រូបបុគ្គល(វៀរអសញ្ញសត្តបុគ្គល) ត្រូវអាស្រ័យ ហទយវត្ថុ កើតដោយប្រាកដ ប៉ុន្តែបើកើតនឹងអរូបបុគ្គល មិនបាច់ អាស្រ័យវត្ថុឡើយ ក៏កើតឡើងបាន ។

## អរូបាវចរវិបាកចិត្ត ៤
## មិនអាស្រ័យវត្ថុរូបកើតដោយប្រាកដ
## “ បាកា រុប្បា អនិស្សិតា ជាយរេ ”

ចិត្តដែលមិនបានអាស្រ័យវត្ថុរូប ដោយប្រាកដ មាន ៤ គឺ អរូបាវចរវិបាកចិត្ត ៤ ព្រោះអរូបាវចរចិត្ត ៤ ដួងនេះ កើតបាន ចំពោះក្នុងអរូបភូមិ ដែលជាភូមិមិនមានរូបធម៌ មានតែនាមធម៌ ប៉ុណ្ណោះ គឺ មានតែនាមក្ខន្ធ ៤ បានដល់ វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ និង វិញ្ញាណក្ខន្ធ ចំណែករូបក្ខន្ធមិនមានទេ ។ អរូបភូមិ នេះ ទើបបានឈ្មោះម្យ៉ាងទៀតថា “ **ចតុវោការភូមិ** ” ។

សេចក្តីនេះ គឺថា អរូបាវចរវិបាកចិត្ត កើតបានចំពោះតែអរូបភូមិ

ប៉ុណ្ណោះ ចំណែកអរូបាវចរកុសលនិងអរូបាវចរកិរិយា អាចកើតបានក្នុងភូមិដទៃៗបាន វៀរតែអបាយភូមិ ព្រោះអបាយសត្វ មិនអាចចម្រើនភាវនា ឲ្យបានសម្រេចឈាន មគ្គផលបាន ដោយហេតុថាមិនបានបដិសន្ធិដោយត្រៃហេតុ ចំណែកឯតាំងពីកាមសុគតិភូមិឡើងទៅ តិហេតុកបុគ្គល អាចចម្រើនភាវនាឲ្យសម្រេចដល់អរូបឈាន-កុសលបាន ឬ ព្រះអរហន្ត អាចចម្រើនអរូបភាវនា រហូតដល់សម្រេចអរូបជ្ឈានកិរិយាបាន ដោយហេតុនោះ ចំពោះអរូបាវចរ-វិបាក សឹងធ្វើនាទីបដិសន្ធិ ភវង្គ ចុតិ របស់អរូបបុគ្គលដោយចំពោះទើបពោលបានថា អរូបាវចរវិបាកចិត្តកើតបាន ចំពោះតែក្នុងអរូបភូមិប៉ុណ្ណោះ ។ ដូច្នេះហើយ ទើបអរូបាវចរវិបាកចិត្ត ៤ ដួងនេះ មិនចាំបាច់ត្រូវមានវត្ថុរូប ជាទីអាស្រ័យកើតឡើយ ។

## ចេតសិកជាមួយនឹងវត្ថុរូប

ចិត្តអាស្រ័យវត្ថុរូបកើត យ៉ាងណា ចេតសិកដែលជាធម៌ប្រកបជាមួយនឹងចិត្ត ក៏រមែងអាស្រ័យវត្ថុរូបកើត ក៏យ៉ាងនោះដែរ ។

## ការចែកចេតសិក ៥២ ដោយវត្ថុរូប ៦

**១.** ចេតសិក ដែលអាស្រ័យ ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ

ជីវ្ហាវត្ថុ កាយវត្ថុកើត **ដោយប្រាកដ** មិនមាន ។

**២.** ចេតសិក ដែលអាស្រ័យចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជីវ្ហាវត្ថុ កាយវត្ថុកើត **ដោយមិនប្រាកដ** មាន **៧** ដួង គឺ :

- សព្វចិត្តសាធារណចេតសិក **៧** ដែលប្រកបជាមួយនឹង ទ្វិបញ្ចវិញ្ញាណចិត្ត **១០**

**៣.** ចេតសិក ដែលអាស្រ័យហទយវត្ថុកើត **ដោយប្រាកដ** មាន **៦** ដួង គឺ :

- ទោចតុកចេតសិក **៤** ព្រោះតែងកើត ចំពោះតែក្នុងកាមភូមិ **១១**
- អប្បមញ្ញាចេតសិក **២** ព្រោះតែងកើតបាន តែក្នុងបញ្ចវោការភូមិប៉ុណ្ណោះ

**៤.** ចេតសិកដែលអាស្រ័យហទយវត្ថុ កើតដោយមិនប្រាកដ មាន **៤៦** ដួង គឺ :

- អញ្ញសមានាចេតសិក **១៣**
- អកុសលចេតសិក **១០** (វៀរទោចតុកចេតសិក៤)

- សោភណចេតសិក **២៣** (វៀរអប្បមញ្ញាចេតសិក២)

ដូច្នេះ ចេតសិកដែលអាស្រ័យវត្ថុរូប កើតដោយប្រាកដ មាន **៦** ដួង គឺ :

- ទោចតុកចេតសិក **៤**
- អប្បមញ្ញាចេតសិក **២**

ចេតសិក ដែលអាស្រ័យ **វត្ថុរូបកើតដោយមិនប្រាកដ** មាន **៤៦** ដួង គឺចេតសិក **៤៦** ( វៀរទោចតុកចេតសិក **៤** អប្បមញ្ញាចេតសិក **២** ) បានសេចក្ដីថា ចេតសិក **៤៦** ដួង នេះ បើកើតក្នុងបញ្ចវោការភូមិ ក៏អាស្រ័យវត្ថុរូបកើត បើកើតក្នុងចតុវោការភូមិ ក៏មិនបានអាស្រ័យវត្ថុរូបកើត ។

## វត្ថុជាមួយនឹងទ្វារ

- **វត្ថុ** ជាទីអាស្រ័យកើតរបស់ចិត្តនិងចេតសិក ។
- **ទ្វារ** ជាច្រកសម្រាប់ឲ្យ ចិត្ត និង ចេតសិក ទទួលដឹងអារម្មណ៍ ដោយការប្រាកដឡើង **ជាវិថីចិត្ត** ។

ដូច្នេះ ទាំងទ្វារ ទាំងវត្ថុ នីមួយៗក៏ជាទីអាស្រ័យរបស់ចិត្ត និងចេតសិកដូចគ្នា គឺ វត្ថុនោះ ជាទីអាស្រ័យរបស់ចិត្តនិងចេតសិក ចំណែកឯ **ទ្វារ** ជាផ្លូវសម្រាប់ឲ្យចិត្តនិងចេតសិក ទទួលដឹងអារម្មណ៍។ ដូច្នេះ ចិត្ត និងចេតសិក ដែលប្រាកដឡើងគ្រប់ៗខណៈ មានសម្ពន្ធគ្នារវាងវត្ថុ និង ទ្វារដោយច្រើន ទើបអាចចែកចេញបាន ជា **៤ ន័យ** គឺ :

- ចិត្តដែលត្រូវអាស្រ័យ ទាំងវត្ថុ និង ទាំងទ្វារ
- ចិត្តដែលត្រូវអាស្រ័យ វត្ថុ តែមិនអាស្រ័យទ្វារ
- ចិត្តដែលមិនត្រូវអាស្រ័យ វត្ថុ តែត្រូវអាស្រ័យទ្វារ
- ចិត្តដែលមិនត្រូវអាស្រ័យ ទាំងវត្ថុ និង ទាំងទ្វារ

**១. ចិត្តដែលត្រូវអាស្រ័យទាំងវត្ថុ និង ទាំងទ្វារមាន ៣៨ ដួង គឺ :**

- ទោសមូលចិត្ត **២**
- អហេតុកចិត្ត **១៧** ( វៀរឧបេក្ខាមនោវិញ្ញាណធាតុ- អហេតុកកិរិយាចិត្ត ១ )
- មហាវិបាកចិត្ត **៨**
- រូបាវចរកុសលចិត្ត **៥**

- រូបាវចរកិរិយាចិត្ត **៥**
- សោតាបត្តិមគ្គចិត្ត **១**

រួមចិត្តទាំង **៣៨** ដួងនេះ ត្រូវអាស្រ័យទាំងវត្ថុ និងទាំងទ្វារ ទើបអាចប្រាកដឡើងបាន ។

## សង្កេត :

សេចក្តីផ្សេងៗគ្នារវាងចិត្តដែលអាស្រ័យវត្ថុកើត និងចិត្តអាស្រ័យទ្វារកើតនោះ មានចំនួនមិនស្មើគ្នាទេ គឺ ចិត្តដែលអាស្រ័យវត្ថុកើតមានចំនួនកំណត់ដោយចំពោះតែឯកន្តៈ ប៉ុន្តែចិត្តដែលអាស្រ័យទ្វារកើតនោះ ចំនួនរបស់ចិត្តកើតបានទូលំទូលាយច្រើនជាងគ្នា គឺ :

## ចិត្តដែលអាស្រ័យវត្ថុ ៦

| | | | | |
|---|---|---|---|---|
| - ចក្ខុវត្ថុ | ចិត្តអាស្រ័យកើត | | **២** | ដួង |
| - សោតវត្ថុ | ” | ” | **២** | ដួង |
| - ឃានវត្ថុ | ” | ” | **២** | ដួង |
| - ជិវ្ហាវត្ថុ | ” | ” | **២** | ដួង |
| - កាយវត្ថុ | ” | ” | **២** | ដួង |
| - ហទយវត្ថុ | ” | ” | **៧៥** | ដួង |

# ចិត្តដែលអាស្រ័យទ្វារ ៦

| | | | |
|---|---|---|---|
| - ចក្ខុទ្វារ | ចិត្តកើតបាន | **៤៦** | ដួង |
| - សោតទ្វារ | ” ” | **៤៦** | ដួង |
| - ឃានទ្វារ | ” ” | **៤៦** | ដួង |
| - ជីវ្ហាទ្វារ | ” ” | **៤៦** | ដួង |
| - កាយទ្វារ | ” ” | **៤៦** | ដួង |
| - មនោទ្វារ | ” ” | **៦៧** | ដួង |

អរូបាវចរវិបាកចិត្ត **៤** មិនបាច់អាស្រ័យវត្ថុរូបទេ មហគ្គតវិបាកចិត្ត **៩** ក៏មិនបាច់អាស្រ័យទ្វារដែរ ។

## ២. ចិត្តដែលត្រូវអាស្រ័យវត្ថុ តែមិនអាស្រ័យទ្វារ មាន ៥ ដួង គឺ :

- រូបាវចរវិបាកចិត្ត **៥** ដួង

រូបាវចរវិបាកចិត្ត **៥** ដួងនេះ ត្រូវអាស្រ័យហទយវត្ថុរូបកើត ព្រោះរូបាវចរវិបាក ជាចិត្តរបស់ព្រហ្មបុគ្គល ដែលធ្វើនាទីបដិសន្ធិ ភវង្គ ចុតិ ។ បដិសន្ធិរបស់ព្រះព្រហ្មបុគ្គលនោះ ត្រូវអាស្រ័យ

ហទយវត្ថុរូប គឺ ត្រូវអាស្រ័យដល់គ្នានិងគ្នា ដោយអំណាច អញ្ញមញ្ញបច្ច័យ ។

ចំណែករូបាវចរវិបាក ដែលមិនត្រូវអាស្រ័យទ្វារកើតនោះ ព្រោះរូបាវចរវិបាក ធ្វើនាទីត្រឹមតែ បដិសន្ធិ ភវង្គ ចុតិ ជាឯកន្តៈ ទ្វារវិមុត្តិចិត្ត គឺ ចិត្តដែលកើតផុតចាកទ្វារដោយប្រាកដ ទើបមិនចាំបាច់អាស្រ័យទ្វារណាឡើយ ។

## ៣. ចិត្តដែលមិនត្រូវអាស្រ័យវត្ថុ តែត្រូវអាស្រ័យទ្វារមាន ៤២ ដួង គឺ :

- អកុសលចិត្ត **១០** ( វៀរទោសមូលចិត្ត **២** )
- ឧបេក្ខាមនោវិញ្ញាណធាតុអហេតុកកិរិយាចិត្ត ១
- មហាកុសលចិត្ត ៨
- មហាកិរិយាចិត្ត ៨
- អរូបាវចរកុសលចិត្ត ៤
- អរូបាវចរកិរិយាចិត្ត ៤
- លោកុត្តរចិត្ត **៧** ( វៀរសោតាបត្តិមគ្គចិត្ត ១ )

រួមចិត្ត **៤២** ដួងនេះ កាលកើតជាមួយនឹងអរូបព្រហ្មបុគ្គល ហើយ មិនត្រូវអាស្រ័យវត្ថុរូបកើតឡើយ ព្រោះអរូបព្រហ្មបុគ្គលនោះ

មិនមានវត្ថុរូបទាំង **៦** ។ តែចិត្ត **៤២** ដួងនេះ ត្រូវតែអាស្រ័យទ្វារ គឺ មនោទ្វារ ទើបអាចកើតបាន ដែលក្នុងអរូបព្រហ្មបុគ្គលមាន ត្រឹមតែមនោទ្វារមួយប៉ុណ្ណោះ ទើបជាទីអាស្រ័យនៃចិត្ត **៤២** ដួង នោះ កើតតាមមនោទ្វារបាន ។

## ៤. ចិត្តដែលមិនត្រូវអាស្រ័យទាំងវត្ថុ និង ទាំងទ្វារ មាន ៤ ដួង គឺ :

- អរូបាវចរវិបាកចិត្ត **៤** ដួង

អរូបាវចរវិបាកចិត្ត **៤** ដួងនេះ មិនត្រូវអាស្រ័យវត្ថុ ព្រោះមិនមានវត្ថុដែលនឹងត្រូវអាស្រ័យ និង មិនត្រូវអាស្រ័យទ្វារនោះ ព្រោះជាឯកន្តៈទ្វារវិមុត្តិចិត្ត គឺ ចិត្តដែលផុតចាកទ្វារដោយប្រាកដ ធ្វើនាទីបដិសន្ធិ ភវង្គ ចុតិ របស់អរូបព្រហ្មបុគ្គល ក្នុងអរូបភូមិ **៤** ប៉ុណ្ណោះ។

# អវសានគាថា

ឥច្ចានុរុទ្ធរចិតេ អភិធម្មត្ថសង្គហេ
តតិយោ បរិច្ឆេទោយំ សមាសេនេវ និដ្ឋិតោ

បរិច្ឆេទទី ៣ ឈ្មោះថា បកិណ្ណកសង្គហវិភាគ ក្នុងបករណ៍អភិធម្មត្ថសង្គហៈ ដែលព្រះអនុរុទ្ធាចារ្យបានរចនាទុកហើយ ចប់ដោយសង្ខេប ដោយប្រការយ៉ាងនេះឯង ៕

**( ចប់ បរិច្ឆេទទី ៣ )**

ដោយចេតនាដែលជាកុសលសម្បទា បំពេញកុសលជាធម្មទាន ក្នុងឱកាសនេះ សូមចូរជាបច្ច័យបញ្ញាបារមី ឲ្យសាធុជនទាំងឡាយ ដល់នូវសេចក្តីសុខក្សេមក្សាន្តសំរាន្តស្រួល ផុតចាកទុក្ខភ័យទាំងពួង អស់កាលជានិច្ចតទៅហោង ៕

ប្រែចប់ នៅថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៣

ធម្មាចារ្យ **រស់ សុផាត**

# មាតិកា


| រឿង | ទំព័រ |
|---|---|
| បកិណ្ណកសង្គហវិភាគ............................. | ១ |
| គាថាសង្គហៈ...................................... | ២ |
| វេទនាសង្គហៈ.................................... | ៤ |
| គាថាសង្គហៈ...................................... | ៤ |
| អធិប្បាយ........................................... | ៥ |
| ន័យទី១ អារម្មណានុភវនលក្ខណន័យ មានវេទនា ៣ | ៦ |
| សម្តែងការចំណែកចិត្ត ១២១ ដោយវេទនា ៣...... | ៧ |
| ចំណែកចិត្តដោយវេទនាទាំង ៥.................... | ១០ |
| ន័យទី២ ឥន្ទ្រិយភេទន័យ មានវេទនា ៥......... | ១១ |
| គាថាសង្គហៈ.................................... | ១១ |
| សម្តែងការចំណែកចិត្ត ១២១ ដោយវេទនា ៥........ | ១៤ |
| ការចំណែកចិត្ត ១២១ ដោយវេទនា ៥ ទៀត........ | ១៥ |
| វេទនានិងចេតសិក............................ | ១៧ |
| វេទនាកើតនិងចេតសិក......................... | ១៧ |
| ចេតសិកដែលកើតព្រមនិងវេទនា.................. | ១៩ |

ហេតុសង្គហៈ.................................. ២១



# មាតិកា

| រឿង | ទំព័រ |
|---|---|
| គាថាសង្គហៈ.................................. | ២១ |
| អធិប្បាយ........................................ | ២១ |
| សម្តែងការចែកចិត្តដោយហេតុ និងគាថាសង្គហៈ... | ២៤ |
| អធិប្បាយ........................................ | ២៤ |
| ចំណែកហេតុដោយប្រភេទនៃសោភណៈនិងអសោភណៈ | ២៧ |
| ហេតុជាមួយនិងធម៌.............................. | ២៨ |
| ចំណែកហេតុដោយប្រភេទនៃធម៌................. | ២៨ |
| ចំណែកហេតុដោយប្រភេទនៃជាតិ................. | ២៩ |
| ចំណែកដោយប្រភេទនៃភូមិ...................... | ៣០ |
| ចំណែកហេតុដោយប្រភេទនៃបុគ្គល............... | ៣១ |
| សម្តែងហេតុជាមួយនិងចេតសិក...................... | ៣២ |
| សម្តែងការចំណែកចេតសិកដែលប្រកប- និងហេតុដោយអគហិតគហានន័យ .......... | ៣៤ |
| សម្តែងការចំណែកចេតសិក ដែល- ប្រកបនិងហេតុដោយគហិតគហានន័យ ....... | ៣៧ |

ការរាប់ចំនួនហេតុដោយពិស្ដារ.................... ៤១



មាតិកា


| រឿង | ទំព័រ |
|---|---|
| កិច្ចសង្គហៈ.......................................... | ៤៤ |
| គាថាសង្គហៈ........................................ | ៤៤ |
| អធិប្បាយ............................................ | ៤៤ |
| សម្ដែងកិច្ចរបស់ចិត្ត ១៤............................ | ៤៧ |
| អធិប្បាយ............................................. | ៤៨ |
| សម្ដែងការចំណែកកិច្ច ១៤ ដោយចិត្ត............... | ៥៣ |
| សម្ដែងការចំណែកចិត្ត៨៩ ឬ១២១ ដោយកិច្ច ១៤... | ៥៦ |
| សម្ដែងការចំណែកចេតសិក ៥២ ដោយកិច្ច ១៤... | ៥៩ |
| អធិប្បាយ........................................ | ៦០ |
| ស្ថានទាំង ១០................................... | ៦៧ |
| សម្ដែងការចំណែកស្ថាន ១០ ដោយចិត្ត............. | ៦៨ |
| សម្ដែងការចំណែកចិត្ត ដោយកិច្ចនិងស្ថាន............ | ៧១ |
| គាថាសង្គហៈ.................................... | ៧១ |
| អធិប្បាយ........................................ | ៧១ |
| សម្ដែងស្ថានដោយពិស្ដារមាន ២៥ ស្ថាន............ | ៧៤ |

សម្ដែងការចំណែកស្ថាន ២៥ ដោយន័យនៃវិថីចិត្ត.... ៧៦


# មាតិកា


| រឿង | ទំព័រ |
|---|---|
| ទ្វារសង្គហៈ.............................................. | ៨០ |
| ទ្វារ...................................................... | ៨១ |
| គាថាសង្គហៈ.............................................. | ៨១ |
| អធិប្បាយ................................................ | ៨២ |
| គាថាសង្គហៈ.............................................. | ៨៤ |
| អធិប្បាយ.................................................. | ៨៤ |
| សម្ដែងទ្វារិកចិត្ត និងទ្វារវិមុត្តិចិត្ត ដោយឯកន្តៈ និងអនេកន្តៈ ............. | ៨៦ |
| ចេតសិកនិងទ្វារ................................... | ៩១ |
| ចំណែកចេតសិកដោយទ្វារ ជាឯកន្តៈ និងអនេកន្តៈ. | ៩២ |
| អធិប្បាយ.................................................. | ៩៣ |
| អារម្មណសង្គហៈ........................................ | ៩៨ |
| អារម្មណ៍ ៦ ប្រភេទ.............................. | ៩៩ |
| អធិប្បាយ.............................................. | ៩៩ |
| អំណាចរបស់អារម្មណ៍............................ | ១០២ |

ការចំណែកទ្វារិកចិត្តនិងទ្វារវិមុត្តិចិត្ត ដោយអារម្មណ៍ ៦ ១០៤


## មាតិកា


| រឿង | ទំព័រ |
|---|---|
| អធិប្បាយ.......................................... | ១០៥ |
| សម្ដែងចិត្តដែលទទួលអារម្មណ៍ដោយឯកន្តៈ- ៤ ប្រភេទ និងដោយអនេកន្តៈ ៣ ប្រភេទ .... | ១០៩ |
| គាថាសង្គហៈ........................................ | ១០៩ |
| អធិប្បាយ.......................................... | ១១១ |
| ចំណែកចិត្ត ៦០ ឬ ៩២ ដែលទទួលអារម្មណ៍ប្រាកដ ដោយអារម្មណ៍ ៦ និងកាល ៣ | ១១៤ |
| ចំណែកចិត្ត ៣១ ដែលទទួលអារម្មណ៍មិន-ប្រាកដ ដោយអារម្មណ៍ ៦ និងកាល ៣ | ១១៨ |
| អធិប្បាយក្នុងគាថាទី ១១........................ | ១១៩ |
| មហគ្គតអារម្មណ៍.................................. | ១២១ |
| បញ្ញត្តិអារម្មណ៍.................................... | ១២៥ |
| និព្វានអារម្មណ៍.................................. | ១២៦ |
| កាលវិមុត្តអារម្មណ៍.............................. | ១២៧ |
| អធិប្បាយក្នុងគាថាទី ១២ សព្វារម្មណ៍........... | ១៣០ |

អារម្មណ៍របស់ទ្វារវិមុត្តិចិត្ត.......................... ១៣២




## មាតិកា


| រឿង | ទំព័រ |
|---|---|
| កម្មអារម្មណ៍.................................... | ១៣៦ |
| កម្មនិមិត្តអារម្មណ៍.............................. | ១៣៩ |
| គតិនិមិត្តអារម្មណ៍.............................. | ១៤២ |
| អារម្មណ៍ពិស្តារ ២១.............................. | ១៥០ |
| សម្តែងអារម្មណ៍ពិស្តារ ២១ ប្រភេទ................ | ១៥១ |
| ការចំណែកចិត្ត ដែលទទួលអារម្មណ៍ ដោយឯកន្តៈ និងអនេកន្តៈ.......... | ១៥៣ |
| កាមអារម្មណ៍.................................... | ១៥៣ |
| មហគ្គតអារម្មណ៍............................... | ១៥៤ |
| និព្វានអារម្មណ៍............................... | ១៥៦ |
| នាមអារម្មណ៍..................................... | ១៥៧ |
| រូបអារម្មណ៍...................................... | ១៥៨ |
| អតីតអារម្មណ៍.................................. | ១៥៩ |
| អនាគតអារម្មណ៍................................ | ១៦០ |
| បច្ចុប្បន្នអារម្មណ៍............................. | ១៦០ |

កាលវិមុត្តិអារម្មណ៍.................................. ១៦១



មាតិកា

រឿង ទំព័រ

បញ្ញត្តិអារម្មណ៍.................................. ១៦៣
បរមត្ថអារម្មណ៍.................................. ១៦៤
អជ្ឈត្តអារម្មណ៍.................................. ១៦៥
ពហិទ្ធអារម្មណ៍.................................. ១៦៦
អជ្ឈត្តពហិទ្ធអារម្មណ៍............................ ១៦៧
បញ្ចារម្មណ៍.................................... ១៦៨
រូបារម្មណ៍...................................... ១៦៩
សទ្ទារម្មណ៍...................................... ១៧០
គន្ធារម្មណ៍...................................... ១៧១
រសារម្មណ៍.................................... ១៧២
ផោដ្ឋព្វារម្មណ៍.............................. ១៧៣
ធម្មារម្មណ៍........................................ ១៧៤
ការសម្តែងអារម្មណ៍របស់ចិត្ត........................ ១៧៥
អធិប្បាយ...................................... ១៧៦
ចេតសិកនិងអារម្មណ៍.......................... ១៨០

# មាតិកា


| រឿង | ទំព័រ |
|---|---|
| ចំណែកចេតសិកទទួលអារម្មណ៍ ២១ ដោយឯកន្តៈ និងដោយអនេកន្តៈ........... | ១៨២ |
| វត្ថុសង្គហៈ.................................. | ១៨៧ |
| វត្ថុ ៦........................................ | ១៨៧ |
| អធិប្បាយ.................................... | ១៨៨ |
| ភូមិ ៣០ វត្ថុរូប ៦ និងវិញ្ញាណធាតុ ៧........... | ១៩០ |
| គាថាសង្គហៈ.................................. | ១៩០ |
| អធិប្បាយ.................................... | ១៩១ |
| ភូមិជាមួយនិងវត្ថុ.............................. | ១៩២ |
| ការចំណែកវិញ្ញាណធាតុ ៧ យ៉ាងដែលកើតក្នុងកាមភូមិ ១១ ដោយវត្ថុរូប ៦ ....... | ១៩៣ |
| វិញ្ញាណធាតុ ១ យ៉ាង ដែលកើតក្នុងអរូបភូមិ ៤ ដោយមិនបានអាស្រ័យវត្ថុរូប ........ | ១៩៤ |
| ចិត្តជាមួយនិងវត្ថុ.............................. | ១៩៤ |
| គាថាសង្គហៈ................................ | ១៩៥ |

អធិប្បាយ......................................... ១៩៥



## មាតិកា

| រឿង | ទំព័រ |
| --- | --- |
| ការចំណែកចិត្ត ៨២ ដួងអាស្រ័យវត្ថុរូបកើតមិនប្រាកដដោយវត្ថុរូប ៦ ............ | ១៩៧ |
| អរូបាវចរវិបាកចិត្ត៤ មិនអាស្រ័យវត្ថុរូបកើតដោយប្រាកដ ............ | ១៩៨ |
| ចេតសិកជាមួយនិងវត្ថុរូប.......................... | ១៩៩ |
| ការចំណែកចេតសិក ៥២ ដោយវត្ថុរូប ៦......... | ២០០ |
| វត្ថុជាមួយនិងទ្វារ................................... | ២០១ |
| ចិត្តដែលអាស្រ័យវត្ថុ ៦............................ | ២០៣ |
| ចិត្តដែលអាស្រ័យទ្វារ ៦........................... | ២០៤ |
| អវសានគាថា........................................ | ២០៦ |